ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរ**

**នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី “ឌុច”**

**សាធារណៈ**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩**

**សវនាការលើកទី៥៣**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាតាចា វិចស៊ែល រីស៊ឺ

*(Ms. Natacha Wexels-Riser)*

លោក អាឡាញ ប្រ៊ែអត *(Mr. Aline BRIOT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក អានីស អះមេដ *(Mr. Anees AHMED)*

លោក ពេជ្រ សម្បត្តិ

លោក *ហ្សាឆិរី ឡាំពែល (Mr.Zachery LAMPEL)*

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

កញ្ញា ទី ស្រ៊ីនណា

កញ្ញា ម៉ុច សុវណ្ណារី

លោក គង់ ពិសី

លោកស្រី ស៊ីលឃី ស្ទូតហ្ស៊ីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វ៉ែនណឺ*(Mr. Alain Werner)*

លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស

*(Ms. Fabienne Trusse-Naprous)*

**មេធាវីជំនួយការរបស់សាក្សី៖**

លោក គង់ សំអុន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

## សាក្សី

### លោក ឡាច មាន

សួរដោយ លោក តាន់ សេណារ៉ុង ផ្ដើមពី ....................ទំព័រ ២
សួរដោយ លោក អានីស អះមេដ ផ្ដើមពី....................ទំព័រ ១៥
សួរដោយ កញ្ញា ទី ស្រ៊ុនណា ផ្ដើមពី ....................ទំព័រ ២២
សួរដោយ លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី ផ្ដើមពី ....................ទំព័រ ២៩
សួរដោយ លោក ការ សាវុត្ថ ផ្ដើមពី....................ទំព័រ ៣៥
សួរដោយ លោក ហ្វេង់ស្វ័រ រ៉ូ ផ្ដើមពី....................ទំព័រ ៤៣

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោក ឡាច មាន | ខ្មែរ |
| លោក តាន់ សេណារ៉ុង | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោក អាឡាំង វែនណឺ | អង់គ្លេស |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក អានីស អះមេដ | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី (ក្រឡាបញ្ជី) | ខ្មែរ |
| លោក ឌុច ផារី (ក្រឡាបញ្ជី) | ខ្មែរ |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| កញ្ញា ទី ស្រ៊ីនណា | ខ្មែរ |
| លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:០៧:៣១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោល ។ ហើយនៅព្រឹកនេះយើងបន្តស្តាប់សក្ខីកម្មសាក្សី ឡាច មាន ។

មុននឹងប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា សូមក្រឡាបញ្ជីឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលត្រូវចូលរួមនៅក្នុងដំណើរការសវនាការសម្រាប់ថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន! ភាគីដែលត្រូវចូលរួម នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការ ក្នុងថ្ងៃនេះមានវត្តមាន ។ ចំណែកឯ សាក្សី ឡាច មាន មានវត្តមាន ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការសួរសំណួរដល់សាក្សីរូបនេះ ។ តំណាងសហព្រះរាជអាជ្ញាមានពេលវេលាសាមសិបនាទីក្នុងការសួរសាក្សីរូបនេះ ។ សូមអញ្ជើញ ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា៖**

**លោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ និងសូមស្វាគមន៍លោក ឡាច មាន ។

តំណាងសហព្រះរាជអាជ្ញា មានសំណួរដូចខាងក្រោមជូនលោក ។ កាលពីម្សិលមិញហ្នឹង លោកបានជម្រាបជូនអង្គជំនុំជម្រះ អំពីធុង និងកែសគ្រាប់ដែលលោកបានបញ្ជាក់ជូនអង្គជំនុំជម្រះថាបានប្រើប្រាស់សម្រាប់ទុកឲ្យអ្នកទោស ដើម្បីធ្វើការបន្ទោបង់ ។ អ៊ីចឹង សុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីបង្ហាញរូបភាពមួយ ដែលមានលេខ ERN 00181445 នៅក្នុង D48/2 ។ ERN 00181445 ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងសោតទស្សន៍ សូមបង្ហាញនូវឯកសារដែលមានលេខ ERN ជាភាសាខ្មែរ 00181445 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

[០៩:១០:៥៣]

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** នេះគឺជារូបភាពដែលមានកែសគ្រាប់និងធុងទឹកមួយដែលលោកបានបញ្ជាក់ជូនអង្គជំនុំជម្រះកាលពីម្សិលមិញថា បានប្រើប្រាស់សម្រាប់ដាក់បន្ទោបង់នូវលាមករបស់អ្នកទោស ។ លោក ឡាច មាន សូមលោកបញ្ជាក់ឡើងវិញមើល៍ថា តើកែសគ្រាប់ប្រភេទហ្នឹង ហើយនិងដូចមាននៅក្នុងរូបភាពហ្នឹង និងកូនធុងមួយហ្នឹងដែលបានប្រើប្រាស់ នៅក្នុងសម័យកាលនោះមែនទេលោក?

**ឆ៖** បាទ គឺសម័យកាលនោះ គឺប្រើនូវធុងនេះ គឺកែសគ្រាប់នេះមែន ។

**ស៖** អរគុណលោក ។ សំណួរបន្ទាប់ជូនលោក។ សុំអង្គជំនុំជម្រះដើម្បីបង្ហាញរូបមួយទៀតដែលមានលេខ 00181435 នៅក្នុង D48/2 ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងសោតទស្សន៍ សូមបង្ហាញឯកសារដែលមានលេខ ERN ដូច ការបង្ហាញរបស់តំណាងសហព្រះរាជអាជ្ញាជាតិ ទៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

**សួរដោយ លោក តាន់ សេណារ៉ុង៖**

**ស៖** លោក ឡាច មាន សូមលោកបញ្ជាក់ឡើងវិញនូវអ្វីដែលលោកបានជម្រាបជូនអង្គជំនុំជម្រះកាលពីម្សិលមិញថា រូបភាពដែលគេបានដាក់អ្នកទោសនៅក្នុងបន្ទប់ធំហ្នឹង គឺគេដាក់តាមប្រភេទដូចរូបភាពរបស់លោក វ៉ាន់ ណាត អ៊ីចឹងមែនទេលោក?

**ឆ៖** បាទ, ចំពោះរូបភាពដាក់នៅក្នុងបន្ទប់ធំ គឺរូបភាពដូចរូបភាពនេះឯង ។

**លោក តាន់ សេណារ៉ុង៖**

សអរគុណលោក ឡាច មាន ។ សំណួរបន្ទាប់ជូនលោក ខ្ញុំសុំការអនុញ្ញាតពីអង្គជំនុំជម្រះ ដើម្បីបង្ហាញនូវឯកសារមួយ ដែលមានហត្ថលេខារបស់លោក ឡាច មាន ។ ប៉ុន្តែ ឯកសាររបស់ចម្លើយសារភាពនោះ វាមិនមាននៅក្នុង*ខេសហ្វាល* របស់យើងទេ ដែលទើបតែការិយាល័យសហព្រះរាជអាជ្ញាហ្នឹងបានរកឃើញ ។ ក៏ប៉ុន្តែ អ្នកទោសដែលមាននៅក្នុងចម្លើយសារភាពដែលមានចុះហត្ថលេខាដោយលោក ឡាច មាន ហ្នឹងវាមាននៅក្នុងបញ្ជីអ្នកទោសរបស់យើង ។ ហើយឥឡូវខ្ញុំសូម មន្ត្រីតុលាការយកសុំឯកសារនេះ យកទៅជូនលោកប្រធានអង្គជំនុំជម្រះ និងភាគីដែលពាក់ព័ន្ធនៅ-- និងលោក ឡាច មាន ដែលមានហត្ថលេខារបស់លោក ឡាច មាន ហើយនិង *លីស* របស់អ្នកទោសដែលមាននៅក្នុង *ខេស*

*ហ្វាល* របស់យើងនេះ ។ សូមអញ្ជើញ ។

[០៩:១៤:៣៥]

ហើយសំណួរបន្ទាប់ទៀត ខ្ញុំចង់ជម្រាបជូនអង្គជំនុំជម្រះដែរថា ការិយាល័យសហព្រះរាជអាជ្ញាហ្នឹងបានរកឃើញសាក្សីឈ្មោះ ឡាច មាន ហ្នឹងបានសួរចម្លើយអ្នកទោសហ្នឹងចំនួនដប់ប្រាំរូប ។ ក្នុងនោះដែរការិយាល័យសហព្រះរាជអាជ្ញា បានរកឃើញបួន ចម្លើយសារភាពហ្នឹងឥឡូវហ្នឹងគឺមានបួនហើយដែលមានពីរដែលមាននៅក្នុង*ខេសហ្វាល*របស់យើងដែលមានលេខ ERN លេខ 00303131 ក្នុង D159/5.39 និងចម្លើយសារភាពមួយទៀតមានលេខ 00296255 ដែលមាននៅលេខ D159/5.2 ។ ចម្លើយសារភាពពីរហ្នឹងមាននៅក្នុងសំណុំរឿង ហើយឯកសារដែលខ្ញុំជូនលោកប្រធានអង្គជំនុំជម្រះអម្បាញ់មិញ ចម្លើយសារភាពនោះគ្មានទេ ប៉ុន្តែបញ្ជីអ្នកទោសហ្នឹងមាននៅក្នុង *លីស* របស់យើង ។ ហើយឯកសារមួយទៀត ដែលខ្ញុំចង់ជម្រាបជូនអង្គជំនុំជម្រះដែលមាន-- ដែលគ្មាននៅក្នុងសំណុំរឿងនោះឈ្មោះ អ្នកទោសនោះឈ្មោះ អ៊ុំ រាម ហៅ ធឿន ជាសមាជិកកងធំនៅមន្ទីរក-១៦ ក្រសួងស-១៧ អាយុ២៨ឆ្នាំ ហើយមានហត្ថលេខារបស់លោក ឡាច មាន ជាអ្នកសួរដែរ ចុះនៅថ្ងៃទី០៣ ខែ០៨ ឆ្នាំ ១៩៧៨ ។

តំណាងសហព្រះរាជអាជ្ញា សូមជម្រាបជូនអង្គជំនុំជម្រះថា សុំដាក់ឯកសារនេះទៅក្នុងសំណុំរឿងផងដែរ ដែលការិយាល័យសហព្រះរាជអាជ្ញាហ្នឹងបានរកឃើញ ។ ហើយចម្លើយសារភាពដទៃទៀត ដែលមានហត្ថលេខារបស់លោក ឡាច មាន ខ្ញុំនឹងរៀបចំឯកសារបន្តបន្ទាប់ទៀត ដើម្បីនឹងជូនទៅអង្គជំនុំជម្រះ ប្រសិនបើអង្គជំនុំជម្រះហ្នឹង តម្រូវការឲ្យដាក់ជូន ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** សំណួរសួរលោក ឡាច មាន ថាតើលោក ឡាច មាន លោកបានឃើញឯកសារដែលខ្ញុំបានជូនលោកអម្បាញ់មិញហ្នឹងទេ? ហើយលោកទទួលស្គាល់ថា ហត្ថលេខាហ្នឹងជាហត្ថលេខារបស់លោកមែនទេ?

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា ឯកសារនេះថ្មី ហើយភាគីមិនទាន់បានធ្វើការកត់សម្គាល់ ហើយអង្គជំនុំជម្រះមិនទាន់សម្រេច ថាតើត្រូវដាក់ឯកសារនេះដេញដោល ឬអត់ទេ? ស្រាប់តែលោក

មកធ្វើការដេញដោលដោយភាគីមិនទាន់បានធ្វើការកត់សម្គាល់ ហើយអង្គជំនុំជម្រះមិនទាន់សម្រេចផង នីតិវិធីនេះដូចយើងអត់ទាន់ អត់ដែលមានទេ ។

[០៩:១៧:១៣]

**លោក តាន់ សេណារ៉ុង៖**

សុំបន្ត បើអ៊ីចឹង ខ្ញុំសុំដាក់នូវឯកសារដែលមាននៅក្នុងសំណុំរឿងរបស់យើងពីរទៀត ដែលមានលេខ ERN ដែលខ្ញុំបានជម្រាបជូនអង្គជំនុំជម្រះអម្បាញ់មិញនេះ គឺលេខ 00303157 នៅក្នុង D159/5.39 និងឯកសារមួយទៀតលេខ 00296499 នៅក្នុង D159/5.2 ។ ឯកសារទាំងពីរនេះ មាននៅក្នុងសំណុំឯកសាររបស់យើងហើយ ។ ហើយដែលមានហត្ថលេខារបស់លោក ឡាច មាន បាទ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ លោកសុំដាក់ឯកសារណាដេញដោលមុន? ឯកសារណាដាក់ដើម្បីសុំអង្គជំនុំជម្រះសម្រេចដើម្បីដាក់ពិភាក្សាដេញដោល? សុំលោកបង្ហាញឲ្យបានច្បាស់លាស់នូវជំហរនៃការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ ដើម្បីងាយស្រួលដល់អង្គជំនុំជម្រះគ្រប់គ្រងសវនាការផងហើយភាគីក៏ងាយស្រួលក្នុងការចូលរួម ដើម្បីធ្វើការដេញដោលផងដែរ ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ។ ខ្ញុំសុំដាក់ឯកសារដែលមានលេខ 00296255 D159/5.2។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ សូមបង្ហាញនូវឯកសារដែលមានលេខ ERN ដូចតំណាងសហព្រះរាជអាជ្ញាជាតិបានលើកឡើង លើអេក្រង់ទូរទស្សន៍ដើម្បីធ្វើការដេញដោល ។

ឈប់សិន ផ្អាកៗបន្តិចលោកសហព្រះរាជអាជ្ញា ។

លោក ហ្សង់ម៉ាក មានបញ្ហាអីសូមអញ្ជើញ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំមិនយល់ថាតើឥឡូវហ្នឹងមានរឿងអ្វីកើតឡើងទេ? ថាតើមានឯកសារដែលនិយាយអំពីអំមិញមានលេខ D159 ឬ? ហើយតើលេខយោងនៃឯកសារអស់ទាំងហ្នឹង គឺជាលេខយោងនៃឯកសារដែលមាននៅក្នុងសំណុំរឿងទីពីរឬ? បើសិនជាក្នុងករណីនេះមែន យើងត្រូវពិចារណាទៅលើឯកសារនេះសិនថាតើឯកសារហ្នឹងគួរតែដាក់នៅចំពោះមុខអង្គសវនាការ ឬក៏យ៉ាងម៉េច? ខ្ញុំយល់ថា ឥឡូវនេះមិនទាន់

ដល់ពេលត្រូវដាក់បញ្ចាំងឯកសារនេះនៅឡើយទេ យើងត្រូវពិភាក្សាគ្នាជាមុនសិន ។

**លោក តាន់ សេណារ៉ុង៖**

ឥឡូវ-- សូមអរគុណលោក ហ្សង់ម៉ាក ។ ឥឡូវខ្ញុំសុំបន្តសំណួរបន្ទាប់ទៀត ដោយមិនពិចារណាសំណួរនេះ ដើម្បីកុំឲ្យខាតពេលរបស់ការិយាល័យសហព្រះរាជអាជ្ញា។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** សំណួរជូនទៅលោក ឡាច មាន បន្ទាប់ទៀត ។ នៅក្នុងឆ្នាំ២០០២ លោក ឡាច មាន លោកបានផ្ដល់ការសម្ភាសន៍ទៅឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានលេខ ERN 00057066 នៅក្នុង D92/1 នៅក្នុងនោះលោកបានបញ្ជាក់ថា លោកបាននៅចាំបានថា លោកបានធ្លាប់បានសួរចម្លើយបុគ្គលម្នាក់តើលោកនៅចាំបានទេ ថាបុគ្គលនោះឈ្មោះអ្វី? ហើយប្រសិនបើមិនចាំលោកអាចសួរមកខ្ញុំវិញបានថា តើឈ្មោះអ្នកដែលលោកបានឆ្លើយប្រាប់គេនោះជាឈ្មោះអ្វីដែរ?

**ឆ៖** ចំពោះចម្លើយដែលខ្ញុំបានឆ្លើយនូវបទសម្ភាសន៍ជាមួយខាងមជ្ឈមណ្ឌលឯកសារគឺ ខ្ញុំកាលណោះ គឺខ្ញុំបានប្រាប់ថា ខ្ញុំនៅចាំឈ្មោះម្នាក់ ។ តែបច្ចុប្បន្នឥឡូវនេះ ខ្ញុំភ្លេចបាត់ហើយមិនដឹងឈ្មោះអីផង ។ ត្រឹម២០០២ មកទល់ពេលនេះយើងខ្ញុំភ្លេចបាត់ហើយ មិនដឹងថាឆ្លើយប្រាប់គាត់ថាឈ្មោះអីផង។

**លោក តាន់ សេណារ៉ុង៖**

សុំការអនុញ្ញាតពីលោកប្រធានអង្គជំនុំជម្រះ ដើម្បីនឹងយកឯកសារមួយសន្លឹកនេះទៅជូន លោក ដើម្បីឲ្យគាត់ធ្វើការចងចាំនូវឈ្មោះហ្នឹងវិញ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយកឯកសារហ្នឹងមកយើងពិនិត្យសិន។ ឯកសារហ្នឹងយកពីណាមកឯកសារហ្នឹង?

**លោក តាន់ សេណារ៉ុង៖**

ខ្ញុំបានជម្រាបជូនអង្គជំនុំជម្រះហើយថា ឯកសារហ្នឹងលេខ 00057066 ដែលមាន D92/1 ជាកិច្ចសម្ភាសន៍របស់លោក ឡាច មាន ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ។

**ប្រធានអង្គជំនុំ៖**

លោកអាចឲ្យលេខ ERN ជាភាសាបរទេសទាំងពីរដែរទេ ដើម្បីឲ្យភាគីពាក់ព័ន្ធផ្សេងទៀតបានទទួលនូវព័ត៌មានពីឯកសារនេះដើម្បីពិនិត្យសម្រេច ពីព្រោះឯកសារដែលមកពី *ឌីស៊ីខែម (DC-Cam)* នេះគឺយើង បានធ្វើកិច្ចការច្រើនលើកច្រើនសាហើយ ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ប្រសិនបើខ្ញុំមិនច្រឡំទេ នេះគឺជាឯកសារដែលមានលេខ D92/1 ដែលជាឧបសម្ព័ន្ធទី៦ ហើយមានលេខ ជាភាសាខ្មែរ 0005708 រហូតដល់លេខ 00057058 ហើយនិងភាសាអង់គ្លេសគឺមានលេខ 00335296 ហើយខ្ញុំគិតថា ឯកសារនេះមិនមានការបកប្រែជាភាសាអង់គ្លេសទេ ។

[០៩:២៣:៤៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមមួយ ។

មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមមួយសូមអញ្ជើញ ។

**លោក អាឡាំង វ៉ែនណឺ៖**

សុំទោសលោកប្រធាន ខ្ញុំឡើងមកនេះដើម្បីជួយសម្រួលដល់ឯកសារដែលបានលើកឡើងអម្បាញ់មិញនេះ ទំព័រនោះគឺមានលេខចុងនោះ 87 និង 88 ។

**លោក គាន់ សេណារ៉ុង៖**

ខ្ញុំគ្រាន់តែចង់សុំជម្រាបជូនអង្គ---

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធានមានការបកប្រែ ជាភាសាបារាំងនៃឯកសាររបស់ *ឌីស៊ីខេម* នេះហើយមានលេខ 00337992 រហូតដល់ 00338015 ក៏ប៉ុន្តែលោកប្រធាន លោក លោកស្រីចៅក្រម គឺថាយើងបានធ្វើការកត់សម្គាល់ថា មិនមានការចង្អុលបង្ហាញណាមួយសោះ អំពីលក្ខណៈសម្បត្តិរបស់បុគ្គលដែលបានធ្វើបទសម្ភាសន៍ដ៏វែងអន្លាយនេះ ។ គឺយើងមិនដឹងថាតើនៅក្នុងកាលៈទេសៈណាដែលឯកសារនេះត្រូវបានគេរៀបចំឡើង ហើយអ្វីដែលយើងបានដឹងនោះគឺថា យើងមិនបានដឹងអ្វីទាំងអស់អំពីឯកសារផ្លូវច្បាប់នេះ ហើយតាមពិតយើងមានឯកសារពីរដែលបានធ្វើឡើងក្នុងទាក់ទងទៅនឹងបទសម្ភាសន៍របស់សាក្សីនេះ ។ គាត់ត្រូវបានសម្ភាសន៍លើកទីមួយ ដោយខាងការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយឯកសារនោះគឺមានលេខ D2/6 ឬក៏D2/6.4 ហើយក្រោយមកគាត់ត្រូវបានសម្ភាសន៍ម្តងទៀតដោយ អ្នកស៊ើបអង្កេតនៅការិយាល័យសហចៅក្រម ស៊ើបអង្កេតគឺ D22/13 ។

ខ្ញុំនៅចាំថា យើងបច្ចុប្បន្ននេះនៅចំពោះមុខតុលាការនៃច្បាប់ ហើយខ្ញុំយល់ថាមិនជាការសមរម្យទេ បើសិនជាឯកសារណាដែលមិនមែនជាឯកសារស្របច្បាប់ ត្រូវបានយកមកប្រើប្រាស់នៅក្នុងអង្គសវនាការនោះ ជាពិសេស ឯកសារនេះគឺជាឯកសារដែលបានធ្វើឡើងដោយអង្គការមួយដែលជាអង្គការក្រៅរដ្ឋាភិបាល ហើយដែលបានធ្វើបទសម្ភាសន៍នេះឡើង ។ ដូច្នេះ លោកប្រធាន ខ្ញុំចង់ឲ្យធ្វើការយោងតែទៅលើឯកសារណាដែលបានតាក់តែងឡើងតាមផ្លូវច្បាប់តែប៉ុណ្ណោះ ។

[០៩:២៧:៤២]

**លោក អានីស អះមេដ៖**

(មិនឮសំឡេង)

**ប្រធានអង្គជំនុំ៖**

លោកមិនអាចងើបឡើងនិយាយដូច្នេះបានទេ គប្បីមានការអនុញ្ញាតជាមុនពីយើងជាប្រធានអង្គជំនុំជម្រះ ។ លោកសុំនិយាយទេ ឥឡូវនេះ ឬក៏ចង់ងើបឡើងនិយាយតាមតែទំនើងចិត្ត ដូច្នេះ?

**លោក អានីស អះមេដ៖**

លោកប្រធាន ខ្ញុំគិតថានេះជាពេលវេលារបស់ខាងការិយាល័យព្រះរាជអាជ្ញា ដើម្បីសួរសំណួរដល់សាក្សីនេះ ។

**ប្រធានអង្គជំនុំ៖**

លោកសុំការអនុញ្ញាតពីយើង ឬក៏អត់ទេ?

**លោក អានីស អះមេដ៖**

ត្រឹមត្រូវណាស់លោកប្រធានគឺថា ខ្ញុំអាចនិយាយបាននៅពេលដែលមានការអនុញ្ញាតពីលោកប្រធានតែប៉ុណ្ណោះ ។ ហើយខ្ញុំយល់ថាពេលវេលានេះ គឺត្រូវបានប្រគល់ទៅឲ្យខាងការិយាល័យសហព្រះរាជអាជ្ញាដើម្បីសួរដល់សាក្សីរូបនេះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ, ប៉ុន្តែលើកក្រោយត្រូវតែមានការអនុញ្ញាតជាមុន ពីព្រោះបញ្ហានេះកំពុងតែដេញដោលគ្នាពីបញ្ហាប្រភេទឯកសារទាំងឡាយដែលកំពុងតែមានបញ្ហាថាត្រូវដាក់ដេញដោល ឬក៏អត់នៅពេលនេះ?

**លោក អានីស អះមេដ៖**

លោកប្រធានគឺថា ខ្ញុំនិយាយនៅពេលដែលមានសំណួរពីលោកតែប៉ុណ្ណោះ ។ ខ្ញុំមានសំណួរមួយ

ចំនួនសម្រាប់ដល់សាក្សីរូបនេះ ។

[០៩:៣០:០០]

**ប្រធានអង្គជំនុំ៖**

បញ្ហាវាជួបនឹងបញ្ហាមួយដែលភាគីសហព្រះរាជអាជ្ញាជាតិបានលើកឡើងនូវឯកសារនេះ ហើយមានការជំទាស់ពីមេធាវីការពារក្តី ។ ឥឡូវហ្នឹងលោកឡើងនិយាយពេលនេះ តើមានការប៉ុនប៉ងយ៉ាងម៉េចច្បាស់លាស់ក្នុងការសុំសួរសំណួរពាក់ព័ន្ធទៅនឹងអង្គហេតុចំពោះសាក្សី ឬក៏មានការពាក់ព័ន្ធនឹងការជំទាស់នៅលើឯកសារដែលសហព្រះរាជអាជ្ញាជាតិបានលើកឡើង សុំដាក់ធ្វើការដេញដោលដែលមានការជំទាស់ពីមេធាវីការពារក្តី ។ លោកគិតដូច្នេះ ត្រូវថាអំឡុងពេលនៃការជំទាស់ និងពិភាក្សាដោះស្រាយនេះពេលវេលាអង្គជំនុំជម្រះនឹងដកចេញ មិនបញ្ចូលទៅក្នុងពេលវេលាដែលបានបែងចែកឱ្យលោកនោះទេ ឱ្យតំណាងសហព្រះរាជអាជ្ញានោះទេ ។

**លោក អានីស អះមេដ៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ ហើយខ្ញុំក៏មានប៉ុនប៉ងធ្វើតាមការណែនាំហើយនិងឆ្លើយតបទៅនឹងមេធាវីការពារ ហើយបន្ទាប់មកខ្ញុំនឹងសួរសំណួរទៅសាក្សីនេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ ។

**លោក អានីស អះមេដ៖**

សូមអរគុណលោកប្រធាន។ ហើយសូមអភ័យទោសប្រសិនបើខ្ញុំមិនមានការយល់ច្បាស់ អំពីការបញ្ជាក់ខាងដើម។ ដើម្បីឆ្លើយតបទៅនឹងមេធាវីការពារនោះ គឺថាឯកសារនេះ គឺជាឯកសារទាក់ទងទៅនឹងរឿងក្តី គឺនៅក្នុងសំណុំរឿងប្រព័ន្ធនៅក្នុងតុលាការរបស់យើងហ្នឹង គឺកាលណាឯកសារនៅក្នុងសំណុំរឿងហើយ កាលណាលើកមកពិភាក្សានៅសវនាការហើយ គឺចាត់ទុកថាជាអាទិ៍ដើម្បីជាភស្តុតាងដើម្បីឱ្យចៅក្រមដើម្បីប្រើជាភស្តុតាងថ្លឹងថ្លែង នៅពេលធ្វើសេចក្តីសម្រេចដែលយើងបានដេញដោល ។ ប្រសិនបើយើង ទទួលស្គាល់យកឯកសារហើយ បើមិនផលិតឡើងដោយសហចៅក្រមស៊ើបអង្កេតក្នុងអតីតកាលទេ អ៊ីចឹងខ្ញុំសូមស្នើថា បើសិនជាត្រូវថ្លឹងថ្លែងលើឯកសារដែលមិនផលិតដោយសហចៅក្រមស៊ើបអង្កេត នោះគឺថាត្រូវពឹងផ្អែកទៅលើសក្ខីកម្មរបស់សាក្សីបញ្ជាក់ទៅលើឯកសារនោះដែលបង្ហាញដោយសហព្រះរាជអាជ្ញាទៅសាក្សី ។ អ៊ីចឹងឯកសារដើម្បីដាក់ជូនទៅចំពោះមុខអង្គជំនុំជម្រះសាក្សីមិន

បានបញ្ជាក់ទេ គឺមិនអាចតម្កល់ថាជាភស្តុតាងទេ ។ អ៊ីចឹងហើយអង្គជំនុំជម្រះអាចនឹងសម្រេចទៅលើករណីហ្នឹង តាមមតិយោបល់របស់ចៅក្រម ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន លោកសហព្រះរាជអាជ្ញា ។ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់អំពីបញ្ជីឯកសារដែលលោកចង់ដាក់ដេញដោលចំពោះមុខអង្គជំនុំជម្រះដោយបញ្ជាក់ពីលេខយោង លេខពាក់ព័ន្ធផងដោយសារយើងមានការភាន់ច្រឡំទៅលើឯកសារទាំងនោះ ។

[០៩:៣៥:០០]

**លោក អានីស អះមេដ៖**

សូមអភ័យទោសចំពោះដែលយើងធ្វើឲ្យមានការច្រឡំ ។ ប៉ុន្តែ ដោយមានការអនុញ្ញាតខ្ញុំសូមអនុញ្ញាត។ ថាតើអនុញ្ញាតឲ្យយើងខ្ញុំសួរសំណួរទាក់ទងទៅនឹងឯកសារនឹងទេ? ហើយមេធាវីការពារអាចសួរបានទាក់ទងទៅនឹង-- បើដូច្នេះគឺថាខ្ញុំអាចនឹងបន្ត ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អ៊ីចឹង ហើយខ្ញុំសូមឲ្យលោកបំភ្លឺគឺឯកសារដែលលោកចង់ប្រើដើម្បីសួរសំណួរទាក់ទងហ្នឹង តើជាឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាឬ?

**លោក អានីស អះមេដ៖**

ឯកសារដែលខ្ញុំនឹងដាក់ នឹងសួរនេះ គឺមិនមែនឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ ឯកសារនោះស្ថិតនៅក្នុងសំណុំរឿង ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

នោះហើយជាឯកសារដែលលោកផ្តោតអារម្មណ៍លើ គឺជាឯកសារតែមួយដែលលោកចង់ដាក់ដេញដោលចំពោះអង្គជំនុំជម្រះ?

**លោក អានីស អះមេដ៖**

សូមអគុណលោកស្រីចៅក្រម ។ ហ្នឹងហើយជាឯកសារតែមួយគត់ដែលខ្ញុំមានបំណងចង់ដាក់ដេញដោលនិងសួរសាក្សី ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អ៊ីចឹង ហើយបច្ចុប្បន្នលោកមិនស្នើឲ្យអង្គជំនុំជម្រះ ដើម្បីសុំឯកសារ *ឌីស៊ីខេម* ដើម្បីដាក់ដេញដោលចំពោះអង្គជំនុំជម្រះ ។

**លោក អានីស អះមេដ៖**

ចំពោះឯកសារ *ឌីស៊ីខេម* គឺបើសិនជាអង្គជំនុំជម្រះអនុញ្ញាតឲ្យប្រើ គឺមេធាវីអាចនឹងប្រើសួរសំណួរតបទៅលើឯកសារ ។ ប្រសិនបើមិនអនុញ្ញាតប្រើឯកសារ *ឌីស៊ីខេម* ទេ ខ្ញុំនឹងប្រើឯកសារដែលមាននៅក្នុងសំណុំរឿង ។

[០៩:៣៧:៣០]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សំណួរមួយទៀតនេះ គឺថាមានលេខ ERN ទាំងពីរ ហើយនិងលេខ D នៅលើឯកសារនោះ ។ តើលោកសហព្រះរាជអាជ្ញា-- តើលោកចៅក្រម ឡាវ៉ែន៍ យល់ថាលេខ D នោះជាលេខរបស់ឯកសារកម្ពុជាទេ-- មជ្ឈមណ្ឌលឯកសារកម្ពុជា។ អ៊ីចឹងសូមលោកប្រើលេខ ERN ។ ហើយខ្ញុំនឹងបញ្ជាក់នឹងសហព្រះរាជអាជ្ញា ។ ហើយអង្គជំនុំជម្រះទទួលថា ឯកសារហ្នឹង គឺអាចនឹងដេញដោលជាមូលដ្ឋាននៃការសួរសាក្សីនេះ ដែលយោងទៅរកឯកសារនោះ ពាក់ព័ន្ធឯកសារ ។

**លោក អានីស អះមេដ៖**

សូមអរគុណ ។ អ៊ីចឹងសូមឲ្យមេធាវី ឲ្យសហសេវិករបស់ខ្ញុំនឹងបន្តសួរសំណួរ បន្ទាប់មកទើបខ្ញុំប្រើពេលដែលនៅសល់ ។

**សួរដោយ លោក តាន់ សេណារ៉ុង៖**

សូមអរគុណលោកប្រធានអង្គជំនុំជម្រះ ។

**ស៖** ស្វាគមន៍លោក ឡាច មាន ជាថ្មីម្តងទៀត ។ សំណួររបស់ខ្ញុំចង់សួរដែលបញ្ជាក់ទៅលើឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលលោកបានសម្ភាសន៍ជាមួយលោក ។ តើលោកមានបានចាំទេ ចងចាំទេថា-- ហើយក្នុងនោះដែរ ខ្ញុំសុំការអនុញ្ញាតដើម្បីដាក់ឯកសារហ្នឹង ជូនអង្គជំនុំជម្រះដើម្បីពិចារណាទៅលើD92/1 ហ្នឹង ។ ជាឯកសារដែលមាននៅក្នុងសំណុំរឿងស្រាប់ ។

លោក ឡាច មាន តើលោកចងចាំទេថា ឈ្មោះដែលបានសួរចម្លើយអ្នកទោសនៅក្នុងសម័យកាលនោះ ដូចឯកសារដែលខ្ញុំបានជូនលោកនោះ លោកអាចចងចាំទេ? ERN នេះមានលេខ 00057

053 ។ ប៉ុន្តែ ទំព័រដែលខ្ញុំបានសួរលោក ឡាច មាន នេះ គឺមានលេខERN 00057066 នៅក្នុងភាសាខ្មែរ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអភ័យទោស ដើម្បីគោលបំណងឲ្យបានយើងយល់ច្បាស់ ហើយដើម្បីឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យការប្រើឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខ្ញុំមិនដឹងថា ខ្ញុំយល់ត្រូវ ឬអត់ទេ? ដើម្បីគោលបំណងឲ្យយើងបានយល់ច្បាស់នោះ គឺតើអង្គជំនុំជម្រះអនុញ្ញាតឲ្យប្រើឯកសាររបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជាមួយនេះឬទេ?

[០៩:៤០:២៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

មែនហើយលោក រូ អង្គជំនុំជម្រះអនុញ្ញាតឲ្យប្រើឯកសារនេះ គឺឯកសារនៅក្នុងសំណុំរឿង ។ ហើយឥឡូវនេះយើងបានសម្រេចថា តើសម្រេចមិនឲ្យប្រើមជ្ឈមណ្ឌលឯកសារ កាលណាសាក្សីមិនវត្តមាន ។ ប៉ុន្តែ ស្ថានភាពនោះវាខុសគ្នាថ្ងៃនេះ យើងមានឯកសារនៅក្នុងសំណុំរឿង ហើយយើងមានលទ្ធភពនឹងសួរសំណួរទាក់ទងទៅនឹងខ្លឹមសារនៃឯកសារនេះ ហើយសាក្សីក៏វត្តមាន ។ ហើយអង្គជំនុំជម្រះបានសម្រេចថាឲ្យនឹងដាក់ដេញដោលចំពោះមុខតុលាការបាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា ។ ហើយតំណាងសហព្រះរាជអាជ្ញាមានពេល-- នៅពេលម្ភៃប្រាំនាទីទៀត ក្នុងការសួរដេញដោលសាក្សីរូបនេះ ។

**លោក តាន់ សេណារ៉ុង៖**

អរគុណបាទ អង្គជំនុំជម្រះ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** លោក ឡាច មាន តើលោកនឹកឃើញទេ ឯកសារហ្នឹង ដែលខ្ញុំបានជូនលោក?

**ឆ៖** ចំពោះឯកសារដែលបានជូនខ្ញុំនេះ គឺខ្ញុំមិនបាននឹកឃើញទេ តែចំពោះហត្ថលេខាចុះនេះ គឺបានមិនមែនជាហត្ថលេខារបស់ខ្ញុំពិតប្រាកដទេ ។

**លោក តាន់ សេណារ៉ុង៖**

លោក ឡាច មាន ខ្ញុំមិនបានសួរទៅឯកសារដែលមានចុះហត្ថលេខារបស់លោកទេ ។

អ៊ីចឹងសុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីបង្ហាញឯកសារដែលមានលេខ ERN នៅក្នុង 000 57066 ជាភាសាខ្មែរនៅក្នុងអេក្រង់ទូរទស្សន៍ដើម្បីបញ្ជាក់ជូនលោក ឡាច មាន ព្រោះខ្ញុំមានតែសំណួរមួយហ្នឹងទេ ដែលនៅសល់ហ្នឹងនោះ ។

[០៩:៤២:២៧]

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍បង្ហាញនូវឯកសារដែលមានលេខERN00057066 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** លោក ឡាច មាន លោកបានឃើញអេក្រង់ទូរទស្សន៍ទេ ហើយនេះជាកិច្ចសម្ភាសន៍ និងជាសម្ដីរបស់លោក ដែលបានលោកឆ្លើយជូនអ្នកទាំងនោះ ។ តើលោកនឹកឃើញទេថា អ្នកទោសណាមួយដែលលោកបាន-- លោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះបានទេថាអ្នកទោសណាម្នាក់ដែលបានលោកបានសួរចម្លើយនៅពេលនោះ?

**ឆ៖** ចំពោះឈ្មោះដែលមាននៅក្នុងចម្លើយខ្ញុំបានសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារ គឺខ្ញុំអត់បាន-- មិនមានការឆ្លើយ មិនមានទេនៅក្នុងឯកសារនេះ ។

ខ្ញុំសូមជម្រាបលោកបន្ដិចថា នៅក្នុងនោះគេបានសួរថាលោក-- ខ្ញុំចាប់ផ្ដើមអានពីដើមចាំឈ្មោះម្នាក់នៅខាងបាត់ដំបង គាត់ពីដើមធ្វើសាស្ត្រាចារ្យខាងគណៈតំបន់ ។ សំណួរគេសួរថា *"ឈ្មោះអីបង"* ហើយលោកបានឆ្លើយថា 'ឈ្មោះ ប៉ែន សាម៉ន" បងសួរផ្ទាល់តែម្ដងថា *"បាទ"* ។ ហើយសំណួរគេសួរថា "កាលហ្នឹង ប៉ែន សាម៉ន ចោទថាយ៉ាងម៉េចបានជាយកមកសួរចម្លើយ?" លោកបានឆ្លើយថា "មិនទេគេចោទថាក្បត់ជាតិនោះហើយ ពីដើមគាត់ធ្វើសាស្ត្រាចារ្យនៅភ្នំពេញ ដល់នេះគាត់ជាផ្ទៃក្នុងរបស់ខ្មែរក្រហម ។ គាត់នៅភ្នំពេញទាល់បែកឆ្នាំ៧៥ គាត់បានទៅធ្វើគណៈតំបន់សាម-- ប៉ុន្មានខាងភូមិភាគនេះ ខ្ញុំភ្លេចអស់ហើយចាំវាមិនច្បាស់" ។

**ស៖** តើនេះពិតជាសម្ដីរបស់លោក ដែលលោកបានឆ្លើយជាមួយនឹងការសម្ភាសន៍របស់គេមែនទេ?

**ឆ៖** បាទ,ខ្ញុំសូមឆ្លើយ ។ ជាចម្លើយរបស់ខ្ញុំបានសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារ គឺខ្ញុំបានឆ្លើយតាមនេះមែន គឺឈ្មោះ ប៉ែន សាម៉ន នេះជា-- គឺ--និយាយកាលនោះ គឺខ្ញុំវាភ្លេចបាត់ទៅហើយ ឥឡូវខ្ញុំមិនដឹងថា ប៉ែន សាម៉ន យ៉ាងម៉េច? អីយ៉ាងម៉េចទេ? ។ តែកាលនោះ បែបខ្ញុំនឹកឃើញក៏មិនដឹង តែមកដល់ពេលគឺខ្ញុំមិនបាននឹកវាទេ ភ្លេចអស់បាត់ហើយ វង្វេងវង្វាន់អស់ហើយ ។

**ស៖** ប៉ុន្តែលោកនៅតែទទួលស្គាល់ថាហ្នឹងគឺជាៗចម្លើយលោកពិតជាបានឆ្លើយអ៊ីចឹងលោក?

**ឆ៖** បាទ, ចម្លើយនេះ គឺខ្ញុំទទួលស្គាល់ថាខ្ញុំបានឆ្លើយមែន ។

**ស៖** អរគុណលោក សុំសំណួរបន្ទាប់មួយទៀត ។ កាលពីម្សិលមិញ លោកបានជម្រាបលោកចៅក្រម យ៉ា សុខន ថា "ឌុច បានទូរស័ព្ទផ្ទាល់សួរចម្លើយ ឬណែនាំឲ្យសួរបន្ថែមលើចម្លើយអ្នកដែលបានសួររួច" ។ ថាក្នុងនោះ តើលោកចាំបានទេថា តើគាត់បានណែនាំមានចំណុចជាក់លាក់អ្វីខ្លះដល់លោកឲ្យសួរបន្ថែមនោះ?

[០៩:៤៦:០៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្រ្វង់ស្វ័រ រូ ។

**លោក ហ្រ្វង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមអភ័យទោសដោយខាងសហព្រះរាជអាជ្ញាដែលខ្ញុំរំខានកាត់នេះ ។ ពីមុនលោកនិយាយអំពីឯកសារមជ្ឈមណ្ឌលកម្ពុជា ប៉ុន្តែខ្ញុំបានឮសាក្សីថា គាត់មិនទទួលស្គាល់ឯកសារហ្នឹងទេ ។ អ៊ីចឹងហើយលោក-- គាត់ទុកបញ្ហានេះមួយឡែក ។

អ៊ីចឹងខ្ញុំសុំអនុញ្ញាតថា តើសាក្សីហ្នឹងទទួលស្គាល់ហត្ថលេខាលើឯកសារហ្នឹងដែរឬអត់ មុននឹងយើងចូលសំណួរមួយទៀត? សូមលោកសហព្រះរាជអាជ្ញាទុកឯកសារនេះនៅលើអេក្រង់ម្ដងទៀតដើម្បីឲ្យសាក្សីថាតើគាត់ទទួលស្គាល់ថាជាហត្ថលេខារបស់គាត់ ឬក៏ជាការបកប្រែ? ខ្ញុំចង់ឲ្យមានការបញ្ជាក់ឲ្យបានច្បាស់នៅលើចំណុចនេះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំក៏ចង់ដឹងឲ្យច្បាស់ផងដែរថាតើសាក្សីអាចបញ្ជាក់លើឯកសារហ្នឹងបានច្បាស់ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញៗទៅមេធាវីប្រឹក្សាជាមួយនឹងសាក្សី សូមអញ្ជើញ ។

**លោក គង់ សំអុន៖**

សូមអនុញ្ញាតជួបជាមួយសាក្សីមួយភ្លែត ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ។

[០៩:៥0:00]

**ប្រធានអង្គជំនុំ៖**

លោកតំណាងព្រះរាជអាជ្ញាជាតិ សូមអញ្ជើញបន្ត ហើយសំណួរនេះគឺការពាក់ព័ន្ធជាមួយនឹងការច្បិចយកមួយទំព័រនៃចម្លើយរបស់បទសម្ភាសន៍របស់សាក្សីរូបនេះនៅចំពោះមុខ *ស៊ីឌីខេម* ហើយបញ្ហានៃការកត់សម្គាល់របស់មេធាវីការពារក្តី គឺចង់បញ្ជាក់ចុងក្រោយថា អំពីភាពត្រឹមត្រូវនៃឯកសារនេះគឺស្នាមហត្ថលេខា ឬក៏ស្នាមមេដៃចុងក្រោយលើកំណត់ហេតុជាក់លាក់ ដើម្បីកំណត់ថា តើគាត់ទទួលស្គាល់ថាជាឯកសារដែលគាត់បានចូលរួមនៅក្នុងការធ្វើសម្ភាសន៍ជាមួយនឹង *ស៊ីឌីខេម* ដែរឬទេ? ការបង្ហាញនេះ គឺលុះត្រាតែបង្ហាញនូវឯកសារទាំងមូល ដើម្បីឃើញនូវរឹមទំព័រចុងក្រោយនៃស្នាមមេដៃឬហត្ថលេខារបស់អ្នកសម្ភាសន៍ ហើយនិងអ្នកដែលគេត្រូវសម្ភាសន៍ ។

**លោក តាន់ សេណារ៉ុង៖**

អរគុណអង្គជំនុំជម្រះ ។ គ្រាន់តែខ្ញុំសូមទាញអារម្មណ៍ជម្រាបជូនអង្គជំនុំជម្រះថា ភាគច្រើនឯកសារដែលមជ្ឈមណ្ឌលកម្ពុជាបានសម្ភាសន៍ជាមួយនឹងអតីតអ្នកសួរចម្លើយក្តី អ្នកយាមក្តី ហើយនិងទាហានរបស់របបខ្មែរក្រហមក្តី គឺភាគច្រើនដែលយើងបានទទួល គឺឯកសារដែលគេជាវាយមកជាប្រតិចារឹក ពុំមានហត្ថលេខារបស់ជននោះទេ ។ ក៏ប៉ុន្តែ ឯកសារទាំងអស់នោះ វាមាននៅក្នុងកាសែតដែលគេបានអាត់ជាសំឡេងរួចហើយ ។ គេថត គេអាត់ជាសំឡេងរួចហើយ បានគេបានវាយជាប្រតិចារឹកហ្នឹងឡើងវិញ ។ ហើយឯកសារទាំងអស់នេះបានដាក់ចូលក្នុងសំណុំរឿងតាំងពីដំបូងរួចរាល់មកហើយដែរ គឺមាននៅក្នុងសំណុំរឿងរួចរាល់មកហើយ ហើយក្នុងឯកសារដដែលខ្ញុំបានលើកនេះ គឺមាន ERN

ជាភាសាអង់គ្លេសលេខ 00335276 រហូតដល់ 00335296 និងភាសាបារាំងដូចលោក ហ្វ្រង់ស្វ័រ រូ បានបញ្ជាក់ជូនអង្គជំនុំជម្រះរួចហើយ ។ ហើយភាសាខ្មែរដូចខ្ញុំបានលើកជូនដែលមានលេខ 00057053 ប៉ុន្តែ ទំព័រដែលខ្ញុំលើកយកមកពិភាក្សានេះ គឺយកលេខ 00577066 ឲ្យចយកតែមួយទំព័រដែលៗ លោក ឡាច មាន គាត់ធ្លាប់បានសួរចម្លើយទៅលើអតីតប្រធានតំបន់ម្នាក់ប៉ុណ្ណោះ ។

**ប្រធានអង្គជំនុំ៖**

បើគ្មានបញ្ជាក់អំពីអត្តសញ្ញាណជាក់លាក់នៅលើឯកសារនេះទេ សូមអញ្ជើញសួរសំណួរបន្តទៀត ។ សំណួរផ្សេងទៀតដែលលោកអាចនៅមាន ។

[០៩:៥៣:៤៥]

**លោក តាន់ សេណារ៉ុង៖**

អរគុណ ។ លោក ឡាច មាន ខ្ញុំអស់សំណួរចំពោះលោកហើយ។ ខ្ញុំជូននាទីបន្ទាប់ទៅសហការីរបស់ខ្ញុំ ។

**សួរដោយលោក អានីស អះមេដ៖**

សូមអរគុណលោកប្រធាន លោកចៅក្រម ។ លោក ឡាច មាន ខ្ញុំមានសំណួរពីរបី ។

**ស៖** តើលោកស្គាល់មនុស្សម្នាក់ឈ្មោះ សុន សេន ដែរឬទេ?

**ឆ៖** បាទ, ចំពោះឈ្មោះ សុន សេន គឺខ្ញុំបានធ្លាប់ស្គាល់ ឃើញមុខគាត់មកបង្រៀនកន្លែងសាលានយោបាយនៅក្នុង-- ក្បែររបងមន្ទីរស-២១ ។ ខ្ញុំធ្លាប់ស្គាល់ ឃើញគាត់មកបង្រៀននយោបាយ ។

**ស៖** តើលោកបានឃើញគាត់ជាញឹកញាប់ប៉ុនណាដែរ ដែលគាត់មកក្នុងបរិវេណស-២១ នោះ?

**ឆ៖** បាទ, ចំពោះគាត់តា សុន សេន គឺគាត់មកប្រហែលជាមិនញឹកញាប់ប៉ុន្មានទេក្នុងពីរ ឬបីខែគាត់មកបង្រៀនម្តង ។

**ស៖** តើវគ្គរៀននយោបាយនោះគេរៀនពីខ្លឹមសារអ្វីដែលលោក សុន សេន បានបង្រៀន? តើគេនិយាយពីអ្វីទៅដល់អ្នកស្តាប់នៅពេលនោះ?

**ឆ៖** បាទ, ជានយោបាយរបស់គេ កាលនោះ គឺខ្ញុំអត់បានចាំអស់ទេ ប៉ុន្តែគឺមានតែនយោបាយគឺបោសសម្អាតខ្មាំង ខ្ញុំនៅចាំតែប៉ុណ្ណឹង ។

**ស៖** តើលោក-- គាត់បានរៀបចំពន្យល់ថា តើខ្មាំងនោះជានរណាដែរឬទេ?

**ឆ៖** បាទ ចំពោះខ្មាំងដែលគាត់ពន្យល់ គឺខ្មាំង គឺជាអ្នកឲ្យតែក្បត់របស់បក្ស គេគឺសុទ្ធតែខ្មាំង ។

**ស៖** លោកបានប្រាប់សហចៅក្រមស៊ើបអង្កេតថា សុន សេន បានមកស-២១ រៀងរាល់ខែ ឬក៏ពីរខែម្តង? តើហ្នឹងជាការកំណត់ពេលវេលាត្រឹមត្រូវដែលតាមដែលលោកចាំដែរឬទេ?

**ឆ៖** ចំពោះរឿង សុន សេន មកមួយខែ ឬពីរខែ គឺខ្ញុំមិនបានកំណត់ ហើយក៏មិនបានចាំច្បាស់ថាគាត់មានកំណត់ ឬអត់មានកំណត់ទេ ។ ថ្ងៃណាគេឲ្យទៅប្រជុំ គឺទៅប្រជុំ ជួនកាលមួយឆ្នាំមកម្តងក៏មាន ជួនកាលមិនដឹងជាប៉ុន្មានខែមកម្តងទេ ខ្ញុំមិនបានចាំច្បាស់ ។

[០៩:៥៦:៥៦]

**ស៖** តើជនជាប់ចោទផ្តល់ការបង្រៀនពីវិធីសួរចម្លើយដល់លោកញឹកញាប់ប៉ុនណាដែរ ឬក៏ណែនាំញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ចំពោះជនជាប់ចោទឈ្មោះ ឌុច គាត់មិនបានមកណែនាំផ្ទាល់ ឬក៏មកកន្លែងសួរចម្លើយផ្ទាល់ទេ គឺបើក្នុងសាលានយោបាយគាត់ណែនាំពន្យល់ពីនយោបាយ ពីរបៀបរបបសួរគឺមាន ។

**ស៖** តើវគ្គរៀនសូត្រនយោបាយហ្នឹងញឹកញាប់ប៉ុនណាដែរ ទាក់ទងនឹងកន្លែងមួយដែលជនជាប់ចោទបានបង្រៀនពីរបៀបសួរចម្លើយដល់លោកនោះ?

**ឆ៖** ចំពោះឈ្មោះជនជាប់ចោទ ឈ្មោះ ឌុច នេះគឺក៏មិនទៀងដែរ ជួនកាលមួយខែ ឬកន្លះខែក៏មានគាត់ចូលក្នុងសាលានយោបាយ ។

**ស៖** នៅក្នុងវគ្គរៀនសូត្រនយោបាយនោះថា តើអ្នកសួរចម្លើយទាំងអស់ត្រូវតែទៅប្រជុំរៀនសូត្រនោះឬ?

**ឆ៖** បាទ,ចំពោះអ្នកសួរចម្លើយគឺទៅទាំងអស់ តែដល់ថ្ងៃ-- ជួនកាលថ្ងៃរួមទៅមានតាំងកម្មា-ភិបាលព្រៃសអីមកចូលរួម គឺមាន ។ តែគ្រាន់តែឃើញមុខទេ មិនដែលស្គាល់ឈ្មោះ មិនដែលអីទេខាងមកពីមន្ទីរខាងព្រៃស នេះមករួមគ្នាទាំងកងការពារ ទាំងសួរចម្លើយ គេចូលរួមក្នុងសាលាទាំងអស់គ្នា ។

**ស៖** តើត្រឹមត្រូវទេដែលយើងថាជនជាប់ចោទនេះ គឺនៅក្នុងវគ្គរៀនសូត្រនយោបាយនោះ បានប្រាប់លោកដោយច្បាស់លាស់ ដែលបញ្ជាក់ថាចំណុចខ្សោយរបស់អ្នកទោសនោះ គឺគាត់បានបញ្ជាក់ពីចំណុចខ្សោយរបស់អ្នកទោសប្រាប់ដែរឬទេ?

**ឆ៖** បាទ, ចំពោះរឿងចំណុចខ្សោយអ្នកទោស គឺគាត់មិនដែលបានមកប្រាប់ខ្ញុំផ្ទាល់ទេ ច្រើនតែមេពួក និងមេក្រុមគាត់ប្រាប់ពីចំណុចខ្សោយរបស់អ្នកទោស ។

**ស៖** នៅក្នុងវគ្គរៀនសូត្រនយោបាយនោះ ជនជាប់ចោទក៏បានប្រាប់លោករបៀបគ្រប់គ្រងដែលត្រូវគ្រប់គ្រងអ្នកទោសដែលមិនឆ្លើយ ឬក៏មិនព្រមធ្វើតាមអ្នកសួរចម្លើយនោះ?

**ឆ៖** បាទ, អត់យល់ ។ សំណួរសុំសួរម្តងទៀត ស្តាប់អត់ទាន់ ។

**ស៖** ជនជាប់ចោទនៅក្នុងវគ្គនយោបាយទាំងអស់នោះ គឺថាដែលលោកវត្តមានគឺប្រាប់លោកអំពីរបៀបគ្រប់គ្រងអ្នកទោសដែលមិនឆ្លើយតប ឬក៏មិនព្រមធ្វើតាមក្នុងពេលសួរចម្លើយ គាត់ប្រាប់ថាឲ្យធ្វើដូចម្តេច?

**ឆ៖** បាទ, ចំពោះចំណុចនេះ គឺគាត់មិនបានណែនាំថាម៉េចទេ គឺគាត់នយោបាយរបស់គាត់ចំពោះអ្នកសួរចម្លើយ គឺធ្វើយ៉ាងម៉េចយើងខិតខំសួរចម្លើយឲ្យបានចម្លើយឲ្យបក្ស ។ អាហ្នឹងគឺមានតែប៉ុណ្ណឹងជាយោបល់របស់គាត់ណែនាំ ។

[១០:០០:៤២]

**ស៖** តើលោកនៅចាំទេ នៅក្នុងឱកាសមួយលោកបានធ្វើការហៅទូរស័ព្ទទៅជនជាប់ដែលលោកប្រាប់គាត់ថា អ្នកទោសម្នាក់បានឆ្លើយដាក់ វន វ៉េត តើលោកនៅចាំទេ?

**ឆ៖** បាទ, ចំពោះរឿងនេះគឺនៅចាំ មានចម្លើយអ្នកទោសម្នាក់ឆ្លើយដាក់ឈ្មោះ វន វ៉េត ខ្ញុំបានទូរស័ព្ទទៅសួរគាត់ តែពេលនោះគាត់បានសួរឆ្លើយមកជាដំបូង គឺគាត់ថាមិនឲ្យឆ្លើយដាក់ទេឲ្យរំលងចោល ។ នេះជា ខ្ញុំបានទៅចាប់ ។

**ស៖** តាមពិត វន វ៉េត គឺជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ថាតើជនជាប់ចោទប្រាប់លោកដូចម្តេចទាក់ទងទៅនឹងអ្នកទោសមួយនោះ?

**ឆ៖** បាទ, ពេលនោះគឺគាត់មិនបានប្រាប់ថាម៉េចទេថា មិត្តឯងរំលងចោលទៅ ។ មិនបាច់អ្នកទោសស្រីចូល គឺគាត់ប្រាប់តែប៉ុណ្ណឹង ។

**ស៖** ហើយបន្ទាប់មក ជនជាប់ចោទហ្នឹងបាននិយាយប្រាប់លោកថា លោកអាចបន្តសួរចម្លើយអ្នកទោសហ្នឹងបន្តទៀតមែនទេ?

**ឆ៖** បាទ, ថ្ងៃក្រោយឡើង គឺគាត់បានតេមកប្រាប់ខ្ញុំថាឲ្យអ្នកទោសនោះសរសេរចម្លើយឈ្មោះ វន វ៉េត បន្តទៀត ។

**ស៖** តើលោកមានបានឃើញជនបរទេស ពួកបស្ចិមប្រទេសទេដែលនៅស-២១ដែលមានស្បែកស ដែលមានខ្ពស់ជាងប្រជាជនអាស៊ីនោះ?

**ឆ៖** ចំពោះជនបរទេសដែលមានស្បែកស ហើយខ្ពស់នោះ គឺខ្ញុំបានៗឃើញពីរនាក់ក៏មិនដឹង បីនាក់ក៏មិនដឹង គឺឃើញអង្គរក្សរបស់ តាចាន់ ឬក៏អង្គរក្ស តាហ៊ី គាត់នាំមកសួរចម្លើយ ឃើញបណ្តើរតាមផ្លូវ ។

**ស៖** តើបន្ទាប់មកពីត្រូវបានសួរចម្លើយហើយហ្នឹង មានរឿងអ្វីកើតឡើងចំពោះជនបរទេសទាំងនោះ?

**ឆ៖** ចំពោះបញ្ហារឿងអីកើតឡើងគឺខ្ញុំមិនបានដឹងទេ ការងារជាការងារសម្ងាត់របស់បក្សទេ ។

[១០:០៣:២៨]

**ស៖** លោកបានប្រាប់ដល់សវនាការថា ជាញឹកញាប់ណាស់លោកបានឮអ្នកទោសហ្នឹងស្រែក ឬក៏ស្រែកយំ ហើយអ្នកខ្លះទៀតបានព្យាយាមធ្វើអត្តឃាតខ្លួនឯង ។ ហើយនៅក្នុងឱកាសមួយនោះ មានទោសម្នាក់បានឆក់យកកាំភ្លើងពីអ្នកយាមម្នាក់ហើយបានសម្លាប់ខ្លួនឯង ។ តើលោកមានចាំពីឧប្បត្តិហេតុនេះទេ?

**ឆ៖** បាទ, ចំពោះឧប្បត្តិហេតុនេះគឺ ខ្ញុំមិនបានឃើញដោយផ្ទាល់ទេ គ្រាន់តែឮនយោបាយរៀនដែលជនជាប់ចោទឈ្មោះ ឌុច បានបង្រៀនពីនយោបាយថា មានខ្មាំងឆក់កាំភ្លើងបាញ់សម្លាប់ខ្លួន ដូច្នេះអ្នកដែលត្រូវយាមការពារទាំងអស់ត្រូវដកកាំភ្លើងទាំងអស់ ។ នេះជាបាតុភាពតាំងពីដើមឆ្នាំ៧៧ដែលទើបនឹងរើសពីប៉េហ្ស៊ី មកនៅមន្ទីរស-២១ ។

**ស៖** លោកបានប្រាប់អង្គវនាការថា គឺមានអ្នកទោសទាំងប្រុសទាំងស្រីនៅស-២១ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, ចំពោះសំណួរនេះគឺត្រឹមត្រូវ ។

[១០:០៥:០០]

**ស៖** តើលោកមានឱកាសដែលបានសួរចម្លើយអ្នកទោសស្រីដែរឬទេ?

**ឆ៖** បាទ, ចំពោះអ្នកទោសស្រី គឺខ្ញុំមិនដែលបានសួរទេ ។

**ស៖** តើលោកមានស្គាល់អ្នកសួរចម្លើយណានៅក្នុងក្រុមរបស់អ្នក ឬក៏ក្រុមអ្នកដទៃទៀតដែលធ្លាប់បានសួរចម្លើយអ្នកទោសស្រីដែរឬទេ?

**ឆ៖** បាទ, តាមខ្ញុំឃើញគេបណ្តើរទៅច្រើនតែពួកខាងអង្គរក្សរបស់ តាចាន់ និង តាហ៊ី បណ្តើរមនុស្សស្រីយកទៅសួរ គឺខ្ញុំដឹងតែប៉ុណ្ណឹង ។

**ស៖** តើលោកមានចាំទេ? មានអ្នកសួរចម្លើយម្នាក់ឈ្មោះ ទូច ហើយប្រហែលជាគាត់ហ្នឹងគាត់តូច ឬក៏ ទូច ដែលប្រហែលជា ទូច នឹងមានន័យថា សំដៅទៅលើមនុស្សដែលមានរូបរាងតូចហើយមានអ្នកសួរចម្លើយណាឈ្មោះអ៊ីចឹងទេ?

**ឆ៖** បាទ,ឈ្មោះ ទូច នេះគឺមាន ។ គាត់ជាអ្នកសួរចម្លើយ ហើយបានលោតពីលើផ្ទះថ្ម ។ គាត់បានសីលធម៌ជាមួយអ្នកទោស ហើយគាត់ភ័យខ្លួនគាត់លោតពីលើផ្ទះថ្មសម្លាប់ តែទើរនឹងខ្សែរភ្លើងគាត់ក៏អត់បានស្លាប់ទេ ។ ហើយគេក៏ចាប់យកទៅដាក់មន្ទីរឃុំឃាំងបណ្ដោយ ។

[១០:០៦:៤៣]

**ស៖** អ៊ីចឹងតើលោកនិយាយអំពីកំហុសសីលធម៌នឹងមានន័យថា ការរំលោភមែនទេ?

**ឆ៖** បាទ, នេះជាការរំលោភរបស់នារី ឈ្មោះ ទូច ហ្នឹងបានរំលោភនារី ។

**ស៖** តើមានរឿងអ្វីកើតឡើងចំពោះស្ត្រីហ្នឹងបន្ទាប់ពីគាត់ត្រូវបាន ទូច រំលោភហើយនោះ?

**ឆ៖** បាទ, ចំពោះរឿងហេតុស្ត្រី គឺខ្ញុំមិនបានដឹងច្បាស់ទេ ។ គេយកទៅពេទ្យមិនដឹងជារស់ឬក៏ស្លាប់ផង ខ្ញុំក៏មិនដឹងដែរ ។

**ស៖** បន្ទាប់ពីលោកបានទទួលចម្លើយសារភាពពីអ្នកទោសហើយ តើមានរឿងអ្វីកើតឡើងទៀតតើលោកបញ្ជូនចម្លើយសារភាពនោះទៅនរណាគេ?

**ឆ៖** បាទ, ចំពោះចម្លើយសារភាពតាម-- បញ្ជូនទៅតាមខ្សែរយៈគឺទៅតាមប្រធានក្រុមដែលមានឈ្មោះ ហេង, ឈ្មោះ កាក់, ឈ្មោះ ណាន ។

**ស៖** តើលោកមានចាំទេ ថាចម្លើយសារភាពនោះបានបញ្ជូនទៅឲ្យជនជាប់ចោទ ហើយបន្ទាប់មកទៀតហ្នឹងគឺ ជនជាប់ចោទបានធ្វើដាក់ទៅ-- បានសរសេរចំណាររទៅលើចម្លើយសារភាពនោះដើម្បីឲ្យសួរបន្តទៀត ។ តើមានករណីអ៊ីចឹងទេ?

**ឆ៖** ចំពោះការចារបន្តនេះ គឺខ្ញុំមិនបានចាំច្បាស់ទេ ចួនកាល-- មិនបានចាំថាគាត់ចារមកឬអត់គឺមិនបានចាំទេ ចួនកាលបែប-- ប្រហែលជាមានចារមកពីការនឹកឃើញស្រមើស្រមៃរបស់ខ្ញុំប្រហែលជាមាន ។

**ស៖** លោកបានជម្រាបប្រាប់អង្គសវនាការថា លោកគឺជាអ្នកសួរចម្លើយថ្មី ដូច្នេះគឺគេឲ្យសួរតែអ្នកទោសសាមញ្ញៗតែប៉ុណ្ណោះ ។ ប៉ុន្តែ លោកក៏បានប្រាប់ទៅចៅក្រមស៊ើបសួរផងដែរថា ក្រោយមកបានមានជំនាញក្នុងការសួរចម្លើយ អ៊ីចឹងមែនទេ?

**ឆ៖** បាទ, ព្រោះរឿងការជំនាញសួរចម្លើយគឺខ្ញុំមិនទាន់បានជំនាញច្បាស់លាស់ប៉ុន្មានទេ ព្រោះទើបរៀនថ្មី ។

**ស៖** លោកបានជម្រាបប្រាប់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា អ្នកសួរចម្លើយវ័យចំណាស់ៗនោះដែលមិនបានទទួលចម្លើយពីអ្នកទោសក្នុងរយៈពេលពីរបីខែក្រោយមកនោះ គេបានបញ្ជូនអ្នកទោសអស់ទាំងហ្នឹងមកឲ្យលោកសួរ ហើយគឺថាលោកទទួលសួរបានចម្លើយភ្លាមតែម្តងតើត្រឹមត្រូវដែរឬទេ?

**ឆ៖** ចំពោះរឿងចំណុចនេះ គឺខ្ញុំមិនបានដឹងច្បាស់ មិនបានដឹងថាគាត់សួរមិនឆ្លើយ ឬឆ្លើយខ្ញុំមិនដឹងដែរ ចំពោះអ្នកទោសគាត់បញ្ជូនមកឲ្យខ្ញុំសួរ គឺខ្ញុំសួរ ។ ឲ្យខ្ញុំសួរឈ្មោះអី គឺឈ្មោះហ្នឹង តែមិនដឹងឈ្មោះហ្នឹងគេសួររួចឬនៅ គឺខ្ញុំអត់បានដឹង ។

[១០:១០:១៧]

**លោក អានីស អះមេដ៖**

ខ្ញុំចង់បង្ហាញឯកសារពីរដល់ជនសាក្សី ដោយមានការអនុញ្ញាតពីលោកប្រធាន ។ គឺឯកសារនោះមានលេខ 00039595 ។ សូមឲ្យដាក់បញ្ចាំងឯកសារនេះ ។ នៅពេលដែលធ្វើការបញ្ចាំងឯកសារនេះ ខ្ញុំចង់រៀបរាប់បន្តិចអំពីឯកសារនេះ ។

ឯកសារនេះ គឺជាបញ្ជីៗអ្នកទោសដែលត្រូវបានគេសួរចម្លើយ ។ សូមលោកប្រធានអនុញ្ញាតឲ្យធ្វើការបញ្ចាំងឯកាសារនេះ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍បញ្ចាំងនូវឯកសារដែលមានលេខERN00039595 លើកញ្ចក់អេក្រង់ទូរទស្សន៍។

**សួរដោយលោក អានីស អះមេដ៖**

**ស៖** លោក ឡាច មាន! សូមឲ្យធ្វើបញ្ចាំងឯកសារនេះនៅខាងស្តាំ គឺកូឡោនចុងក្រោយបំផុតនៅខាងស្តាំដៃ ។ លោក ឡាច មាន លោកជាមនុស្សដែលអាចចេះអានអក្សរ សូមលោកអាចអានអក្សរនៅលើអេក្រង់នេះបានទេ? ហើយតើលោកអាចប្រាប់ទេថា តើប្រភេទឯកសារហ្នឹងត្រូវបានគេប្រើនៅក្នុងស-២១ នោះ?

**ឆ៖** ឈ្មោះ អ្នកទោសសួរថ្ងៃ៣០ ខែ៤ ឆ្នាំ៧៨ នាទីចាស់ថ្មី ធ្វើឯកសារថ្ងៃចាប់មិត្តអ្នកសួរសេនាធិការអនុប្រធានមន្ទីរស-២១ អី! ៦២ ចាស់ធ្វើឯកសារ ៧/ ៤/ ៧៧ ស៊ូ ឡាត់ ភាគបូព៌ា សមាជិក

កងពលតំបន់២០ ចាស់, ត្រៀមថត ១៧ ខែ៤ ៧៧ ។ ខឹម ផូ ប្រធានសន្តិសុខតំបន់៣២ ចាស់ ។

កំណត់ហេតុ ១៤/ ៤/ ៧៨ ។ ប្រាក់ ណាន ប្រធានវរសេនាធំ១១៦ ចាស់ កំណត់ហេតុ២២ ខែ៣ /៧៨ ។ រស់ អឿន ។

**ស៖** តើលោកមានអាចចាំបានទេ? ថាអ្នកសួរដែលមានឈ្មោះនៅខាងស្តាំដៃហ្នឹង លោកមានស្គាល់ឈ្មោះនរណាគេទេ?

**ឆ៖** បាទ, ចំពោះឈ្មោះអស់នេះ គឺខ្ញុំបានស្គាល់ ។ ស្គាល់ឈ្មោះ ណាន ជាប្រធានពួករបស់ខ្ញុំ ហើយឈ្មោះ អឿន ជាអ្នកសួរ ។ ស៊ូ ឡាត់ គឺខ្ញុំស្រពេចស្រពិលដែរ មិនបានស្គាល់ទេ ។ ប្រហែលជាមានក៏មិនដឹង អត់ក៏មិនដឹង ខ្ញុំវាភ្លេចបាត់ទៅ ។

**ស៖** តើលោកគិតថា ឯកសារអស់ទាំងហ្នឹងត្រូវបានលោកប្រើប្រាស់ ឬក៏ក្រុមរបស់លោកដែលជាអ្នកសួរចម្លើយហ្នឹងប្រើប្រាស់នៅស-២១ មែនទេ?

**ឆ៖** បាទ, ចំពោះឯកសារនេះ គឺខ្ញុំភ្លេចបាត់ហើយ ។ ហើយមានមែនក៏មិនដឹង គឺខ្ញុំមិនបានចាំច្បាស់ទេ ព្រោះឯកសារអស់នេះវាយូរហើយ ។ មិនដឹងជាប្រើ ឬក៏នេះមិនដឹង គឺខ្ញុំមិនច្បាស់ ហើយគឺខ្ញុំសូមថាមិនឆ្លើយ ។

[១០:១៤:៣២]

**លោក អានីស អះមេដ៖**

ខ្ញុំចង់បញ្ចាំងឯកសារមួយទៀតគឺមានលេខ00039596 ដែលមានការអនុញ្ញាតពីលោកប្រធាន។ សូមលោកប្រធានឲ្យធ្វើការបញ្ចាំងឯកសារនេះ ។

**ប្រធានអង្គជំនុំ៖**

ខាងសោតទស្សន៍បញ្ចាំងនូវឯកសារនេះ ហើយសំណួរចុងក្រោយរបស់តំណាងសហព្រះរាជអាជ្ញាហើយ ព្រោះការប្រើប្រាស់ពេលវេលាលើសហើយ ។

**លោក អានីស អះមេដ៖**

បាទ លោកប្រធាននេះ គឺជាសំណួរចុងក្រោយរបស់ខ្ញុំដែរ ។ ឯកសារនេះមានលេខ ERN000--

**ស៖** លោក ឡាច មាន តើលោកអាចអានឯកសារនេះបានទេ? សូមឲ្យធ្វើការបញ្ចាំងនូវកូឡោនខាងក្រោយនៅខាងស្តាំដៃ ។ សូមលោកអាននូវឈ្មោះអ្នកសួរ ហើយតើពេលអានហើយតើលោកអាចចាំថា មានឈ្មោះណាដែលលោកស្គាល់ទេ?

**ឆ៖** បាទ, ចំពោះឈ្មោះអ្នកសួរចម្លើយ គឺខ្ញុំអាចចាំបានឈ្មោះ ហ៊ាង ប្រហែលជាមាន គឺស្រពេចស្រពិលដែរ ហើយឈ្មោះ អឿន នេះគឺមាន ។ អឿនៗ សួរចម្លើយគឺមានពីរនាក់ មួយឈ្មោះ សួស អឿន មួយឈ្មោះ ជា អឿន នេះគឺមានពីរ ។ ហើយចំពោះ ប្រាក់ អឿន ខ្ញុំស្រពេចស្រពិល ភ្លេចបាត់ហើយ ។ ចំពោះឈ្មោះ ហេង គឺមានជាប្រធានក្រុមរបស់ខ្ញុំ ។ ហើយឈ្មោះ ទិត គឺមានជាអ្នកសួរចម្លើយដែរ ។ ហើយឈ្មោះ ហាន់ ខុន ប្រហែលជាមានខ្ញុំស្រពេចស្រពិលដែរ ។ ឈ្មោះ វ៉ែន ខុលខឿន ខ្ញុំមិនបានស្គាល់ទេ ។ ហើយឈ្មោះ សៀក ខនៗ គឺខ្ញុំស្រពេចស្រពិលដែរ ប្រហែលជាមាន ។

[១០:១៦:៥១]

**លោក អានីស អះមេដ៖**

លោកប្រធាន ខ្ញុំបាទបានចប់ហើយក្នុងការសួរសាក្សីនេះ ។ ខ្ញុំចង់ធ្វើការស្នើទៅអង្គជំនុំជម្រះថា សំណួរ-- ការឆ្លើយរបស់គាត់នៅចំពោះសហចៅក្រមស៊ើបអង្កេតនោះ គឺសូមឲ្យចាត់ទុកថាត្រូវបាន-- ចាត់ទុកថាត្រូវបានអាន ហើយនិងដាក់នៅចំពោះមុខអង្គសវនាការ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តសូមប្រគល់វេទិកាទៅមេធាវីអ្នកតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការសួរសំណួរដល់សាក្សីរូបនេះ ។ សូមអញ្ជើញបាទ ។

[១០:១៧:៤៤]

**ការតាំងសំណួរដោយក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

**សួរដោយកញ្ញា ទី ស្រ៊ុនណា៖**

ជាបឋមនាងខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល ។ ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីយើងខ្ញុំ បានព្រមព្រៀងគ្នាឲ្យមេធាវីក្រុមមួយ និងក្រុមពី នឹងធ្វើការតាំងសំណួរទៅលើសាក្សីរូបនេះ ដោយធ្វើការបែងចែកពេលវេលាពាក់កណ្តាលម្នាក់ ។ នាងខ្ញុំសូមធ្វើការតាំងសំណួរ ។

ជម្រាបសួរលោក ឡាច មាន ។ នាងខ្ញុំជាមេធាវីឈ្មោះ ទី ស្រ៊ុនណា និងលោកមេធាវី អាឡាំង វ៉ែនណឺ ជាមេធាវីអន្តរជាតិនៅក្នុងក្រុមខ្ញុំ ។ សូមធ្វើការតាំងសំណួរដូចតទៅ៖

**ស៖** នាងខ្ញុំសូមលើកនូវកំណត់ហេតុមួយដែលលោកបានធ្វើការឆ្លើយនៅជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា ដែលចុះថ្ងៃទី៧ ខែធ្នូ ២០០៦ ដែលមានលេខ ERN ជាភាសាខ្មែរ 00145587

និងERN ជាភាសាអង់គ្លេសដែលមានលេខ 00146789 លេខរបស់ក្បាលឯកសារដែលមានលេខ D2.6/2 ។ នៅក្នុងហ្នឹងនៅចំណុចមួយ ឃ្លាមួយលោកបានជម្រាបទៅការិយាល័យសហចៅក្រមស៊ើបអង្កេតថា ឯកសារដែលវាយអង្គុលីលេខហើយ យកមកឲ្យទៅ ឌុច ដើម្បីពិនិត្យរកខ្សែរយៈអ្នកក្បត់តាមរយៈចម្លើយនោះ ។ តើលោកពិតជាបានជម្រាបទៅការិយាល័យសហព្រះរាជអាជ្ញាដូច្នេះដែរឬទេ? លោកនៅទទួលស្គាល់ថា លោកពិតជាបានឆ្លើយបែបនោះដែរឬទេ?

[១០:១៩:៣៧]

**ឆ៖** បាទ, ចំពោះចម្លើយអស់នេះ គឺខ្ញុំមិនប្រាកដដែរ តែចម្លើយរបស់ខ្ញុំថាវាមិនច្បាស់ទេ តែចំពោះចម្លើយដែលអ្នកទោស-- ខ្ញុំចម្លងឯកសារហើយគឺឲ្យទៅឈ្មោះប្រធានរបស់ខ្ញុំគឺឈ្មោះ ភាព ជាអ្នកបង្រៀនខ្ញុំវាយអង្គុលីលេខហ្នឹង ។ ចម្លងឯកសារហ្នឹង គឺឈ្មោះ ភាព ហៅ ច្រឹក បច្ចុប្បន្នរស់នៅខាងឃុំតាចេសដែរ នៅខាងព្រែកលិច ។

**ស៖** ដោយសារតែលោកមានការចងចាំទាបអ៊ីចឹង អ៊ីចឹងនាងខ្ញុំសូមជួយរំឭកដល់លោកបន្តិចកាលពីម្សិលមិញ លោកក៏បានឆ្លើយជាមួយនឹងលោកចៅក្រម យ៉ា សុខន ដែលលោកបានឆ្លើយ-- លោកចៅក្រម យ៉ា សុខន បានសួរលោកថា តើនៅពេលដែលមានការសួរយកចម្លើយយកទៅអ្នកទោស ស-២១ សួរថា តើគេសួរចម្លើយដើម្បីអ្វី? លោកក៏បានឆ្លើយដែរ ថាកាលនុ៎ងគេសួរចម្លើយគឺដើម្បីរកខ្សែរយៈអ្នកក្បត់។ តើលោកពិតជាបានឆ្លើយអំពីម្សិលមិញអ៊ីចឹង ដែរឬទេ? លោកទទួលយកនូវចំណុចនេះដែរឬទេ?

**ឆ៖** បាទ, ចំពោះសំណួរនេះ គឺខ្ញុំទទួលបាន គឺខ្ញុំបានឆ្លើយ ។ ពីម្សិលមិញ គឺខ្ញុំបានឆ្លើយនូវចំណុចនេះមែន ។ ខ្ញុំទទួលបាន ។

**ស៖** ផ្ទុយមកវិញ នាងខ្ញុំគ្រាន់តែចង់បង្ហាញទៅលើ-- ចង់បង្ហាញលោកថាកាលនៅក្នុងឯកសារដែលខ្ញុំបានរៀបរាប់ពីលើអំមិញហ្នឹង លោកបាននិយាយថា នៅក្នុងឯកសារហ្នឹង លោកបានឆ្លើយជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា ដោយលោកបានលើកនូវចំណុចមួយ ដែលពេលនុ៎ងលោកឆ្លើយ -- ខ្ញុំសុំអានពីលើបន្តិច ដើម្បីជាការរំឭកដល់លោក ពីព្រោះថាវារឿងយូរឆ្នាំដែលហើយ ដែលនាំឲ្យលោកភ្លេចភ្លាំង ។ អ៊ីចឹង ខ្ញុំសុំអានពីលើបន្តិចនូវចំណុចមួយ ដែលលោកដែលបានលើកឡើងថា៖

*“គេដឹកអ្នកទោសចូលតាមឡាន ឈ្មោះ ធី នាំអ្នកទោសចុះពីឡាន និងឈ្មោះ ឡាញ ក៏នាំអ្នកទោសចេញពីឡានដែរ ។ ឯកសារដែលវាយអង្គុលីលេខហើយ យក១ឲ្យទៅ ឌុច ដើម្បីពិតរក*

*ខ្សែរយៈក្បត់ អ្នកក្បត់តាមរយៈចម្លើយនោះ ។"*

តើលោកទទួលស្គាល់នូវចម្លើយនេះដែរ-- លោកពិតជាបានឆ្លើយបែបនេះ នៅក្នុងការិយាល័យសហព្រះរាជអាជ្ញា ដែរឬទេ? លោករក្សាចម្លើយនេះដែរឬទេ?

**ឆ៖** ចំពោះចម្លើយនេះ គឺខ្ញុំទទួលស្គាល់ថា ខ្ញុំបានឆ្លើយនូវកាលហ្នឹងមែន ។

**ឆ៖** អ៊ីចឹង ខ្ញុំសូមបន្តទៀត នៅពេលដែលលោកសួរបានចម្លើយហើយ តើអ្នកទោសនៅក្នុងមន្ទីរស-២១ ឆ្លើយថា អ្នកដែលក្បត់ខ្សែរយៈអ្នកក្បត់ តើពេលនុ៎ង អ្នកទោសពិតជាបានឆ្លើយដាក់ឈ្មោះ ក ឬក៏ឈ្មោះ ខ ដទៃទៀត ដែរឬទេ?

**ឆ៖** ចំពោះចម្លើយអ្នកទោសគឺ--អ្នកទោសដែលព្រមសារភាពគឺមានចម្លើយដាក់ឈ្មោះអ្នកនេះអ្នកនោះ គឺមានចម្លើយ ។

[១០:២៣:២០]

**ស៖** ទាក់ទងនៅនឹងការឆ្លើយដែលបានចម្លើយឈ្មោះ ក, ខ តើថ្នាក់លើដែលៗយើងបញ្ជូនឯកសារហ្នឹង ទៅដល់ថ្នាក់លើ ដើម្បីធ្វើការពិតរកខ្សែរយៈអ្នកក្បត់ ពេលដែលពេលបញ្ជូនទៅដល់ថ្នាក់លើ តើលោកមានបានដឹង ឬក៏បានចាំអី ថាតើថ្នាក់លើមានធ្វើការស្វែងរកបុគ្គលតាមរយៈចម្លើយរបស់អ្នកសួរហ្នឹង ដែរឬទេ?

**ឆ៖** ចំពោះបញ្ហានេះ គឺខ្ញុំមិនដឹង ព្រោះការងារសម្ងាត់ ជាការងាររបស់បក្សគេ គឺការងារសម្ងាត់គឺខ្ញុំមិនបានទទួលដឹងទេ នូវសំណួរនេះ ។

**ស៖** ចុះលោកមានបានដឹងថ្នាក់លើមានបានបញ្ជាឲ្យកូនចៅ ដើម្បីធ្វើការចុះទៅចាប់តាមចម្លើយរបស់អ្នកឆ្លើយដែរឬទេ? ចុះទៅចាប់ឈ្មោះ ដែលមាននៅក្នុងចម្លើយនុ៎ងដែរឬទេ? មានបញ្ជាទៅថ្នាក់ក្រោមដើម្បីឲ្យធ្វើការងារហ្នឹងជំនួសដែរឬទេ?

**ឆ៖** បាទ, ចំពោះការងារចាត់តាំង ការងារអាបញ្ជាឲ្យខាងក្រោមរបស់គាត់ទៅចាប់ចំពោះអ្នកទោស គឺខ្ញុំមិនបានដឹងទេ ។

**ស៖** ចុះលោកមានដែលប្រទះអ្នកដែលគេឆ្លើយដាក់ឈ្មោះ ក ។ ឧទាហរណ៍ថាឈ្មោះ ក អ៊ីចឹង តើលោកមានដែលប្រទះថា ឈ្មោះ ក ហ្នឹង ត្រូវបានចាប់មកចូលមកមន្ទីរទួលស្លែងដែរឬទេ លោកមានដែលប្រទះទេ?

**ឆ៖** បាទ, ចំពោះបញ្ហានេះ គឺអត់ដែលប្រទះទេ ព្រោះការងារសម្ងាត់របស់គេ ។ អ្នកសួរចម្លើយមិនអាចទៅដើរមើលអ្នកទោសដែលចាប់មកថ្មី ឬក៏ចាប់មកដាក់បន្ទប់ គឺមិនដែលបានឱ្យអើតមកមើលអ្នកទោសឃើញទេ គឺអ្នកសួរចម្លើយទៅដល់ស៊ីញេរបងពីក្រៅហ្នឹង គឺស៊ីញេឈ្មោះឱ្យអ្នកយាមទៅយកមកឱ្យ ម្ល៉ោះហើយមិនអាចដឹងថា ចាប់ ឬក៏មិនចាប់ទេ ។ នេះ ខ្ញុំមិនអាចទទួលដឹងបាន ។

**ស៖** ខ្ញុំសូមបន្តសំណួរទៀត ទាក់ទងទៅនឹងឯកសារ ទាក់ទងទៅនឹងកំណត់ហេតុស្តាប់នូវសាក្សីស្តាប់ចម្លើយសាក្សីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលចុះថ្ងៃទី២៤ តុលា ឆ្នាំ២០០៧ ដែលមានលេខ ERN ជាភាសាខ្មែរ00162775 និងERN ជាភាសាអង់គ្លេស ដែលមានពីរទំព័រ ព្រោះវាមានលក្ខណៈឆ្លងទំព័រ គឺមានលេខ00162786 ដល់ 00162787 ។ ខ្ញុំសូមធ្វើការបញ្ជាក់ឡើងវិញ លោកបានឆ្លើយជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា ដោយមានសំណួរសួរថា តើមានអ្នកទោសស្លាប់នៅក្នុងគុកនោះដែរឬទេ? លោកបានឆ្លើយថា មានតែស្លាប់ដោយជំងឺរាគជំងឺរាកមួល ។ តើលោកទទួលស្គាល់នូវចម្លើយលោកនេះ ដែរឬទេ?

**ឆ៖** បាទ, ចំពោះចម្លើយនេះ គឺខ្ញុំបានទទួលស្គាល់ ។ គឺកាលពីខ្ញុំនៅកងការពារ គឺឃើញអ្នកទោសមានឈឺស្គម ដោយរាកមួលស្លាប់ គឺខ្ញុំបានធ្លាប់ឃើញ ។ ខ្ញុំទទួលស្គាល់ ។

**ស៖** តើមានជំងឺផ្សេងក្រៅពីជំងឺរាគជំងឺរាកមួលហ្នឹងដែរឬទេ? ដែលនាំឱ្យអ្នកទោសនៅមន្ទីរស-២១ ស្លាប់?

**ឆ៖** បាទ, ចំពោះជំងឺផ្សេងៗ ខ្ញុំមិនដែលឃើញទេ ។

**ស៖** តើលោកមានបានដឹងពីមូលហេតុអ្វី ដែលនាំឱ្យមានការឈឺរាកមួល រហូតដល់ស្លាប់?

**ឆ៖** បាទ, ចំពោះមូលហេតុដែលនាំឱ្យមានរាកមួលនេះ គឺខ្ញុំមិនអាចដឹងបានទេ ព្រោះខ្ញុំមិនបានដឹងដែរ តែតាមការសន្និដ្ឋានរបស់ខ្ញុំ គឺឆ្លងពីគ្នាទៅពីមួយទៅមួយ ព្រោះការបន្ទោបង់ គឺដាក់កែសតែមួយជាមួយគ្នា ។

[១០:២៧:៤៦]

**ស៖** ខ្ញុំសូមធ្វើការបញ្ជាក់ចំណុចមួយទៀតដែលពាក់ព័ន្ធទៅនឹងចៅក្រម ឡាវែន៍ ដែលគាត់បានសួរពីបញ្ហាទាក់ទងនៅនឹងឧបករណ៍ ហើយនៅក្នុងចំណុចនោះ ក៏មានការសរសេរនៅក្នុង១ឯកសារដែលលោកបានឆ្លើយជាមួយនឹងសហចៅក្រមស៊ើបអង្កេតដែរ ដែលមានលេខ ERN 00162777 ជាភាសាខ្មែរ និងERN ជាភាសាអង់គ្លេស ដែលមានលេខ 00162790 ។ នៅក្នុងនុ៎ងគេបានសួរលោកថា

តើមានឧបករណ៍អ្វីផ្សេងទៀតទេ ក្នុងការទារុណកម្ម? លោកបានក៏បានឆ្លើយថាគេចាប់ខ្សែភ្លើងនិងត្រចៀក ហើយរវៃឌីណាម៉ូឲ្យឆក់ ។ លោករក្សាចម្លើយរបស់លោកដែរឬទេ? ពីព្រោះម្សិលមិញនេះពេលដែលលោកចៅក្រម ឡាវែន៍ គាត់បានសួរទៅលោកហ្នឹង ខ្ញុំមានលក្ខណៈស្តាប់អត់ច្បាស់ ព្រោះមានលក្ខណៈប្រហែលជាមកពីការបកប្រែ ឬក៏យ៉ាងម៉េច ក៏ខ្ញុំអត់ច្បាស់ ។ អ៊ីចឹង ខ្ញុំសូមសួរលោកបញ្ជាក់បន្ថែម តើលោកពិតជាបានឆ្លើយបែបនេះមែនដែរឬទេ?

**ឆ៖** បាទ, ជាចម្លើយរបស់នេះ គឺជាចម្លើយរបស់ខ្ញុំមែន ។ ខ្ញុំបានឆ្លើយថា មានចាប់ស្លឹកត្រចៀករវៃជាឌីណាម៉ូ ហើយឆក់ខ្សែ-- ឆក់ស្លឹកត្រចៀកគឺមាន ។ គឺជាចម្លើយពិត ។

**ស៖** បើតាមគំនិតលោក លោកបានឃើញផ្ទាល់ ឬក៏យ៉ាងម៉េច? បើសិនជាលោកបានឃើញផ្ទាល់ ខ្ញុំគ្រាន់តែចង់សួរថា តើបើតាមលោកគិត ទំហំនៃការឈឺចាប់របស់អ្នកទោសដែលត្រូវបានគេកៀបនិងត្រចៀក នឹងរវៃឌីណាម៉ូហ្នឹង តើលោកបើតាមលោកគិតមើលទៅ តើទំហំនៃការឈឺចាប់មានកម្រិតណាដែរ?

**ឆ៖** បាទ, ចំពោះការឈឺចាប់ គឺខ្ញុំមិនបានអាចដឹងទេ ។ ការដែលរវៃទៅ គឺអ្នករវៃខ្លាំងគឺអាចខ្ទើចៗស្លឹកត្រចៀកខ្លាំងហ្នឹង គឺក្បាលខ្លាំងទៅ បើរវៃតិចទៅ អាចតិចទៅ ។ នេះជាការដែលខ្ញុំមើលឃើញ ។

**ស៖** ខ្ញុំសូមបន្តសំណួរទៀត នៅក្នុងឯកសារដែលមានលេខ ERN00162778 និងERN ជាភាសាអង់គ្លេស ដែលមានលេខ 00162790 ជាឯកសាររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដដែល សំណួរសួរថា លោករៀនខាងវាយអង្គុលីលេខ តើពេលសួរចម្លើយ លោកជាអ្នកសរសេរឬយ៉ាងណា? លោកបានឆ្លើយថា ឯកសារមានបីផ្នែក។ ទីមួយ ប្រសិនបើអ្នកទោសអាចសរសេរបាន គឺសរសេរខ្លួនឯង ឬយកចម្លើយនោះមកវាយអង្គុលីលេខឡើងវិញ ។ ទីពីរ គឺវាយជាអង្គុលីលេខ និងទីបីថតយកសំឡេង ចំពោះការថតយកសំឡេងគឺបានប្រើប្រាស់ចុងក្រោយ ប្រហែលមួយខែជិតបែកភ្នំពេញទេ ទើបទទួលបានម៉ាញេ ។ ការថតសំឡេងគឺដើម្បីតាមដានអ្នកសួរនិងអ្នកឆ្លើយ ។ តើលោកទទួលយកចម្លើយនេះដែរឬទេ?

**ឆ៖** បាទ, ចម្លើយនេះ គឺខ្ញុំទទួលបាន ។

**ស៖** ខ្ញុំចង់សួរលោកថា ចំពោះអ្នកទោសដែលគាត់មិនចេះសរសេរ តើគេធ្វើយ៉ាងម៉េច? ហើយនៅក្នុងអំឡុងពេលនុ៎ងហ្នឹង លោកមានវាយអង្គុលីលេខដោយផ្ទាល់ដែរឬទេ?

**ឆ៖** ចំពោះអ្នកទោសដែលមិនចេះសរសេរអក្សរ គឺជាដំបូងអ្នកសួរ គឺសួរមួយម៉ាត់ គឺកត់មួយម៉ាត់ៗ បន្ទាប់ពីចាប់ហើយគឺចម្លងជាអង្គុលីលេខ ។

**ស៖** ខ្ញុំសូមបន្តទៀត ទាក់ទងទៅនឹងការថតសំឡេងៗ ទាក់ទងនឹងការថតសំឡេងគឺដើម្បីតាមដានអ្នកសួរ និងអ្នកឆ្លើយ ។ ខ្ញុំចង់សួរលោកថា តើសម័យនុ៎ង ពិតជាមានការតាមដានទាំងអ្នកសួរ ទាំងអ្នកឆ្លើយ នោះពិតប្រាកដមែនឬទេ?

**ឆ៖** បាទ, ចំពោះចម្លើយនេះគឺជាការពិត ។ ព្រោះការចម្លើយតាមដានអ្នកសួរ ខ្លាំងចង់ជាងតាមដានអ្នកឆ្លើយទៅទៀត ព្រោះការសួរដឹកនាំ ដឹកមុខអ្នកទោស គឺអាចខុសនឹងច្បាប់របស់គេ ម៉្លោះហើយអាចដឹកនាំអ្នកទោសឲ្យឆ្លើយដាក់អ្នកនេះអ្នកនោះ ខុសវិន័យ ខុសច្បាប់ គេនឹងអាចចោទប្រកាន់អ្នកសួរចម្លើយបន្តទៀត ។

**ស៖** តើលោកមានបានដឹងថា តើអ្នកណាជាអ្នកបង្កើតឲ្យមានប្រព័ន្ធនេះ ការប្រើម៉ាញ៉េដើម្បីថតសំឡេងសំឡេងនេះ?

**ឆ៖** បាទ, ចំពោះការប្រើប្រព័ន្ធម៉ាញ៉េឲ្យថតសំឡេងនេះ គឺខ្ញុំមិនបានដឹងដែរ តែខ្ញុំឃើញតែមេក្រុមរបស់ខ្ញុំ គេយកម៉ាញ៉េមកឲ្យខ្ញុំប្រើ នៅពេលសួរចម្លើយ ។ ខ្ញុំដឹងតែប៉ុណ្ណឹង ។

**ស៖** ខ្ញុំចង់សួរលោកថា នៅពេលដែលលោកមកដល់មន្ទីរស-២១ ដំបូង តើលោកមានបានទៅធ្វើប្រវត្តិរូបបញ្ជាក់-- ដើម្បីបញ្ជាក់ថាលោកជាបុគ្គលិករបស់មន្ទីរស-២១ ដែរឬទេ?

**ឆ៖** បាទ, សុំសួរឲ្យច្បាស់ម្តងទៀត ស្តាប់អត់ទាន់ ។

**ស៖** ខ្ញុំសួរថា ពេលដែលលោកមកដល់មន្ទីរស-២១ ដំបូង តើលោកមានបានធ្វើប្រវត្តិរូប ឬមួយក៏បានចុះឈ្មោះនៅក្នុងបញ្ជីអីមួយ តើលោកអាចចាំបានទេ? តើលោកមានបានធ្វើប្រវត្តិរូបអី ដើម្បីបញ្ជាក់ថា គឺលោកជាបុគ្គលិករបស់មន្ទីរស-២១ ឬអត់?

**ឆ៖** ចំពោះប្រវត្តិរូបរបស់ខ្ញុំ គឺចុះបញ្ជីនៅក្នុងស-២១ គឺមានជាប្រចាំ ។ ចួនកាលមួយឆ្នាំធ្វើប្រវត្តិរូបម្តងក៏មាន ។

**ស៖** ទាក់ទងទៅនឹងការរៀនវគ្គនយោបាយ តើខ្ញុំចង់សួរថា តើវាមានភាពខុសគ្នាដែរឬទេ រវាងវគ្គនយោបាយនុ៎ង គឺវគ្គនយោបាយសម្រាប់បក្សកុម្មុយនីស្តទាំងមូល ឬក៏វគ្គនយោបាយសម្រាប់មន្ទីរស-២១?

[១០:៣៤:៥៨]

**ឆ៖** ចំពោះវគ្គនយោបាយគឺមានពីរផ្នែក គឺថ្ងៃដែលរួមទាំងកងការពារ រួមទាំងកងសួរចម្លើយ រួមទាំងខាងព្រៃស គឺជាវគ្គនយោបាយរួមទូទៅ ។ តែចំពោះអ្នកសួរចម្លើយ គឺនយោបាយខុសគ្នា នេះជានយោបាយជំនាន់នោះ ។

**សៈ** តើនរណាជាអ្នកបង្កើតនយោបាយសម្រាប់អ្នកសួរចម្លើយ?

**ឆ៖** ចំពោះអ្នកបង្កើតនយោបាយ អ្នកសួរចម្លើយគឺខ្ញុំមិនបានដឹងដែរ តែឃើញតែជនជាប់ចោទឈ្មោះ ឌុច នេះ គឺបង្រៀននៅកន្លែងសាលានយោបាយ ។

**សៈ** តើលោកបានជួបជនជាប់ចោទប៉ុន្មានដឹងដែរ ចាប់តាំងពីលោកធ្វើការនៅមន្ទីរស-២១?

**ឆ៖** បាទ, ចំពោះការជួប ចំពោះជនជាប់ចោទ គឺខ្ញុំជួបតាំងពីខ្ញុំនៅមកចូលកងសួរចម្លើយ ជួបសឹងតែរាល់ថ្ងៃ ។

**សៈ** តើពេលដែលលោកជួប លោកមានអារម្មណ៍ខ្លាច ឬមួយក៏លោកមានអារម្មណ៍សប្បាយនៅក្នុងការធ្វើការជាមួយគាត់?

**ឆ៖** បាទ, ចំពោះកាលនោះ គឺខ្ញុំមិនសូវហ៊ាននិយាយជាមួយគាត់ គឺឃើញគាត់មកគឺខ្លាច គេចមុខរហូត ។

[១០:៣៦:៤០]

**សៈ** មូលហេតុអ្វីបានជានាំឲ្យលោកខ្លាចគាត់?

**ឆ៖** បាទ, គឺជំនាន់នោះ គឺឃើញមុខគាត់ គឺមុខរាងដូចកាចផង ហើយសម្ដីគាត់ម៉ាត់ៗ គឺឃើញគាត់គឺឲ្យខ្លាចតែម្ដង ។

**សៈ** ខ្ញុំសូមសួរមួយសំណួរទៀត ជាសំណួរចុងក្រោយ ទាក់ទងទៅនឹងករណីជនក្បត់ ខ្សែរយៈក្បត់ ឬក៏ខ្មាំង ។ ខ្ញុំចង់សួរលោកថា ពេលដែលខាងអង្គការគេចោទប្រកាន់អ្នកទោសមន្ទីរស-២១ ថាជាខ្មាំង ឬក៏ជាអ្នកក្បត់ តើលោកជឿជាក់ថា ពួកទាំងនោះពិតជាខ្មាំង ឬក៏ជាអ្នកក្បត់ដែរឬទេពេលនុ៎ង?

**ឆ៖** ចំពោះបញ្ហានេះ គឺខ្ញុំមិនបាន ក៏មិនសូវជឿដែរ ព្រោះអ្នកទោស-- អ្នកសួរចម្លើយ ដូចជាប្រធានក្រុមខ្ញុំអី គាត់ណែនាំខ្ញុំឲ្យសួរអីអ៊ីចឹង ។ បើគាត់ថាអ្នកនឹងក្បត់ ក៏ខ្ញុំមិនសូវជឿដែរ ព្រោះការងារគាត់ធ្វើគឺដូចជាមិនមានបញ្ហាអីខុសដែរ តែលោគេលេចធ្វើការងារសម្ងាត់ខាងក្រៅទៀត ក៏ខ្ញុំមិនបានដឹងដែរ ។ បើតាមការងារជាក់ស្ដែងគឺអត់ជឿថាគាត់ក្បត់ ។

**កញ្ញា ទី ស្រ៊ីនណា៖**

តំណាងឲ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណីយើងខ្ញុំ ខ្ញុំសូមធ្វើថ្លែងអំណរគុណចំពោះលោក ឡាច មាន ដែលបានផ្តល់នូវចម្លើយដល់ក្រុមនាងខ្ញុំ ក៏ដូចជាអង្គសវនាការទាំងមូល ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំនាទីរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តការសួរស្តាប់សក្ខីកម្មសាក្សីរូបនេះ ។ មន្ត្រីតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យដល់សាក្សីរូបនេះផង ហើយឲ្យនាំគាត់មកកាន់សាលសវនាការមុនម៉ោងកំណត់ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកនៅម៉ោង១០:៣៨នាទីដល់ម៉ោង ១០:៥៤នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោល ហើយជាបន្តនេះ សូមប្រគល់វេទិកាទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងក្រុមពីរដែលត្រូវសួរសាក្សីរូបនេះ ។ សូមអញ្ជើញ ។

**សួរដោយលោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី៖**

សូមអរគុណលោកប្រធាន ហើយសូមជម្រាបសួរលោក ឡាច មាន ខ្ញុំឈ្មោះ ស្ទួតហ្សីនស្គី ។ ខ្ញុំជាមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយខ្ញុំនឹងសួរសំណួរមួយចំនួនទៅលោក ។

**ស៖** សំណួរទីមួយរបស់ខ្ញុំ គឺយោងទៅរកការសង្កេតទូទៅរបស់លោក នៅពេលដែលលោកធ្វើនៅទួលស្លែង នៅស-២១ ។ ជនជាប់ចោទបានជម្រាបតុលាការថា យ៉ាងហោចណាស់មានអ្នកទោសម្នាក់ត្រូវបានឃុំខ្លួននៅស-២១ នោះ គឺដប់ប្រាំបួនខែ ដែលវែងជាងគេ ។ អ៊ីចឹងសំណួររបស់ខ្ញុំចំពោះលោក តើលោកបានដឹងអំពីថា តើនៅទួលស្លែងហ្នឹងបានឃុំអ្នកទោសដូចម្តេច នៅពេលដែលគេនៅឃុំខ្លួនយូរ? តើគេកាត់សក់ឲ្យអ្នកទោសដែរឬទេ? តើមានជាងកាត់សក់ដែរឬទេ នៅកន្លែងនោះ? តើមានឱកាសណាមួយដែលគេអាចនឹងមានវិធានការដូចម្តេច ដែលថាគេមានសក់វែង ហើយគេបានកាត់សក់

របៀបម៉េចដែរ?

**ឆ៖** ចំពោះជាងកាត់សក់នៅកន្លែងនោះ គឺចំពោះអ្នកទោស គឺមិនដែលបានកាត់សក់នោះទេ ទោះបីសក់វែង ឬសក់ខ្លីយ៉ាងណា គឺអត់ដែលបានកាត់ទេ ។ គឺមិនដឹងថា មានជាងកាត់ ឬក៏អត់ទេ គឺខ្ញុំមិនបានដឹងច្បាស់ដែរ តែបើខ្ញុំនៅជាកងការពារ គឺមិនដែលបានឃើញកាត់សក់ទេ ។ ហើយចំពោះអ្នកដែលជាប់ថា ជាយូររយៈ ប្រាំមួយ ប្រាំពីរខែ គឺខ្ញុំមិនបានដឹងទេរឿងនេះ ។

**ស៖** តើលោកបានឃើញអ្នកទោសដែលមានសក់វែង ហើយកាន់តែវែងកាលណាគេឃុំខ្លួននៅទីនោះកាន់តែយូរនៅស-២១ នោះ?

**ឆ៖** បាទ, ចំពោះការសក់វែង គឺមាន គឺឃើញមានអ្នកទោសចំពោះអ្នកទោសសក់វែង ។

**ស៖** សូមអរគុណ អ៊ីចឹងខ្ញុំចូលទៅដល់សំណួរមួយទៀត ។ គឺនៅពេលដែលលោកបំពេញការងារនៅស-២១ ហើយខ្ញុំចង់សួរបញ្ជាក់ជាដំបូង ថាតើអ្វីជាការងារដំបូងរបស់លោកពេលដែលលោកចូលទៅដល់ស-២១?

[១០:៥៨:៣៣]

**ឆ៖** ចំពោះការងារដំបូង ដែលខ្ញុំចូលមកដល់ស-២១ ការងារដំបូង ដែលខ្ញុំចូលមក គឺយាមអ្នកទោសនៅតាមបន្ទប់ហ្នឹងតែម្តង ។

**ស៖** ខ្ញុំសូមយោងទៅរកចម្លើយដែលលោកបានឆ្លើយទៅឲ្យអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានពិភាក្សាថ្ងៃនេះដែរ ហើយខ្ញុំនឹងអានមួយផ្នែកមួយនៅក្នុងចម្លើយ ដែលលោកបានឆ្លើយនោះនៅក្នុងទំព័រ១១ លេខ ERN-- ។ តើលោកប្រធាន ខ្ញុំគួរអានលេខ ERN ទេ? ពីព្រោះព្រឹកមិញនេះយើងបានអាន តើខ្ញុំអានឡើងវិញទេ? អ៊ីចឹងនៅក្នុង ERN នោះ គឺ 00335276 រហូតទៅដល់ 00335296 នៅក្នុងអត្ថបទអង់គ្លេសនៅក្នុងទំព័រ១២ អង់គ្លេស នៅក្នុងភាសាខ្មែរ នៅក្នុងនោះ គឺ 0057073 រហូតទៅដល់ 0057078 ។ លោក ឡាច មាន ខ្ញុំអានអំពីកំណត់ត្រាសួរចម្លើយនេះ ដូចខាងក្រោម៖

គេបានសួរលោកថា តើលោកបានឈប់ធ្វើជាអ្នកយាមនៅពេលដែលគេបញ្ជូនលោកទៅគុកទួលស្លែងឬ? ពេលនោះលោកឆ្លើយថា “បាទ” ។ បន្ទាប់មកគេសួរលោកតទៅទៀត តើលោកធ្វើការជាអ្នកវាយម៉ាស៊ីនអង្គុលីលេខឬទេ នៅពេលនោះ? ពេលនោះលោកឆ្លើយថា “ខ្ញុំជាអ្នកវាយអង្គុលីលេខរហូតដល់ឆ្នាំ១៩៧៩ ហើយនៅពេលនោះគេបានបញ្ជូនខ្ញុំឲ្យទៅរៀនសួរចម្លើយ”។

តើលោកនៅចាំដែរឬទេ ពីព្រោះការនេះបានធ្វើយូរហើយ? តើលោកអាចបញ្ជាក់អ្វីដែលលោក

បានឆ្លើយទៅខាងមជ្ឈមណ្ឌលឯកសារកម្ពុជានោះ អំពីកិច្ចការដែលខ្ញុំបានអានអំមិញឲ្យលោកស្ដាប់ហ្នឹងដែរឬទេ?

**ឆ៖** បាទ,ចំពោះសំណួរនេះ គឺខ្ញុំបានឆ្លើយប្រាប់មណ្ឌលឯកសារមែន តែគឺថាជាចម្លើយរបស់ខ្ញុំ។

**ស៖** សូមឲ្យលោកនិយាយឡើងវិញម្ដងទៀត ពីព្រោះខ្ញុំមិនបានឮការបកប្រែពេញលេញនៅឡើយទេ ។ សំណួររបស់ខ្ញុំគឺថា តើលោកអាចបញ្ជាក់ឡើងវិញបានទេ ពីអ្វីដែលលោកបានប្រាប់ទៅខាងមជ្ឈមណ្ឌលឯកសារកម្ពុជា? គឺនៅពេល ដែលលោកត្រូវបានគេបញ្ជូនទៅធ្វើការនៅគុកទួលស្លែងនោះ លោកបានឈប់បំពេញកិច្ចការជាអ្នកយាមហើយ ។ មែនទេ?

[១១:០២:១២]

**ឆ៖** បាទ, ជា-- ខ្ញុំឈប់បំពេញកិច្ចការជាអ្នកយាម គឺគេឲ្យខ្ញុំទៅរៀនវាយអង្គុលីលេខ ចម្លងឯកសារ ។ នេះជាសំណួរ-- ជាចម្លើយរបស់ខ្ញុំ ជាការពិត ។

**ស៖** តើអ្វី ដែលលោកនិយាយហ្នឹង គឺជាការពិត មែនទេ?

**ឆ៖** បាទ, ជាការពិត ។

**ស៖** សូមអរគុណ ។ ឥឡូវនេះ ខ្ញុំបន្តទៅទៀតទាក់ទងទៅនឹងចំណុចថ្មីមួយទៀត ។ ចំណុចនេះត្រូវបានពិភាក្សារួចហើយ ហើយត្រូវបានសួរដោយខាងលោកសហព្រះរាជអាជ្ញា គឺទាក់ទងទៅនឹងការសួរចម្លើយអ្នកទោសដែលជាស្ត្រី ។ ខ្ញុំចង់និយាយម្ដងទៀតទៅលើចម្លើយរបស់លោកជាមួយនឹង*ឌីស៊ីខេម* ហើយនៅក្នុងភាសាអង់គ្លេសនោះ គឺនៅទំព័រទី១៦ ហើយមានលេខ ERN ដដែល ដូចដែលខ្ញុំបានអានមុននោះ គឺ ERN ជាភាសាអង់គ្លេស 00335291 ហើយលោក ឡាច មាន ខ្ញុំនឹងអានឲ្យលោកស្ដាប់នូវអ្វី ដែលគេបានសួរលោក និងអ្វីដែលលោកបានឆ្លើយជាមួយនឹង *ឌីស៊ីខេម* នោះ ។

សំណួរគឺថា តើនរណាគេជាអ្នកសួរចម្លើយអ្នកទោសជាស្ត្រី? ហើយលោកបានឆ្លើយថា “ពួកយើងសួរចម្លើយអ្នកទោសស្ត្រីហ្នឹង ដូចជាធម្មតា ។ ចួនកាលយើងទទួលបានបញ្ជាឲ្យសួរចម្លើយអ្នកទោសស្ត្រីនោះ ហើយចួនកាលទៀត គឺសួរចម្លើយអ្នកទោសប្រុស ។ គេមិនបានធ្វើការកំណត់ឲ្យយើងសួរតែទៅលើអ្នកទោសស្ត្រី ឬក៏បុរសនោះទេ” ។

សំណួររបស់ខ្ញុំនៅពេលនេះ គឺថា តើលោកមានបានចាំ លោកបាននិយាយដូច្នេះទេ ពេលដែលលោកប្រាប់ទៅខាង *ឌីស៊ីខេម* នោះ?

**ឆ៖** បាទ, ចំពោះការ សំណួរនេះគឺខ្ញុំមិនប្រាកដក្នុងខ្លួនទេ តើខ្ញុំបានឆ្លើយឬក៏អត់ គឺខ្ញុំមិនបានចាំ។ ដូច្នេះ គឺខ្ញុំសូមមិនឆ្លើយនឹងសំណួរនេះ ។

**ស៖** តើលោកមានដឹងទេអំពីវិធាន ឬក៏បទបញ្ជាកផ្ទៃក្នុងអ្វីដែលត្រូវបានគេកំណត់នៅស-២១ អំពីការប្រព្រឹត្តិទៅលើអ្នកទោស ដែលជាអ្នកទោសស្រីនិងអ្នកទោសប្រុសនៅក្នុងពេលសួរចម្លើយនោះ?

**ឆ៖** បាទ, ចំពោះការវិន័យ ឬការបទបញ្ជាឲ្យប្រព្រឹត្តនូវចំពោះអ្នកទោស គឺចំពោះការណែនាំ ឬក៏បទបញ្ជារបស់គេ គឺឲ្យធ្វើម៉េចខំសួរចម្លើយឲ្យអ្នកទោសឆ្លើយ ហើយឲ្យត្រឹមត្រូវស្របច្បាប់ ហើយឲ្យពិត កុំឲ្យកុហក ហើយមិនឲ្យយើងធ្វើទារុណកម្ម ឬធ្វើកាចសាហាវដាក់អ្នកទោសជាដំបូងជាដាច់ខាត ។ នេះជាការណែនាំការសួរចម្លើយ ។

[១១:០៦:២៤]

**ស៖** សូមអរគុណ ។ ខ្ញុំនឹងបន្តទៅទៀត ។ ខ្ញុំចង់និយាយឡើងវិញអំពីការរំលោភទៅលើស្ត្រីនៅស-២១ ដែលលោកបាននិយាយមុននោះ ។ លោកនិយាយថា លោកបានឮអំពីការរំលោភមកលើស្ត្រីនោះ តើលោកអាចផ្តល់ព័ត៌មានពិស្តារបន្ថែមមកទៀតប្រាប់យើងខ្ញុំបានទេ អំពីការរំលោភលើស្ត្រីនោះ?

**ឆ៖** បាទ, ចំពោះការរំលោភលើស្ត្រីនោះ គឺមិនដឹងជាឆ្នាំណាទេ តែដំបូងនោះឈ្មោះ ទូច ជាអ្នកសួរចម្លើយអ្នកទោសស្រី ដល់ពេលសួរចម្លើយហើយ ពេលហូបបាយ គឺអ្នកសួរចម្លើយដទៃទៀតយកអ្នកទោសទៅទុកហើយទៅហូបបាយ ។ ចំពោះឈ្មោះ ទូច ហ្នឹងអត់ទៅហូបបាយទេ គាត់នៅរំលោភចាប់រំលោភចំពោះអ្នកទោសស្រីហ្នឹង ហើយដល់ពេលអ្នកដទៃទៀតមកពីហូបបាយវិញ អ្នកទោសស្រីនេះ គឺរាយការណ៍ប្រាប់អ្នកទោសដទៃទៀត ប្រាប់ថាឈ្មោះ ទូច នេះចាប់រំលោភ ថាម្នាក់គាត់ ។ ដល់ហើយ ទូច ឮដូច្នោះក៏ភ័យខ្លួនក៏រត់ឡើងលើដំបូលផ្ទះ ហើយលោតមកដី តែលោតមកចំពោះខ្សែ ភ្លើង គឺឈ្មោះ ទូច នោះមិនបានស្លាប់ ក៏អ្នកនៅតាមការពារចាប់យកមកដាក់នៅក្នុងមន្ទីរស-២១ វិញ ។ នេះសូមបញ្ជាក់តែប៉ុណ្ណឹង ។

**ស៖** សូមអរគុណ ។ តើលោកមានបានមើលឃើញផ្ទាល់ទេ អំពីការចាប់ឈ្មោះ ទូច នេះ?

**ឆ៖** បាទ, ចំពោះការចាប់អ្នកទោសឈ្មោះ ទូច នេះ គឺខ្ញុំមិនបានឃើញផ្ទាល់ទេ ខ្ញុំបានក៏នាំគ្នាជាមួយព័ទ្ធទាំងអស់ និយាយរួម គឺអ្នកនៅក្នុងមន្ទីរស-២១ នេះ គឺនាំគ្នាព័ទ្ធចាប់ទាំងអស់គ្នា ។ ម្ល៉ោះហើយការចាប់ គឺអាចចាប់បាន គឺដឹងថាចាប់បាន ។

**ស៖** តើនៅពេលដែលលោកធ្វើការនោះ ពេលហ្នឹងមានន័យថា អ្នកសួរចម្លើយហ្នឹងបានរំលោភស្ត្រីនោះហើយ មែនទេ?

**ឆ៖** បាទ,គឺបានរំលោភស្ត្រីនោះហើយ ស្ត្រីនោះក៏រាយការណ៍ប្រាប់អ្នកសួរចម្លើយដទៃទៀត ។ ឈ្មោះ ទូច នោះខឹងក៏យកថ្នាំទៅច្រកស្ត្រីនោះ តែក្រោយមកស្ត្រីនោះគេយកទៅដាក់នៅ-- មើលឲ្យពេទ្យមើល តែមិនដឹងជាបញ្ជូនទៅពេទ្យកន្លែងណាទេ ។ ខ្ញុំមិនបានដឹងច្បាស់ដែរ តែស្ត្រីនោះមិនដឹងជារស់ ឬស្លាប់យ៉ាងណាក៏ខ្ញុំមិនបានដឹង ។

[១១:១០:00]

**ស៖** សូមអរគុណ ។ ឥឡូវនេះ ខ្ញុំចង់សួរឡើងវិញម្តងទៀត សំណួរដែលខ្ញុំបានសួរពីមុននេះ ។ តើនៅពេលដែលមានរឿងចាប់រំលោភកើតឡើងនោះ លោកបានធ្វើការជាអ្នកសួរចម្លើយហើយមែនទេ?

**ឆ៖** បាទ, ចំពោះការចាប់រំលោភនោះ ពេលដែលខ្ញុំទើបចូលវាយអង្គុលីលេខ រៀនវាយអង្គុលីលេខនៅឡើយមិនទាន់បានសួរចម្លើយទេ ។

**ស៖** តើលោកមានបានដឹងទេថា នរណាគេជាអ្នកចេញបញ្ជាឲ្យចាប់ឈ្មោះ ទូច នោះ?

**ឆ៖** ចំពោះការបញ្ជាឲ្យចាប់ឈ្មោះ ទូច នោះ គឺជាមេក្រុមរបស់ខ្ញុំ ឈ្មោះ-- កាលនុំងមេក្រុមរបស់ខ្ញុំឈ្មោះ នន មិនដឹងឈ្មោះ កាក់ មិនដឹងទេ ខ្ញុំចាំមិនច្បាស់ដែរ ។ តែជាមេក្រុមរបស់ខ្ញុំហ្នឹង គឺគាត់បញ្ជាថា ឥឡូវឈ្មោះ ទូច ក្បត់ហើយចាប់រំលោភអ្នកទោស វារត់ឡើងលើផ្ទះថ្ម ហើយយើងនាំគ្នាព័ទ្ធ ។ អានេះ គឺជាបញ្ជារបស់មេក្រុមខ្ញុំ អង្កាល់នុំង គឺខ្ញុំចាំមិនច្បាស់ ឈ្មោះ អាចឈ្មោះ ប្រហែលជាឈ្មោះ ភាព មិនដឹង គឺខ្ញុំនៅវាយអង្គុលីលេខប្រហែលជាឈ្មោះ ភាព ។ ហៅ ច្រឹក ។

**ស៖** តើលោកមានបានដឹងទេថា ប្រធានក្រុមរបស់លោកហ្នឹងបានធ្វើ បានរាយការណ៍ទៅប្រធាន ស-២១ មុននឹងគាត់ធ្វើការចាប់ឈ្មោះ ទូច នោះដែរឬទេ?

**ឆ៖** បាទ, ចំពោះរឿងនេះ គឺខ្ញុំមិនបានដឹងច្បាស់ដែរ ស្រាប់តែគេចេញបញ្ជាឲ្យនាំគ្នាព័ទ្ធតែម្តង គឺខ្ញុំមិនបានដឹងច្បាស់ថា បញ្ជាពីត្រឹមណា ឬត្រឹមណា គឺខ្ញុំមិនបានដឹងច្បាស់ដែរ ។

**ស៖** ឥឡូវនេះ ខ្ញុំនឹងបន្តទៅមុខទៀត ទាក់ទងទៅនឹងការសួរចម្លើយផ្ទាល់របស់លោក ។ តើលោកមានស្គាល់ឈ្មោះ ស្រី អ៊ុំរឿន ទេដែលជាលេខានៅតំបន់២ នៅផ្នែកភូមិភាគពាយ័ព្យដែរឬទេ?

**ឆ៖** បាទ,ចំពោះសំណួរនេះ គឺខ្ញុំមិនបានចាំឈ្មោះអ្នកទោសស្រី ឬប្រុស គឺខ្ញុំមិនបានចាំ និយាយរួម គឺខ្ញុំមិនបានចាំ ភ្លេចអស់ហើយ អស់រយៈកាលយូរហើយ គឺមិនបានចាំ ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្ដ៖**

លោកប្រធាន តើលោកប្រធានអាចឲ្យខាងផ្នែកសោតទស្សន៍ដាក់ឯកសារបញ្ចាំងបានដែរទេ? ឯកសារគឺមានលេខ 0039714 ហើយសូមឲ្យដាក់បញ្ចាំងនៅទំព័រទី១៩ នៃឯកសារនេះ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងសោតទស្សន៍ ដាក់បញ្ចាំងនូវឯកសារដែលមានលេខ ERN0039714 នៅលើអេក្រង់ទូរទស្សន៍ដោយបង្ហាញតែទំព័រទី១៩ទេ ។

[១១:១៤:២៣]

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្ដ៖**

សម្រាប់អ្នកដែលមិននិយាយភាសាខ្មែរ មានលេខ-- ភាសាអង់គ្លេសមានលេខ 00233835 ។ សូមឲ្យផ្នែកសោតទស្សន៍បញ្ចាំងនូវឯកសារនេះ គឺនៅទំព័រទី១៩ ។

**សួរដោយលោកស្រី ស៊ីលឃីស្ទូត ហ្សីនស្ដ៖**

**ស៖** លោក ឡាច មាន នេះ គឺជាបញ្ជីឈ្មោះអ្នកទោស ហើយនិង គឺមានន័យថាអ្នកទោសដែលត្រូវបានសួរចម្លើយរួចហើយ ។ សូមលោកមើលឯកសារនេះ គឺមានចំណុចមួយនិយាយថាមានអ្នកទោសនោះមកពីភាគពាយ័ព្យ ដែលគាត់ឈ្មោះ ស្រី អឿន ហើយនៅខាងស្ដាំដៃ នៅកូឡោនខាងស្ដាំដៃហ្នឹងកន្លែងឈ្មោះអ្នកសួរហ្នឹង គឺឈ្មោះ ឡាច មាន ។ តើលោកមានចាំថា លោកមានបានសួរចម្លើយអ្នកទោសនេះដែរឬទេ?

**ឆ៖** ចំពោះចម្លើយនេះ គឺចំពោះរូបខ្ញុំមិនបានចាំទេ ខ្ញុំមិនបានចាំថា ខ្ញុំសួរចម្លើយដោយផ្ទាល់ក៏មិនដឹង គឺខ្ញុំភ្លេចអស់ចំពោះការនេះ គឺខ្ញុំទទួលក៏បាន ក៏មិនទទួលក៏បាន គឺខ្ញុំមិនអាចថា សន្និដ្ឋានថាខ្ញុំសួរឬក៏អត់ ក៏ខ្ញុំមិនហ៊ានទទួលដែរ ព្រោះថាវាជាកាលនោះ វាភ្លេចអស់បាត់ មិនដឹងជាឈ្មោះណាឈ្មោះណីគឺមិនបានចាំ ។ ម្ល៉ោះហើយខ្ញុំសុំមិនឆ្លើយថា ខ្ញុំសួរមែនឬក៏អត់ គឺខ្ញុំមិនបាន --សុំថាមិនឆ្លើយ ។

**ប្រធានអង្គជំនុំ៖**

តំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមពីរ អស់ពេលហើយ ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្ដ៖**

លោកប្រធាន តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំសួរនូវសំណួរចុងក្រោយមួយបានទេទាក់ទងទៅនឹងឯកសារអម្បាញ់មិញនេះ?

**ប្រធានអង្គជំនុំ៖**

មួយសំណួរចុងក្រោយណ៎ា?

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្ត៊ី៖**

**ស៖** នៅលើឯកសារដដែលនេះ ប៉ុន្តែខាងផ្នែកសោតទស្សន៍បានដកចេញហើយ ខ្ញុំចង់បង្ហាញនូវទំព័រទីមួយនៃឯកសារនេះឲ្យខាងសាក្សីគាត់បានមើល ចំណងជើងឯកសារនេះ គឺមាននៅទំព័រទីមួយ គឺឯកសារហ្នឹងឯងនៅទំព័រទីមួយហ្នឹង គឺមានលេខ ERN00039714 ។ លោក ឡាច មាន តើលោកអាចអានចំណងជើងឯកសារនេះបានដែរឬទេ?

[១១:១៨:៣៤]

**ឆ៖** បាទ, គឺខ្ញុំអាចអានបាន ។ ឈ្មោះដើម ឈ្មោះប្រែ នាទី ចាស់ ថ្មី ផ្នែក ថ្ងៃចាប់ ភូមិភាគ បូព៌ា គន់ ឈិន, សារ៉ុម ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្ត៊ី៖**

អ្វីដែលខ្ញុំចង់ឲ្យលោកអានហ្នឹង គឺឲ្យអានពាក្យដំបូងគេ ដែលមាននៅបន្ទាត់ទីមួយ ខាងឆ្វេងដៃ គឺពាក្យដំបូងគេបង្អស់នោះ ។

**ឆ៖** ក្រុមក្តៅ អានបាន ក្រុមក្តៅ ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្ត៊ី៖**

សូមអរគុណលោក ឡាច មាន សម្រាប់ការឆ្លើយតបសំណួររបស់ខ្ញុំ ហើយសូមអរគុណ លោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះសូមប្រគល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការសួរដល់សាក្សីរូបនេះ ។ ប្រសិនបើមានសំណួរ សូមអញ្ជើញ ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី៖**

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន និងសូមគោរពលោកប្រធាន សូមគោរពលោកចៅក្រមជាតិ និងអន្តរជាតិ និងសូមគោរពអង្គសវនាការទាំងមូល ។

**ស៖** លោក ឡាច មាន លោកបានជម្រាបលោកតុលាការថា មុនមកភ្នំពេញ លោកជាយោធាស្រុក១២ កំពង់ត្រឡាចលើ ដែលឥឡូវហៅថា ស្រុកសាមគ្គីមានជ័យ ។ តើលោកនៅតែរក្សាពាក្យនេះដដែល ឬក៏លោកកែប្រែ?

**ឆ៖** បាទ, ចំពោះចម្លើយរបស់ខ្ញុំជាយោធាស្រុកគឺខ្ញុំរក្សានូវចម្លើយនេះដដែល ព្រោះខ្ញុំកាលនោះគេដកចេញពីទ័ពស្រុកមក គឺពិតប្រាកដ គឺខ្ញុំចេញពីទ័ពស្រុកកំពង់ត្រឡាចលើ ។

**ស៖** សូមអរគុណ ។ លោកបានជម្រាបតុលាការទៀតថា នៅគុកព្រៃកត្នោតតាខ្មៅ គេឲ្យអ្នកទោសស្រោចបន្លែនិងធ្វើតុទូ ។ តើលោកនៅតែរក្សាពាក្យនេះដដែលឬក៏យ៉ាងម៉េច? សូមលោកបញ្ជាក់។

**ឆ៖** បាទ, ចម្លើយនេះ គឺខ្ញុំនៅរក្សាដដែល ព្រោះកាលដែលខ្ញុំចូលដំបូង គឺខ្ញុំចូលមកពេលយប់ព្រលឹម ពេលយប់ប្រហែលជាម៉ោងប្រាំពីរបានគេនាំខ្ញុំយកទៅដាក់នៅតាខ្មៅ ។ ពេលនោះគឺខ្ញុំ ព្រឹកឡើងគេឲ្យខ្ញុំនាំអ្នកទោសទៅយាមអ្នកទោស ទៅមើលអ្នកទោសដំបូង ទៅយាមឲ្យអ្នកទោសដើរស្រោចបន្លែមានដាំស្ពៃ ស្ពៃក្តោប ដាំខាត់ណា ខាត់អី មាត់ស្ទឹងតាខ្មៅហ្នឹង ហើយគឺខ្ញុំនៅយាមកន្លែងហ្នឹង គឺខ្ញុំនៅរក្សាដដែល គឺជាដំបូងបំផុត បង្អស់ ដែលខ្ញុំនៅកន្លែងហ្នឹង ។

**ស៖** សូមអរគុណ ។ លោកបានឮពីម្សិលមិញហើយ តាឌុច អះអាងថា គាត់លម្អៀងទៅរកស្រុកកំពង់ត្រឡាចលើ ។ តើលោកជឿពាក្យនេះដែរឬទេ?

**ឆ៖** ចំពោះសម្តីជនជាប់ចោទឈ្មោះ ឌុច ថាសំអាងគាត់មានមោទនភាពចំពោះស្រុកកំពង់ត្រឡាចលើ គឺសម្តីរបស់គាត់ គឺខ្ញុំមិនអាចសន្និដ្ឋានបានថា គាត់ជាការពិត ឬជាការមិនពិតទេ អានេះគឺខ្ញុំមិនអាចសន្និដ្ឋានបាន ។

**ស៖** អរគុណ ។ សូមលោកបញ្ជាក់បន្តិចមើល តើនីរសាររបស់ តាឌុច នេះមានប៉ុន្មាននាក់មកពីស្រុកកំពង់ត្រឡាចលើ? ហើយមានប៉ុន្មាននាក់មកពីកំពង់ឆ្នាំង? និងប៉ុន្មាននាក់មកពី៧០៣? សូមលោកបញ្ជាក់ ។

**ឆ៖** បាទ, ចំពោះនីរសាររបស់ថាឈ្មោះ ឌុច គឺខ្ញុំមិនបានស្គាល់ផង ស្គាល់ឈ្មោះគាត់ទេ ខ្ញុំស្គាល់តែមុខ ឃើញតែគាត់ឌុបម៉ូតូ ឬជាដើរជាមួយ តាឌុច គឺខ្ញុំមិនដែលស្គាល់ឈ្មោះម្នាក់ក៏ខ្ញុំមិនដែលស្គាល់សោះ មិនដឹងជាមកពីខាងណា ឬមកពីខាងណា គឺខ្ញុំមិនស្គាល់ទេ ព្រោះខ្ញុំគ្រាន់តែស្គាល់តែមុខទេ បើនីរសាររបស់គាត់ នេះជាចម្លើយរបស់ខ្ញុំ ។

**ស៖** សូមអរគុណ ។ អង្កាល់លោកនៅ *ប៉េហ្ស៊ី* តើ *ប៉េហ្ស៊ី* ឬក៏ ប៉េអេស មានកំផែងជុំវិញទេ?

**ឆ៖** បាទ, អង្កាល់ណោះ គឺមានកំផែង មានរបង គេចាក់ជារបងថ្មប្រហែលជាលិចក្បាល ហើយមានដោតជាអំបែងដបជុំវិញនៅតាមកំផែង ។

**ស៖** សូមអរគុណ ។ អ៊ីចឹងនៅ ប៉េហ្ស៊ី មានអគារសម្រាប់ដាក់អ្នកទោសប៉ុន្មានអគារ?

**ឆ៖** ចំពោះអគារដាក់អ្នកទោសប៉ុន្មាន គឺខ្ញុំមិនបានដឹងច្បាស់ទេ ព្រោះខ្ញុំគេឲ្យយាមតែអគារមួយតែមួយកន្លែងទេ អង្កាល់ណោះ គឺខ្ញុំទើបមកពីតាខ្មៅ មិនដែលស្គាល់ មិនដែលដឹងថា អ្នកទោស គេយ៉ាងម៉េចអីយ៉ាងម៉េច គឺគេឲ្យយាមតែមួយកន្លែង ដល់ម៉ោងមកហូបបាយ ចេញពីហូបបាយសម្រាកមួយសន្ទុះ មកដល់ម៉ោងទៅយាមទៀត ម្ល៉ោះហើយយាមតែមួយកន្លែងហ្នឹង មិនដឹងជាអគារប៉ុន្មាន ឬប៉ុន្មាន គឺខ្ញុំមិនបានទទួលដឹង ។

**ស៖** អ៊ីចឹង បើលោកមិនបានដឹងអគារទាំងអស់នោះ អ៊ីចឹងអគារដែលលោកយាមមួយនោះ តើមានប៉ុនអគារនៅទួលស្លែងឬទេ?

[១១:២៥:០០]

**ឆ៖** បាទ, ចំពោះអគារនៅកន្លែងនោះគឺមិនបានមានអគារប៉ុនអគារទួលស្លែងទេ គឺអគារដូចផ្ទះថ្មយើងធម្មតា ហើយមូល ផ្ទះអគារនោះគឺមូលជុំវិញឥតមានជ្រុងទេ ។

**ស៖** សូមអរគុណ ។ ពីម្សិលមិញលោកបានឆ្លើយជូនតុលាការថា លោកស្គាល់ច្បាស់គុកដាំផេង បើស្គាល់ច្បាស់សូមលោករៀបរាប់ពីរឿងគុកដាំផេងហ្នឹងជូនតុលាការបន្តិចមើល វាយ៉ាងម៉េច?

**ឆ៖** បាទ, ចំពោះការគុកដាំផេងនេះគឺ ពេលដែលខ្ញុំសម្រាកពីការងារមក គេចេញពីកន្លែងយាមអ្នកទោសក្នុងផ្ទះហ្នឹងមកខាង កន្លែងគុកដាក់ដាំផេង ហ្នឹងគឺមានអក្សរ-- រោងទៅក្រោមបន្តិចហើយក្នុងនោះគឺមានដាក់សរសេរអក្សរថា យកឈាម-- អាហ្នឹងគេ អ្នកនៅក្នុងហ្នឹងជាមួយគេថា នេះជាអក្សររបស់ ដាំផេង មានអារឈាមសរសេរជាអក្សរដាក់នៅតាមជញ្ជាំងក្នុងខាងក្រោមហ្នឹង នៅបន្ទប់ក្រោមនេះគេៗនាំខ្ញុំដើរមើលតាមហ្នឹង ។

**ស៖** សូមអរគុណ ។ អ៊ីចឹងនៅ *ប៉េហ្ស៊ី* តើផ្ទះដែលលោកហូបបាយនៅកន្លែងណា?

**ឆ៖** បាទ, ចំពោះនៅ *ប៉េហ្ស៊ី* កន្លែងសេដ្ឋកិច្ចហូបបាយគឺនៅខាងក្រៅរបង *ប៉េហ្ស៊ី* ហ្នឹង មិនដឹងជាខាងណា ខាងជើងខាងត្បូង កាលណោះគឺខ្ញុំមិនបានស្គាល់ច្បាស់ មិនចាំ វាវង្វេងមិនដឹងខាងណាខាងត្បូង ខាងជើងទេ ព្រោះនៅខាងក្រៅរបងមានថ្នល់មួយធំហ្នឹងចេញទៅលើផ្សារថ្មី ។ ម្ល៉ោះហើយហូបពីខាងនោះថ្នល់ របង មិនដឹងខាងជើងហ្នឹង-- ផ្លូវហ្នឹងទៅផ្សារថ្មី ទៅជើង ឬទៅកើតទៅលិចទេ

ខ្ញុំមិនបានចាំទេ ព្រោះអង្កាល់នោះខ្ញុំនៅមិនស្គាល់ច្បាស់ ។ វង្វេង ។

**ស៖** អ៊ីចឹងសូមលោកបញ្ជាក់តទៅទៀត កាលនៅ *ប៉េហ្ស៊ី* ហ្នឹង ផ្ទះតាឌុច ដែលជាថា លោកថាគាត់អ្នកដឹកនាំនៅហ្នឹង តើផ្ទះ តាឌុច នោះនៅកន្លែងណា?

**ឆ៖** ចំពោះផ្ទះតាឌុច គឺខ្ញុំអត់បានស្គាល់ទេ មិនដឹងគាត់នៅឯណាទេ ឃើញតែគាត់មកម្តងម្កាល តែកាលណោះគឺមិនបានសួរ-- គាត់មិនដែលសួរទៅផង ឃើញតែម្តងគាត់ ដែលខ្ញុំឃើញឈ្មោះ ឌុច ហ្នឹង ។ ឃើញអ្នកគេចាស់ៗគេថា “នោះបងមកប្រធានអាហ្នឹង ឌុច មកហើយហ្នឹង” ។ គាត់បើកឡានទៅតែម្តង ម៉្លោះហើយគឺខ្ញុំមិនដែលដឹងថាផ្ទះគាត់នៅកន្លែងណាទេ ។ ទៅញ៉ែកញាប់គឺឈ្មោះ ចាន់ ហ្នឹង ឃើញទៅញ៉ែកញាប់កន្លែងហ្នឹង ។

[១១:២៨:១៦]

**ស៖** សូមអរគុណ ។ ពេលលោកធ្វើការនៅស-២១មណ្ឌលភ្នំពេញ មជ្ឈមណ្ឌលភ្នំពេញ លោកបានត្រូវអនុញ្ញាតឲ្យចេញទៅទស្សនាភាពយន្តដែលថតអំពីទស្សនកិច្ចរបស់ ប៉ុល ពត នៅចិន និងនៅកូរ៉េ ទេ លោកដែលបានចេញទៅមើលទេ?

**ឆ៖** ចំពោះការចេញទៅមើលនៅភាពយន្ត គឺបានចេញទៅមើលម្តង គឺគាត់ដាក់ឡានចេញទៅមិនដឹងជាទៅខាងណាទេ ចេញទៅមើលម្តងនៅមិនដឹងខាងណាទេ ខ្ញុំមិនស្គាល់ដែរ មិនដឹងទៅលិច មិនដឹងទៅកើតទេ ចេះទៅមើលចំនួនម្តងក្នុងកន្លែងរោងភាពយន្តគេហ្នឹង ។ ចេញទៅមើលបានម្តង ហើយនិងទៅទស្សនកិច្ចនៅតំបន់២៥ម្តង ។

**ស៖** សូមអរគុណ ។ អ៊ីចឹង លោកបានទៅទស្សនាថែមទៀតទេ នៅពេលដែលសៀកចិនមកលេងក្នុងរយៈពេលបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃហ្នឹង គឺមានសៀកចិនមកលេងនៅភ្នំពេញហ្នឹង តើលោកគេបានអនុញ្ញាតឲ្យលោកចេញទៅមើលទេ?

**ឆ៖** បាទ,ចំពោះសៀកចិនមកលេងនៅក្រុងភ្នំពេញនេះ គឺខ្ញុំនៅកងការពារនៅឡើយទេ គឺខ្ញុំមិនបានចេញទៅមើលទេ ឮតែគេនិយាយថា សៀកមកលេងៗ ។ គេទៅមើល ខាងក្រុមគេទៅមើល គេបានទៅមើល តែចំពោះខ្ញុំគឺរវល់ការងារ កំពុងភារកិច្ចកំពុងយាម គឺមិនបានទៅមើលទេ ។

**ស៖** សំណួរតទៀត លោកនៅតែអះអាងថា គុកទួលស្លែងមានអគារធំៗបី អ៊ីចឹងមែនទេ លោកនៅតែអះអាងអ៊ីចឹងមែនទេ?

**ឆ៖** ចំពោះអគារធំៗបីហ្នឹង គឺខ្ញុំនៅទទួលអះអាងថា បី មានបីជ្រុង ។ ជ្រុងមួយជ្រុងទៅត្បូង មួយជ្រុងកណ្តាល មួយជ្រុងខាងជើង ។

**សៈ** សូមអរគុណ តើលោកនៅតែអះអាងថា អ្នកទោសស្រីៗ គេឃុំនៅអគារកណ្តាលអ៊ីចឹង មែនទេ?

**ឆ៖** ចំពោះស្រីៗដែលខ្ញុំឃើញភាគច្រើននៅខាងការិយាល័យតូច ខាងមុខអគារធំកណ្តាលហ្នឹង គឺខ្ញុំដើរទៅឃើញៗអ្នកទោសស្រីៗនៅទីនោះ ។

**សៈ** តើគេឃុំអ្នកទោសស្រីៗនេះ រហូតដល់ថ្ងៃ២ ឬថ្ងៃ៣ មករា ១៩៧៩ មែនឬទេ?

[១១:៣១:១៥]

**ឆ៖** បាទ, ចំពោះសំណួរនេះគឺខ្ញុំមិនបានបញ្ជាក់ថា នៅដល់ជិតថ្ងៃ២ ថ្ងៃ៣ នោះទេ គឺខ្ញុំមិនបានដឹងថា អ្នកទោសស្រីនៅដល់ឆ្នាំណា ថ្ងៃណា គឺខ្ញុំមិនបានដឹងទេ ព្រោះអ្នកសួរចម្លើយ-- ដែលខ្ញុំមកនៅសួរចម្លើយហើយ គឺខ្ញុំមិនបានដឹងទេ ព្រោះខ្ញុំមិនបានដើរជិតអគារនោះទេ ។

**សៈ** សូមអរគុណ ។ លោកថា មានអ្នកទោសម្នាក់ឆ្លើយដាក់ វន វ៉េត តើអ្នកទោសនោះឈ្មោះអី? សូមលោកបញ្ជាក់ផង ។

**ឆ៖** បាទ, ចំពោះសំណួរនេះ គឺខ្ញុំមិនបានចាំទេ ចំពោះអ្នកទោសដែលឆ្លើយដាក់ឈ្មោះ វន វ៉េត ព្រោះអស់រយៈកាលយូរហើយ គឺខ្ញុំមិនបានឆ្លើយទេ តែអ្នកដែលឆ្លើយនោះគឺនៅក្នុងមន្ទីរក-១ ឬក-២ កាលហ្នឹង ខ្ញុំចាំបានថា នៅនឹងក-១ ឬក-២ ។

**សៈ** បាទ, សូមអរគុណ ។ ខ្ញុំសូមសួរលោក ឲ្យលោកបញ្ជាក់ ឯកសារ D2.6/2 ERN0014 5587 ចុះថ្ងៃទី ៧ ខែ១២ ឆ្នាំ២០០៦ ជាភាសាខ្មែរ លោកបានឆ្លើយទៅសហ--

*(អ្នកបកប្រែ៖ លោកចៅក្រមប្រធានទាន! សូមឲ្យលោក ការ សាវុត្ថ អានERN ណាំប៊ីរ ម្តងទៀតទាន គាត់អានរៀងញាប់បន្តិច ។)*

**សៈ** ERN00145587 នៅក្នុងឯកសារនេះ លោកបានឆ្លើយទៅសហព្រះរាជអាជ្ញាថា ឯកសារសួរចម្លើយ ពេលខ្លះខ្ញុំយកទៅឲ្យឌុចផ្ទាល់ តែពេលសវនាការនេះ លោកឆ្លើយថា មិនដែលយកចម្លើយអ្នកទោសទៅឲ្យ ឌុច ផ្ទាល់ទេ ។ ដូច្នេះ ចម្លើយពីរនេះ ខ្ញុំយល់ឃើញថាដូចជាផ្ទុយគ្នា តើលោកយកចម្លើយនៅសហព្រះរាជអាជ្ញា ឬមួយក៏យកចម្លើយនៅពេលសវនាការនេះ? សូមលោកបញ្ជាក់ ។

**ឆ៖** ចំពោះចម្លើយរបស់ខ្ញុំថា យកឯកសារទៅឲ្យឈ្មោះឌុច គឺខ្ញុំមិនដែលបានយកទៅឲ្យឈ្មោះឌុច ផ្ទាល់ទេ គឺខ្ញុំដែលតែបញ្ជូនតាមរយៈមេពួក គឺខ្ញុំឆ្លើយ-- សួរចម្លើយចប់គឺឲ្យទៅប្រធានពួករបស់ខ្ញុំគឺមានឈ្មោះ ហេង, ឈ្មោះ កាក់, ឈ្មោះ ណាន, ឈ្មោះ នន ហ្នឹង ។

**ស៖** អរគុណ។ អ៊ីចឹងបានសេចក្តីថាលោកបដិសេធចោលនូវចម្លើយដែលលោកឆ្លើយចំពោះមុខព្រះរាជអាជ្ញាកាលពីថ្ងៃទី៧ ខែ១២ ២០០៦ ហើយលោកទទួលស្គាល់ចម្លើយដែលលោកឆ្លើយនៅពេលសវនាការនេះ ។ អ៊ីចឹងមែនទេ?

[១១:៣៤:៣០]

**ឆ៖** បាទ, ចំពោះចម្លើយរបស់ខ្ញុំឆ្លើយនៅពេលនេះគឺ ខ្ញុំឆ្លើយទៅតាមការនឹកឃើញរបស់ខ្ញុំដែលខ្ញុំបានធ្វើនៅពេលនោះ តែចំពោះចម្លើយខ្ញុំនៅសវនាការពីកាលនោះគឺខ្ញុំឆ្លើយយ៉ាងម៉េចៗ គឺខ្ញុំមិនបានចាំហើយមិនបានដឹងថា ខ្ញុំឆ្លើយយ៉ាងម៉េចទេ គឺខ្ញុំអត់បានចាំទេ ។ ម្ល៉ោះហើយខ្ញុំមិនអាចទទួលបាន ។

**ស៖** សូមអរគុណ ។ បន្ទាប់មកទៀត លោកអ្នកដើរយាមតាមបន្ទប់ខាងក្នុង អាហ្នឹងមុនលោកទៅសួរចម្លើយ លោកថា មិនដែលឃើញ តាឌុច ធ្វើទារុណកម្មអ្នកទោស ហើយក៏មិនដែលឃើញតាឌុច វាយសម្លាប់អ្នកទោសនោះទេ ។ តើលោកនៅរក្សាចម្លើយនេះដដែលឬយ៉ាងណា?

**ឆ៖** បាទ, សួរចម្លើយនេះគឺខ្ញុំនៅរក្សាដដែល គឺខ្ញុំមិនដែលឃើញគាត់ដើរចូលខាងក្នុង ឬដើរទៅសម្លាប់អ្នកទោសណា គឺខ្ញុំមិនដែលឃើញគាត់ធ្វើដោយផ្ទាល់ ។ ម្ល៉ោះហើយខ្ញុំរក្សានូវចម្លើយនេះជាការពិត ។

**ស៖** សូមអរគុណ ។ លោកបានឆ្លើយបញ្ជាក់ជូនតុលាការហើយថា លោកជាអ្នកដើរយាម និងធ្លាប់សួរចម្លើយ លោកថា មិនដែលឃើញមានវិន័យសន្តិបាល១០(ខ)នោះទេ ទោះបីនៅបន្ទប់សួរចម្លើយក្តី នៅបន្ទប់ដែលលោកយាមក្តី តើនៅរក្សាចម្លើយនេះដដែលឬយ៉ាងណា?

**ឆ៖** ចំពោះចម្លើយនេះគឺខ្ញុំនៅរក្សាដដែល ព្រោះអង្គាល់នោះគឺខ្ញុំមិនដែលឃើញថា គេសរសេរជាវិន័យយ៉ាងម៉េច ដាក់ប៉ុន្មានថា-- ដាក់ថាយ៉ាងម៉េចៗនៅតាមជញ្ជាំង ឬតាមកន្លែងសួរ-- បន្ទប់សួរចម្លើយយ៉ាងម៉េចៗ គឺខ្ញុំអត់ដែលមានសំណេរសរសេរនៅក្តារខៀនហ្នឹងដែរ ។

**ស៖** សូមអរគុណ ។ លោកក៏បានឆ្លើយបញ្ជាក់ជូនតុលាការដែរថា ពេទ្យនៅស-២១ គ្មានពេទ្យជាស្ត្រីទេ ហើយក៏គ្មានពេទ្យជាកុមារពេទ្យនោះដែរ ។ អ៊ីចឹង លោកនៅរក្សាចម្លើយនេះដដែលឬយ៉ាងណា?

**ឆ៖** ចំពោះពេទ្យដែលដើរមើលអ្នកទោស គឺខ្ញុំមិនដែលឃើញពេទ្យស្រីដើរមើលអ្នកទោសទេ តែចំពោះពេទ្យនៅកន្លែងណាមួយមានស្រី គឺខ្ញុំមិនដែលឃើញ គឺខ្ញុំមិនដឹងទេ តែចំពោះពេទ្យដែលដើរមើលអ្នកទោស គឺខ្ញុំឃើញតែពេទ្យប្រុសៗដើរមើលអ្នកទោស ។ ម្ល៉ោះហើយខ្ញុំនៅរក្សាចម្លើយនេះដដែល ។

**ស៖** សូមអរគុណ ។ មួយទៀត លោកថា តាំងពីលោកធ្វើការនៅស-២១ លោកមិនដែលបានទទួលបញ្ជាស្អីពី តាឌុច ទេ តើអ៊ីចឹងមែនទេ?

[១១:៣៧:៤១]

**ឆ៖** បាទ, ចំពោះចម្លើយនេះ គឺខ្ញុំមិនដែលបានបញ្ជាគាត់ បញ្ជាផ្ទាល់មែន គឺខ្ញុំនៅរក្សាចម្លើយនេះដដែល ។

**ស៖** ពេលលោករៀនសួរចម្លើយ គឺឈ្មោះ កាក់ ជាអ្នកបង្រៀនលោកពីរបៀបសួរចម្លើយ ។ តើឈ្មោះ កាក់ នេះមានធ្វើទារុណកម្មអ្នកទោស ដើម្បីបង្ហាញលោកជាបទពិសោធន៍ក្នុងការរៀនសូត្រឬទេ?

**ឆ៖** ចំពោះការរៀនសួរចម្លើយ គឺឈ្មោះ កាក់ នេះគឺមានធ្វើទារុណកម្មដូចខ្ញុំថា ។ គាត់មានវ៉ៃនឹងរំពាត់ រវៃនឹងខ្សែភ្លើងឆក់ត្រចៀកហ្នឹង គឺគាត់មានធ្វើ ។ តែចំពោះការណែនាំអប់រំឲ្យខ្ញុំធ្វើគឺមិនទាន់មានទេ ព្រោះការយើងសួរទៅសុទ្ធតែអ្នកសួរហើយ ចេះចាប់ចំណុចសង្កត់លើអ្នកទោស ដើម្បីឲ្យអ្នកទោសឆ្លើយ វ៉ៃថែម ។ ម្ល៉ោះហើយការរៀនពិសោធន៍ ធ្វើទារុណកម្មគឺមាន ។

**ស៖** សូមអរគុណ ។ លោកធ្វើការនៅស-២១ តើលោកដឹងទេ លោកស្គាល់ទេ អ្នកធំណាឈ្មោះអី ដែលនៅពីលើ តាឌុច ទៀតនេះ? សូមលោកបញ្ជាក់ តើលោកស្គាល់លោកបញ្ជាក់?

**ឆ៖** ចំពោះនៅស-២១ ដែលធំជាងជនជាប់ចោទឈ្មោះ ឌុច ទៀតនោះ គឺខ្ញុំមិនបានដឹងទេ ។ ដឹងថាគាត់ហៅបងៗ តែមិនដឹងបងណា បងប៉ុល, បងខៀវ, បងអី បងណា គឺខ្ញុំចាំមិនបានច្បាស់ដែរ ស្រេចគាត់ហៅថាបងៗ ពេលបង្រៀននយោបាយម្ដងៗ ។ អាហ្នឹងជានយោបាយរបស់គាត់ ក៏គាត់បង្រៀនថា អ៊ីចឹងហើយតែឲ្យខ្ញុំដឹងថា អ្នកណាបញ្ជាពីលើគាត់ ឬមេធំនៅលើមន្ទីរស-២១ គឺខ្ញុំអត់បានដឹងទេ ដឹងតែគាត់ម្នាក់ បន្ទាប់មកមានឈ្មោះ ហ៊ី, ឈ្មោះ ចាន់, ឈ្មោះ ប៉ុន ឈ្មោះអី ជាកម្មាភិបាលធំៗនៅទីនោះ ។

**ស៖** អរគុណ ។ អ៊ីចឹងលោកមានស្គាល់ សុន សេន ច្បាស់ទេ?

**ឆ៖** ចំពោះ សុន សេន គឺខ្ញុំបានឃើញច្បាស់ ពេលគាត់មកបង្រៀននយោបាយនៅ-- នយោ-បាយខាងក្រៅសាលា-- ខាងក្រៅមន្ទីរស-២១ គឺគាត់មកបង្រៀននយោបាយជាញឹកញាប់ដែរ ប្រហែលជាបីឬបួនដងដែរតាំងពីខ្ញុំបានទៅនៅស្នួរចម្លើយ ។

**ស៖** សំណួរចុងក្រោយ តើលោកពេញចិត្តនឹងមុខងារភារកិច្ចរបស់លោកនៅស-២១ ឬទេ?

**ឆ៖** ចំពោះការបំពេញភារកិច្ចនៅទីនោះគឺឲ្យខ្ញុំពេញចិត្តនឹងធ្វើ ឬក៏ស្រឡាញ់នឹងការងារនោះ គឺខ្ញុំអត់បានពេញចិត្តទេ ព្រោះការងារនៅកន្លែងនោះគឺចប់ចល់គ្មានដើរទៅណាបានមួយថ្ងៃឬចេញទៅក្រៅបានឲ្យសប្បាយចិត្ត ហើយការងារនោះគឺធ្វើ ភ័យខ្លាចខុស ខ្លាចស្លាប់ខ្លួន ដោយសារការធ្វើស្នួរចម្លើយទៅតែមិនត្រូវតាមការកំណត់របស់គេ ខុសខ្លាចខុស ។ ម្ល៉ោះហើយការរស់នៅទីកន្លែងនោះ គឺខ្ញុំភ័យជារៀងរាល់ថ្ងៃ មិនដឹងជាថ្ងៃណាខ្ញុំស្លាប់ដូចជាមេពួករបស់ខ្ញុំបន្តបន្ទាប់ទេក៏មិនដឹង ។ ម្ល៉ោះហើយខ្ញុំគ្មានពេញចិត្តនឹងការធ្វើនៅទីនោះទេ តែកានោះជាការចាត់តាំងជាការបញ្ជាពីថ្នាក់ ម្ល៉ោះហើយការដែលខ្ញុំរស់នៅទីនោះគឺខ្ញុំធ្វើតាមបញ្ជា តាមបទបញ្ជា ម្ល៉ោះហើយគឺខ្ញុំធ្វើទៅតាមបទបញ្ជាប៉ុណ្ណោះ ។

**ស៖** សូមអរគុណ ខ្ញុំសូមលោកបញ្ជាក់បន្តិចទៀត ។ លោកថា លោកមិនពេញចិត្តនឹងរបបនោះដែលឮថាមិនពេញចិត្តនឹងលោកធ្វើការងារនៅកន្លែងស-២១ នេះទេ ។ បើលោកមិនពេញចិត្ត ហេតុអីក៏លោកមិនរកមធ្យោបាយដើម្បីគេចរត់ចេញពីស-២១? សូមលោកបញ្ជាក់មើល ។

**ឆ៖** ចំពោះការដែលខ្ញុំរកមធ្យោបាយចេញពីមន្ទីរស-២១ គឺគ្មានមធ្យោបាយចេញរួចទេ មិនដែលទៅស្គាល់ទាក់ទងទៅអង្គភាពនៅកន្លែងណា អង្គភាពណាផ្សេងៗគឺខ្ញុំមិនដែលបានទៅទាក់ទង ម្ល៉ោះហើយរកមធ្យោបាយក៏រកមិនបានដែរ ។ ម្ល៉ោះហើយគឺខ្ញុំចេះតែទ្រាំនៅ ហើយខំធ្វើការឲ្យគេស្រឡាញ់ ឲ្យគេអាណិត ដើម្បីកុំឲ្យខ្លួនស្លាប់ កុំឲ្យខ្លួនលំបាកតែប៉ុណ្ណោះ ។

**ស៖** អ៊ីចឹងសូមលោកបញ្ជាក់បន្ថែមទៀត លោកមានដឹងទេ បុគ្គលិកស-២១ ដែលគេធ្វើការដូចលោកហ្នឹង ប្រហែលជាគេអត់ពេញចិត្តនឹងការងារដូចលោកដែរឬទេ?

**ឆ៖** ចំពោះអ្នកដទៃទៀតដែលស្នួរចម្លើយដែលធ្វើការជាមួយគ្នា តាមដែលខ្ញុំមើលខ្លះគេពេញចិត្ត ខ្លះប្រហែលជាមិនពេញចិត្តដូចខ្ញុំដែរការងារអស់នេះ ។ ខ្លះគេថា នឹកផ្ទះដល់ហើយ ចង់ទៅលេងម៉ែតែមិនដឹងជា-- អត់ហ៊ានសុំទៅទេ ខ្លាច ។ ម្ល៉ោះហើយមានអ្នកខ្លះនិយាយអ៊ីចឹង ចង់ទៅលេងផ្ទះម្តង ភូមិស្រុកមិនដឹងយ៉ាងម៉េចទេឥឡូវ ។ ម្ល៉ោះហើយ មានអ្នកខ្លះៗថា ទៅលេងអ្នកស្រុកបានការអីអ៊្នា ការងារគរគោកគរដីបំពេញភារកិច្ចជូនបក្ស ដើម្បីបក្សចម្រើន ។ អ្នកខ្លះនិយាយអ៊ីចឹង អ្នកខ្លះអ៊ីចុះ ។ ម្ល៉ោះ

ហើយមានអ្នកខ្លះជឿតាមបក្ស អ្នកខ្លះមិនជឿ ។ ម្ល៉ោះហើយមានអ្នកខ្លះស្រឡាញ់ អ្នកខ្លះមិនស្រឡាញ់ ជំនាន់នោះគឺមាន ។

**ស៖** សូមអរគុណ អ៊ីចឹងចំពោះអ្នកមិនស្រឡាញ់ ប្រហែលជាដូចលោកដែរ ចង់រត់ដែរតែមិនដឹងរត់ទៅណា អ៊ីចឹងមែនទេ?

[១១:៤៤:១៣]

**ឆ៖** បាទ, គឺអ៊ីចឹងមែន ចង់រត់ដែរ ចង់ចេញដែរ តែមិនដឹងចេញទៅខាងណា បើមិនស្គាល់ទីកន្លែង មិនស្គាល់អីផង ។

**លោក ការ សាវុត្ថ៖**

សូមអស់សំណួរ ហើយសូមអរគុណលោកប្រធាន ហើយសូមឲ្យមេធាវីអន្តរជាតិ ហ្វ្រង់ស្វ័រ បន្តសំណួរទៀត ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រូ ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រូ៖**

**ស៖** សូមអរគុណលោកប្រធាន ។ លោក មាន ខ្ញុំមិនមានសំណួរច្រើនសម្រាប់លោកទេ ។ លោកទើបតែនិយាយថា ការងាររបស់លោកនៅស-២១ គឺជាការងារធុញថប់ តើលោកដឹងទេថាមានមនុស្សប៉ុន្មាននាក់ដែលស្លាប់នៅស-២១ នោះ? ក្នុងពេលដែលលោកធ្វើការនៅទីនោះ?

**ឆ៖** ចំពោះសំណួរនេះ គឺខ្ញុំមិនបានដឹងថា ស្លាប់ប៉ុន្មានអីប៉ុន្មានទេ តែខ្ញុំដឹងថាអ្នកដែលនៅក្នុងទីនោះជាមេរបស់ខ្ញុំ គឺដឹងបាត់ថាមេៗរបស់ខ្ញុំគឺមានឈ្មោះ ប៉ូច, ឈ្មោះ ផូ, ឈ្មោះ ប៉េង, ឈ្មោះ ហេង, ឈ្មោះ កាក់, ឈ្មោះ នន ។ នេះគឺបាត់ឈ្មោះហើយ ម្ល៉ោះហើយគឺខ្ញុំសូមសន្និដ្ឋានថាពួកនេះប្រហែលជាស្លាប់ បានជាបាត់ខ្លួននៅក្នុងមន្ទីរស-២១ ។

**ស៖** តើលោកដឹងទេ ថាលោកមិនអាចចេញពីស-២១ ហើយរស់រានមានជីវិតបានទេ?

**ឆ៖** ចំពោះការដែលខ្ញុំរស់នៅមន្ទីរស-២១នេះ គឺខ្ញុំមិនកំណត់ខ្លួនឯងទេ ថាខ្ញុំរស់បានយ៉ាងណានោះទេ គឺខ្ញុំធ្វើការមិនដឹងជាថ្ងៃណា ខ្លួនបាត់ដូចគេដែរទេក៏មិនដឹង គឺខ្ញុំមិនអាចកំណត់បានទេ ។

**ស៖** ខ្ញុំមិននិយាយអំពីអ្នកយាម ឬក៏អ្នកសួរចម្លើយទេ ខ្ញុំសួរលោកអំពីជនរងគ្រោះ អ្នកដែលជាប់ឃុំនៅកន្លែងនោះ តើលោកដឹងទេថាតើអ្នកជាប់ឃុំទាំងអស់នោះត្រូវបានគេបញ្ជូនចេញ ឬក៏ចេញ

ពីគុកដោយរស់រានមានជីវិតដែរឬទេ?

**ឆ៖** ចំពោះអ្នកទោសដែលនៅក្នុងស-២១ នេះ គឺខ្ញុំមិនអាចសន្និដ្ឋានបានថារស់ឬស្លាប់យ៉ាងណាដែរ គឺខ្ញុំមិនអាចដឹងទេ ព្រោះការងារសម្ងាត់របស់បក្សគេ គឺមិនអាចឲ្យដឹងទេ ឃើញតែគេ-- កាលពីខ្ញុំនៅកងការពារនៅឡើយ ឃើញតែគេដឹកឡានចេញ ដឹកឡានចូល ។ ម៉្លោះហើយមិនដឹងគេដឹកយកទៅខាងណា គឺខ្ញុំមិនបានដឹងទេ ។

**ស៖** ហើយលោកមិនដែលបានសួរ ឬក៏ព្យាយាមចង់ដឹងថា តើអ្នកទោសទាំងអស់ហ្នឹងគេយកទៅណា ហើយគេយកទៅធ្វើអីទេ?

**ឆ៖** ចំពោះការសួរចង់ដឹងអ្នកទោសហ្នឹងគេយកទៅណាៗ គឺចង់ដឹងដែរតែមិនដឹងសួរអ្នកណាមិនដឹងសួរអ្នកណា បើមិនដឹងថាគេយកទៅណា ។ ម៉្លោះហើយចេះតែឆ្ងល់តែខ្លួនឯង “គេសួររួច គេយកទៅណាអ្នកទោស?” ម៉្លោះហើយចេះឆ្ងល់តែខ្លួនឯងតែប៉ុណ្ណោះ ។ អត់ប៊ានសួរពី-- សួរគេ មេជាមេ ជាមេក្រុម មេពួកអីមិនប៊ានសួរគេ ខ្លាចថាយើងចង់ដឹងពីការងារសម្ងាត់របស់បក្សគេ ។ ម៉្លោះហើយខ្លាចមិនប៊ានសួរទេ ។ ម៉្លោះហើយពេលនោះ គឺការងារអីអ្នកនឹងគឺធ្វើតែការងារនោះ ដឹងតែធ្វើការងារតែប៉ុណ្ណោះ ។

**ស៖** អ៊ីចឹងហើយ ខ្ញុំអាចនិយាយថា នៅក្នុងរយៈពេលដែលលោកធ្វើការនៅស-២១ ទាំងស្រុងនោះ លោកមិនដែលព្រួយបារម្ភ ហើយលោកមិនដែលឆ្ងល់ថាតើអ្នកទោសទាំងអស់នោះជួបជោគវាសនាយ៉ាងដូចម្តេច? តើលោកគិតអ៊ីចឹងដែរឬទេ? លោកមិនដែលព្រួយបារម្ភថាតើអ្នកទោសនុ៎ងនឹងក្លាយទៅជាយ៉ាងម៉េច ឬក៏ជួបលទ្ធផលយ៉ាងម៉េចចុងក្រោយនោះ?

**ឆ៖** បាទ, ជាចម្ងល់របស់ខ្ញុំ គឺខ្ញុំមិនបានដឹងទេ តែចម្ងល់របស់ខ្ញុំគឺគ្រាប់តែបានឆ្ងល់តែខ្លួនឯងតែប៉ុណ្ណោះ ហើយចំពោះជោគវាសនារបស់អ្នកទោសនោះគឺមិនដឹងជាយ៉ាងណា គឺខ្ញុំមិនបានដឹងទេ គ្រាន់តែឆ្ងល់តែខ្លួនឯងថា អ្នកទោសប្រហែលជាស្លាប់ ជាអារម្មណ៍របស់ខ្លួនឯងតែប៉ុណ្ណោះទេ គឺបក្សរបស់គេកាលនោះ គឺតឹងរ៉ឹងម៉ឺងម៉ាត់ដាច់ខាត និយាយពីដាច់ខាតកម្ទេចខ្មាំងៗ ។ ម៉្លោះហើយ គេមិនអាចទុកអ្នកទោសឲ្យរស់រានមានជីវិតទេ ។ ព្រោះប្រហែលតែអ្នកសួរចម្លើយនៅក្នុងទីនោះ អ្នកការពារនៅក្នុងទីនោះធ្វើការ ខ្លួនមើលទៅដូចមិនឃើញខុសផងក៏អាចគេចាប់ដែរ ។ ម៉្លោះហើយមិនទុកចិត្តសូម្បីតែកងការពារខ្លួនឯង ឬជាអ្នកសួរចម្លើយខ្លួនឯងនេះក៏មិនទុកចិត្តក្នុងខ្លួនដែរថា ខ្លួននឹងរស់រានមានជីវិតរហូតក៏មិនទុកចិត្តដែរ ។

[១១:៥១:០៨]

**ស៖** អ៊ីចឹងហើយលោកបានដឹងច្បាស់ណាស់ថា នយោបាយរបស់បក្សនោះ គឺដើម្បីកម្ទេចខ្មាំង។ ដូច្នេះហើយលោកបានដឹងច្បាស់ថា អ្នកទាំងអស់ដែលត្រូវបានគេឃុំខ្លួននៅស-២១ នឹងត្រូវបានគេកម្ទេច តើអ៊ីចឹងមែនទេ?

**ឆ៖** ចំពោះការកម្ទេច ឬមិនកម្ទេច គឺខ្ញុំមិនបានដឹងទេ តែជាការសន្និដ្ឋានរបស់ខ្ញុំ គឺគេអាចកម្ទេច ឬក៏យកទៅណាក៏ខ្ញុំមិនដឹងដែរ ។ អានេះជាយោបល់របស់ខ្ញុំ គឺមិនអាចឆ្លើយបាន ។

**ស៖** ដូច្នេះមានន័យថា លោកមិនដែលបាននិយាយជាមួយអ្នកសួរចម្លើយផ្សេងទៀតទេ។ ក្នុងចំណោមអ្នកសួរចម្លើយ លោកមិនដែលនិយាយអំពីបញ្ហាទាំងអស់ហ្នឹងទេ ។ តើមែនទេ?

**ឆ៖** បាទ, ចំពោះការទាក់ទង ចំពោះអ្នកសួរចម្លើយដទៃទៀត រឿងផ្សេងៗគឺមិនបាននិយាយពីបញ្ហានេះទេ គឺអត់មាននិយាយគ្នាពីរឿងអ្នកទោសគេយកទៅណាទៅណី គឺមិនដែលបាននិយាយគ្នាទេ។

**ស៖** ទោះបីជានៅពេលល្ងាចក្រោយពីធ្វើការងារមួយថ្ងៃមក គឺថាដែលលោកជួបជុំគ្នាក្នុងចំណោមអ្នកសួរចម្លើយ ទោះជាពេលសម្រាកអ៊ីចឹងក៏មិនដែលនិយាយសួរនាំគ្នាពីរឿងហ្នឹង តើមែនឬទេ?

**ឆ៖** បាទ, ចំពោះរឿងហ្នឹង គឺមិនដែលនិយាយគ្នាទេ បើនិយាយរួមគឺខ្លាចគ្នាទៅវិញទៅមក មិនទុកចិត្តគ្នា លែងទុកចិត្តគ្នាឯង ខ្លាចគ្នាឯងរាយការណ៍ថា ឯងនិយាយនេះគឺមើលងាយបក្សគេ ឬថាយ៉ាងម៉េចៗ ។ ម្ល៉ោះហើយជាសតិអារម្មណ៍របស់ខ្ញុំ គឺអង្គាល់នោះលែងទុកចិត្តគ្នាឯងទាំងអស់ ។ ម្ល៉ោះហើយខំប្រឹងតែធ្វើការងារខ្លួនឯងដើម្បីរស់ខ្លួនឯងតែប៉ុណ្ណោះ ។

**ស៖** តើលោកធ្លាប់ដឹងអ្នកសួរចម្លើយម្នាក់ដែលថាមានឈ្មោះ ប្រាក់ ខន ដែរឬទេ?

**ឆ៖** អ្នកសួរចម្លើយឈ្មោះ ប្រាក់ ខន ប្រហែលជាមាន ។ ឈ្មោះ ខន មិនដឹងជាគាត់ឈ្មោះ ប្រាក់ ខន ឬ ឈ្មោះ ខន ឈ្មោះអី ខន ក៏មិនដឹងដែរ ។ ឈ្មោះ ខន គឺមាន ឈ្មោះ ផុន ក៏មានដែរ ។

**ស៖** តើលោកបានជួបគាត់ដែរឬទេ?

**ឆ៖** ចំពោះឈ្មោះ ខន ខ្ញុំដូចជាដែលបានជួបគាត់ម្តងដែរ គាត់នៅមជ្ឈមណ្ឌលឯកសារ គឺឃើញតែមុខគាត់ តែមិនដែលបានជួបគាត់ ឬនិយាយស្តីជាមួយគាត់ គឺអត់បានដែរ និយាយជាមួយគ្នាទេ គ្រាន់តែឃើញគាត់ដើរ ។ ឃើញគាត់រាងកំបុតស្លឹកត្រចៀកមួយចំហៀង ហើយថាបែបឈ្មោះ ខន ហើយហ្នឹងមើលទៅ ។ ដល់ហើយ គឺគ្រាន់តែសង្ស័យទេ មិនបានថាឈ្មោះ ខន ហ្នឹងបាននិយាយគ្នាពិតប្រាកដទេ ខ្ញុំឃើញគាត់ជិះឡានដើរទស្សនកិច្ច ។ ហើយដែលទៅបឹងជើងឯកអីជាមួយគ្នា ឃើញគាត់ដើរជាមួយ

ជនបរទេស ម្ល៉ោះហើយ គឺដឹងថាឈ្មោះហ្នឹងឈ្មោះ ខន ហើយ តែមិនដែលបាននិយាយគ្នាទេ ។

**ស៖** ខ្ញុំសួរលោកថាតើលោកបាននិយាយ ឬក៏សន្ទនាជាមួយគាត់ដែរទេនៅពេលដែលលោកធ្វើការនៅស-២១? គឺក្នុងចំណោមអ្នកសួរចម្លើយនោះ ជាពិសេស ធ្លាប់និយាយជាមួយលោក ប្រាក់ ខន ដែរឬទេកាលណោះ?

**ឆ៖** បាទ ចំពោះឈ្មោះ ប្រាក់ ខន នេះគឺខ្ញុំមិនដែលបាននៅក្រុមជាមួយគ្នា ហើយមិនដែលបានទាក់ទងគ្នា ម្ល៉ោះហើយមិនសូវបាននិយាយគ្នាទេ ។

**ស៖** តើលោកបានធ្វើអ្វីជាពិសេសនៅក្នុងឆ្នាំ១៩៧៩ តើលោកអាចប្រាប់យើងខ្ញុំបានទេនៅពេលដែលកងទ័ពវៀតណាមចូលមកដល់?

**ឆ៖** បាទ, ចំពោះពេលកងទ័ពចូលមកដល់ ខ្ញុំមិនបានដឹងថា គេធ្វើយ៉ាងណាទេ តែពេលដែលឮសូរអាវុធផ្ទុះប្រាវៗ ខ្ញុំយកអ្នកទោសទៅទុកម៉ោងដប់មួយ ។ យកអ្នកទោសទៅទុកហើយ ពេលទៅហូបបាយទៅដល់កន្លែងបាយមិនទាន់បានហូបបាយផង ផ្ទុះអាវុធប្រាវៗ ម្ល៉ោះហើយតា ឌុច ជិះម៉ូតូវ៉ាំមកមកដល់ប្រាប់ឲ្យខ្ញុំទៅយកអាវុធកន្លែងឃ្លាំង ។ ពេលនោះនាំគ្នាទៅយកអាវុធកន្លែងឃ្លាំង អត់បានហូបបាយទេ ទៅយកអាវុធនៅឃ្លាំងហើយទៅត្រៀមនៅតាមមាត់លូទឹកស្អុយត្រៀមរហូត បាយក៏អត់ហូបទល់ប្រហែលជាម៉ោងបី បានចេញពីកន្លែងនេះទៅ ចេញទៅអត់ហូបបាយរហូត ។ រហូតដល់ដើរពីម៉ោងបីទៅ ដើរបណ្តើរស៊ីបបណ្តើរ ដើរបណ្តើរខ្លាចយួនបណ្តើរ។ ម្ល៉ោះហើយដើរមិនបានលឿនប៉ុន្មានទេ ។ ដល់ឃើញបាយតាមរោងបាយមិនដឹងជាកន្លែងណាទេ ឃើញមានរោងបាយរោងអី រកហូបក៏អ្នកខ្លះថា មកកុំហូបទៅទៀត ។ ទៅទៀតអត់ហូបបាយរហូតដល់ទៅដល់បឹងទំពុន នាំគ្នាទៅនៅពួនតាមបឹងទំពុន នៅតាមគុម្ពចេក ខ្លាចវៀតណាមកាលណោះ ។ រហូតដល់ម៉ោងប្រាំពីរយប់ចេញពីបឹងទំពុនឆ្លងតាមបឹង ហែលកាត់បឹងឆ្លងទៅត្រើយខាងលិចមិនដឹង ខាងកើតខាងត្បូងមិនដឹង ខ្ញុំមិនចាំច្បាស់ដែរមិនស្គាល់ទិស ។ នាំគ្នាហែលឆ្លងទៅ បានគេនាំឆ្លងថ្នល់ជាតិលេខ៤ អ្ហាថ្នល់ជាតិលេខ-- ប៉ុន្មានទេ ថ្នល់ជាតិទៅលិច-- ទៅជើងអ៊ីចឹងទៅ ធ្លាក់ទៅលើក្អែកពង ជិតឧដុង្គអ៊ីចឹងទៅ ។ ទៅដល់ទៅរៀបកងនៅត្រពាំងព្រីង គេហៅ ត្រពាំងព្រីង ថ្នល់ពង ខាងលិចស្បែកពស់ ។

[១១:៥៨:៥១]

**ស៖** អ៊ីចឹង គឺថាលោកពិនិត្យឃើញថា ពេលខ្លះលោកអាចនៅចងចាំរឿងរ៉ាវមួយចំនួន លោកបានប្រាប់យើងថា លោកបានយកអ្នកទោសយកទៅដាក់កន្លែងឃុំវិញ ។ តើនៅមានអ្នកទោសទេនៅ

ពេលនោះ នៅដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ មានអ្នកទោសនៅទីហ្នឹងមែនទេ?

**ឆ៖** បាទ, ថ្ងៃនោះគឺមានអ្នកទោស ខ្ញុំនៅសួរចម្លើយនៅឡើយ ព្រោះខ្ញុំថាមិនដឹងអ្នកទោសនៅច្រើន ឬតិច គឺខ្ញុំមិនបានដឹងទេ ដឹងថាឈ្មោះដែលខ្ញុំសួរចម្លើយនោះគឺនៅ ។ ខ្ញុំពេលដែលយួនចូលហ្នឹង ខ្ញុំយកចម្លើយអ្នកទោសយកទៅទុកៗដើរទៅហូប ដល់ពេលទៅដល់តុបាយ គឺផ្ទុះអាវុធ ។ តាឌុច ជិះម៉ូតូមកនាំគ្នាទៅយកអាវុធ នាំគ្នាទៅយកអាវុធ រត់ទៅយកអាវុធទាំងអស់គ្នា ។ ម្ល៉ោះហើយអ្នកទោស គឺនៅមានតែត្រង់នៅមានប៉ុន្មាន តិច ឬច្រើន ខ្ញុំមិនបានដឹងទេ ។

**ស៖** តើអ្នកណាជាអ្នកទោសដែលលោកបានសួរចម្លើយ ហើយយកទៅទុកវិញនោះឈ្មោះអ្វី?

**ឆ៖** បាទ, ចំពោះឈ្មោះអ្នកទោសដែលខ្ញុំយកទៅទុក ហើយខ្ញុំយកមកសួរចម្លើយនៅពេលនោះ គឺមិនដឹងជាឈ្មោះអីទេ ខ្ញុំមិនបានចាំទេ វាភ្លេចអស់ហើយ ។ ចម្លើយអ្នកទោសមិនដឹងជាឈ្មោះអី ខ្ញុំមិនបានចាំ ។

**ស៖** លោកបានជម្រាបប្រាប់អង្គសវនាការកាលពីម្សិលមិញថា លោកបានសួរចម្លើយអ្នកទោសទាំងអស់ហ្នឹងតែបួននាក់ទេ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, ជាចម្លើយរបស់ខ្ញុំ គឺជាការត្រឹមត្រូវ ព្រោះកាលណោះ គឺខ្ញុំសួរដោយផ្ទាល់ម្នាក់ឯង ខ្ញុំមិនថា កំណត់ថាបួននាក់គត់ ឬប៉ុន្មានាក់នោះ គឺខ្ញុំមិនកំណត់ទេ គឺខ្ញុំមិនច្បាស់ ។ ដូច្នេះ គឺខ្ញុំសន្និដ្ឋានថាប្រហែលជាបួន ឬប្រាំនាក់ ខ្ញុំថាអ៊ីចឹង ។

**ស៖** តើលោកខ្លួនឯងផ្ទាល់ហ្នឹងមានប្រើអំពើហិង្សាអ្វីទេ ទៅលើអ្នកទោសនោះនៅពេលដែលលោកសួរចម្លើយ? តើលោកមានបានធ្វើទារុណកម្មទៅលើអ្នកទោសអស់ទាំងនោះដែរឬទេ?

**ឆ៖** ចំពោះការធ្វើទារុណកម្ម ចំពោះខ្លួនខ្ញុំផ្ទាល់ គឺមិនទាន់បានមានសិទ្ធិធ្វើមានសិទ្ធិវ៉ៃទេ ព្រោះខ្ញុំមិន-- បើនិយាយរួមមិនហ៊ានវ៉ៃទេ គ្រាន់តែសួរៗ បើកំហ្ញើញគឺអាច មានកំហ្ញើញថា រកវ៉ៃ រកជេរអ៊ីចឹងមាន ។ ជេរ ប្រើអំពើហិង្សាជាជេរ ជារកវ៉ៃ រកអីអ៊ីចឹង គឺមាន តែចំពោះការវ៉ៃតប់ គឺខ្លួនឯងផ្ទាល់គឺមិនទាន់បានមានការវ៉ៃតប់ ។ ហើយពេលដែលអ្នកទោសមិនឆ្លើយខ្លាំង យើងសួរបួនប្រាំថ្ងៃមិនបានឆ្លើយអ៊ីចឹង បានខ្ញុំតែប្រាប់ តាហ៊ី មិនតេទេ តាហ៊ី គាត់ដើរមើលរាល់ថ្ងៃ ប្រាប់ម៉េចអ្នា តាហ៊ី ដើរចូលមក“ម៉េចវាឆ្លើយអត់?” “អត់ឆ្លើយទេ” “អត់ឆ្លើយសួរទៀតទៅ” ។ នេះជាចម្លើយជាសំណួរ ។ ហើយគាត់ដើរទៅហួសទៅ ស្អែកឡើងគាត់មកទៀត ។ “ឆ្លើយនៅអ្ហា?” “នៅទេបងអ្ហើយ” ។ ម្ល៉ោះហើយម្តងនេះ “មើល៍បើវាមិនឆ្លើយអ្អែងទៅកាច់រំពាត់ឲ្យអញ” ។ ម្ល៉ោះហើយមានតែការ មានតែប៉ុណ្ណឹង ការសួរ

ចម្លើយជាទារុណកម្មរបស់ខ្ញុំ គឺមិនទាន់បានប៉ាន់ធ្វើដោយខ្លួនឯងផ្ទាល់ផង ។

[១២:០៣:០៤]

**ស៖** លោកប្រធាន ខ្ញុំមានសំណួរចុងក្រោយមួយទៀត ។ លោកសាក្សី ថ្ងៃនេះតើលោកសោកស្ដាយទេ ដែលថាលោកបានធ្វើការងារនៅស-២១នោះ? តើលោកមានការសោកស្ដាយដែរឬទេ ដែលថាលោកបានបម្រើការនៅស-២១នោះ?

**ឆ៖** ចំពោះការបម្រើនៅស-២១នោះ គឺសោកស្ដាយ ហើយក៏សោកស្ដាយក្នុងការធ្វើនៅស-២១ គឺខ្ញុំមានការសោកស្ដាយណាស់ ដែលធ្វើជាអ្នកយាមគុកនៅទីនោះ លំបាកក៏លំបាក បើថានៅកងការពារវិញមួយយប់តាំងពីម៉ោងដប់ពីរទល់ភ្លឺ គឺដើររហូត ។ ម្ល៉ោះហើយលំបាកគ្មានពេលទំនេរនេះទេ ។ ដើរចួនកាលងោក១ ដើរងោកបុកជញ្ជាំងភឹងក៏មាន បុកសសរភឹងក៏មាន ម្ល៉ោះហើយធុញថប់សឹងថា ប្រេះទ្រូងហើយ ម្ល៉ោះហើយអន់ចិត្តនឹងខ្លួនឯងដែលធ្វើការងារមិនត្រឹមត្រូវតាមលក្ខណៈនេះ ។ ម្ល៉ោះហើយធ្វើការងារហ្នឹង វាតឹងតែងពេកអន់ចិត្តខ្លួនឯង ។ សោកស្ដាយដែលខ្លួនឯងមកនៅធ្វើការគ្មានពេលទំនេរគ្មានបានស្រួលដើរទៅណាស្គាល់ញាតិមិត្ត ស្គាល់មិត្រភក្ដិជិត ឬឆ្ងាយ ស្គាល់បងប្អូននៅទីណា១ មិនដឹងថា បងប្អូនគេបញ្ជូនទៅណាទៅនៅអង្គភាពណា ម្ល៉ោះហើយស្ដាយ មានការសោកស្ដាយណាស់ដែលខ្ញុំបាននៅស-២១ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណ លោកសាក្សី ។ លោកប្រធាន សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាចុងក្រោយនេះ អង្គជំនុំជម្រះផ្ដល់ឱកាសទៅជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់បន្ថែមចំពោះសក្ខីកម្មរបស់សាក្សីរូបនេះ ប្រសិនបើមាន ។ ប៉ុន្តែ អង្គជំនុំជម្រះសូមរំឭកសាក្សីថា មិនគប្បីធ្វើការកត់សម្គាល់ដោយសង្កត់ទៅលើសាក្សីថា ភ្ជាប់ខ្លួនមកឧក្រិដ្ឋកម្មនោះទេ ពីព្រោះសាក្សីអញ្ជើញមកនេះ គឺតាមសេចក្ដីត្រូវការ តាមនីតិវិធីដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្វះស្វែងរកដើម្បីស្វែងរកការពិត ។ អ៊ីចឹង គឺជាសាក្សីដែលត្រូវមកដោយបំពេញករណីយកិច្ច ក្នុងនាមពលរដ្ឋដែលបានដឹងរឿងហេតុពិតប្រាកដ ពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះយល់ឃើញថា ដែលចាំបាច់នៅក្នុងការកោះហៅមកឲ្យនិយាយផ្ដល់ព័ត៌មានប្រាប់ដល់អង្គជំនុំជម្រះ ។ ដូច្នេះ គឺលោកអាចធ្វើការកត់សម្គាល់ទៅការអ្វីដែលលោកយល់ឃើញ ប៉ុន្តែចៀសវាងនៅចំណុចដែលយើងបញ្ជាក់អម្បាញ់មិញនេះ ។

សូមអញ្ជើញ ។

[១២:០៦:៤៦]

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! ម្សិលមិញ ខ្ញុំបានសន្យាជាមួយនឹងលោកចៅក្រម ឡាវែន៍ ថាខ្ញុំនឹងទៅស្រាវជ្រាវឯកសារនៅបន្ទប់ឃុំឃាំងរបស់ខ្ញុំ គឺបញ្ជីសួរចម្លើយ ។ ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតជូនលទ្ធផលនៃការដែលខ្ញុំស្រាវជ្រាវ ដូចតទៅ៖

ឯកសារដែលសហចៅក្រមស៊ើបអង្កេតប្រគល់មកដល់ដៃខ្ញុំក្នុងសំណុំរឿងលេខ០០១ មាន២៣ទំព័រ ដែលមានលេខ ERN ដូចតទៅ ។ ដំបូងមួយក្រុមហ្នឹងមាន២០ទំព័រ គឺពីលេខ ERN 00006957 ដល់ 00006976 ។ មួយសំណុំទៀត មានតែពីរទំព័រទេគឺ 00040092 និង 00040093 ។ ហើយចុងក្រោយមានតែមួយទំព័រទេគឺ 00040220 ។ ក្នុងចំណោមឯកសារទាំង២៣ទំព័រ ដែលខ្ញុំបានស្រាវជ្រាវនេះ ខ្ញុំអត់ឃើញមានឈ្មោះមិត្ត កាក់ ជាអ្នកសួរចម្លើយអ្នកទោសទេ ក៏ប៉ុន្តែមានឈ្មោះមិត្ត មាន គឺ ឡាច មាន បីទំព័រ នៅលើទំព័រដូចតទៅ៖

ទីមួយ ឈ្មោះ មាន នៅទំព័រ 00040092 ត្រង់លេខរៀងទី៩ ។ ឡាច មាន សួរចម្លើយចប់នារីម្នាក់ឈ្មោះ គាំ លីន ហៅ រីន ជានារី អនុប្រធានផ្នែកព្យាបាលរបស់ព-១៧ ។ ទីពីរ បញ្ជាក់ថា មិត្ត ឡាច មាន បានសួរចម្លើយម្នាក់នៅលេខរៀង៣ ដែលជាប្រធាន-- ជាប្រជាជនចាស់សហករណ៍បឹងអណ្តែង តំបន់២៣ ។ ជនរងគ្រោះរូបនេះស្ថិតនៅក្នុងលេខរៀងទី៣ ទំព័រ 00006967 ។ ហើយទីបីមិត្ត ឡាច មាន បានសួរចម្លើយជនរងគ្រោះម្នាក់ឈ្មោះ ហាយ ជុត ប្រធានឃោសនាការតំបន់២៣ នៅត្រង់លេខរៀងទី៦ នៃទំព័រ 00006971 ។ សូមបញ្ជាក់ថា ទំព័រ ERN ជាន់គ្នា គឺ 00006971 និង 00006977 ដូចគ្នាទាំងស្រុង ។ ខ្ញុំស្រាវជ្រាវឃើញមិត្ត ឡាច មាន សួរចម្លើយមនុស្សបីនាក់ ដូចតទៅនេះ ។

សរុបមកនៅបុគ្គលិកមន្ទីរស-២១ ពិតជាមានកម្មាភិបាលម្នាក់សួរចម្លើយរបស់មន្ទីរស-២១មែនឈ្មោះ ឡាច មាន មែន ។ ក្នុងឯកសារ២៣សន្លឹកដែលខ្ញុំស្រាវជ្រាវនេះ ឃើញមានបីសន្លឹកហើយដែលមានឈ្មោះ ឡាច មាន ។ តើរឿងពិតវាយ៉ាងម៉េច? ខ្ញុំសុំទុកជូនអង្គជំនុំជម្រះសាលាដំបូងនេះ លោកវិភាគចុះ ។ ខ្ញុំមានជំនឿទាំងស្រុងលើសុភវិនិច្ឆ័យនៃអង្គជំនុំជម្រះក្នុងបញ្ហានេះ ដើម្បីរកការពិត ។ ខ្ញុំសុំចប់ប៉ុណ្ណេះ ដោយគោរព ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ការស្តាប់សក្ខីកម្មសាក្សីឈ្មោះ ឡាច មាន ក៏ដល់ទីបញ្ចប់ហើយ ។ ហើយស្របគ្នានៃការចប់នៃការស្តាប់សាក្សីនេះ ក៏ពេលវេលាត្រូវសម្រាកពិសាអាហារថ្ងៃត្រង់ដែរ ។ ហើយលោក ឡាច មាន អង្គជំនុំជម្រះអរគុណចំពោះលោកដែលបានអញ្ជើញមកផ្តល់សក្ខីកម្មតាមការកោះហៅរបស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ហើយស្ថានភាព និងទិដ្ឋភាពនៃការប្រឈមរបស់លោក ក្នុងនាមលោកជាសាក្សីចំពោះការឆ្លើយនឹងសំណួរជាច្រើន ពីអង្គជំនុំជម្រះនិងភាគីដែលមានសិទ្ធិនៅក្នុងការសួរដេញដោលនៅក្នុងសវនាការ ចំពោះលោកឃើញថាក៏មានការតឹងតែង។ ហើយហេតុផលមួយទៀតគឺ ដោយសាររឿងហេតុហ្នឹង វាកើតឡើងយូរឆ្នាំមកហើយនោះដែលប្រឈមនឹងការលំបាកចំពោះសាក្សី ។ ប៉ុន្តែការកត់សម្គាល់ឃើញថា ទោះបីប្រឈមយ៉ាងណា គឺសាក្សី អត់ធ្មត់នឹងការខិតខំក្នុងឆ្លើយតបនឹងសំណួររបស់អង្គជំនុំជម្រះ និងភាគីនៅក្នុងដំណើរការសវនាការនេះ ។

ហើយការសួរស្តាប់សក្ខីកម្មរបស់លោក គឺចប់ហើយ អ៊ីចឹងគឺ លោកអាចត្រឡប់ទៅផ្ទះវិញបានហើយ ។ ហើយមន្ត្រីតុលាការសម្របសម្រួលដល់សាក្សីរូបនេះ ជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីជូនគាត់ត្រឡប់ទៅលំនៅដ្ឋានរបស់គាត់វិញ ។

ហើយអង្គជំនុំជម្រះប្រកាសសម្រាកសម្រាប់ពិសាអាហារថ្ងៃត្រង់ គឺត្រឹមពេលនេះ ហើយអង្គជំនុំជម្រះនឹងបន្តដំណើរការសវនាការរសៀលនេះចាប់ពីម៉ោងមួយកន្លះតទៅ ។ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់មកកាន់សាលសវនាការវិញឲ្យបានមុនម៉ោងមួយកន្លះរសៀលនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១២:១៣នាទី ដល់ម៉ោង ១៣:៣៥នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ ហើយនីតិវិធីបន្តសម្រាប់សវនាការនៅរសៀលនេះគឺ អាននូវកំណត់ហេតុស្តាប់សក្ខីកម្មរបស់សាក្សីដែលបានធ្វើនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ។ ហើយសាក្សីទាំងនោះអង្គជំនុំជម្រះសម្រេចមិនធ្វើការកោះហៅគាត់

មកឱ្យផ្តល់សក្ខីកម្មផ្ទាល់ នៅចំពោះមុខអង្គជំនុំជម្រះ។ ហើយមួយទៀតបញ្ហានៃការអាននូវកំណត់ហេតុស្តាប់សក្ខីកម្មសាក្សី ដែលអង្គជំនុំជម្រះសម្រេចមិនកោះហៅគាត់ មកធ្វើសក្ខីកម្មចំពោះមុខអង្គសវនាការនារសៀលនេះ គឺអង្គជំនុំជម្រះសម្រេចឱ្យក្រឡាបញ្ជីសវនាការ អាននូវកំណត់ហេតុជាភាសាខ្មែរ ។ ដោយឡែកភាសាពីទៀតគឺ ភាសាបារាំង និងភាសាអង់គ្លេស ដោយមានហេតុផលការពិនិត្យរបស់អង្គជំនុំជម្រះទៅឃើញថាមិនស្របគ្នានូវចំណុចមួយចំនួន ហេតុដូច្នេះភាគីទាំងអស់សូមមានការចាប់អារម្មណ៍ គឺសូមស្តាប់នូវការបកប្រែដោយ ផ្ទាល់នាពេលអាននាពេលសវនាការនេះដោយក្រឡាបញ្ជីឆ្លងកាត់តាមការបកប្រែ ។

ដោយឡែក ការបកប្រែផ្លូវការគឺនឹងមានការកែសម្រួលនិងរៀបចំជូនភាគីជាក្រោយ ដោយផ្អែកតាមប្រតិចារឹកដែលយើងនឹងទទួលបានកត់ត្រានៅក្នុងអំឡុងពេលនៃការអានកំណត់ហេតុនាពេលនេះ ។ ដូច្នេះសូមភាគីជ្រាប ។

តទៅនេះ សូមអញ្ជើញលោកស្រី សែ កុលវុឌ្ឍី អាននូវកំណត់ហេតុស្តាប់សក្ខីកម្មសាក្សី ខៀវ ចេស ដែលមានឯកសារជាភាសាខ្មែរ D28/2 ហើយ ERN 00163636 រហូតដល់ 00163641 ។

**លោកស្រី សែ កុលវុឌ្ឍី៖**

“ការិយាល័យសហចៅក្រមស៊ើបអង្កេត សំណុំរឿងព្រហ្មទណ្ឌលេខ០០២ ចុះថ្ងៃទី១៤ ខែ សីហា ឆ្នាំ២០០៦ ។ លេខស៊ើបសួរ០០១ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០៧ ។

ឆ្នាំ២០០៧ ខែវិច្ឆិកា ថ្ងៃទី២៨ នៅវេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក នៅខេត្តកំពង់ឆ្នាំង ។

យើង ស៊ឹម សុរិយ៉ា ជាអ្នកស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ ដែលត្រូវបានចាត់ដោយដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ ។

បានឃើញ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ។

បានឃើញវិធាន២៤, ២៨ និង៦០ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ។

បានកត់ត្រាយកចម្លើយពីឈ្មោះ ខៀវ ចេស ហៅ ពៅ ជាសាក្សី ដែលបានផ្តល់ព័ត៌មាន ស្តីពីអត្តសញ្ញាណដូចខាងក្រោម៖

ឈ្មោះ ខៀវ ចេស ឈ្មោះហៅក្រៅ ពៅ កើតនៅឆ្នាំ១៩៦៣ ។

ជននេះបានប្រកាសថា ខ្លួនមិន ចេះអាន និងសរសេរភាសាខ្មែរតែចេះស្តាប់ និងចេះនិយាយភាសាខ្មែរ ។ ហេតុដូច្នេះច្បាប់ដើមនៃកំណត់ហេតុនេះត្រូវបានសរសេរជាភាសាខ្មែរ ។

យើងបានជូនព័ត៌មានរួចហើយដល់ជននេះថា ការស្ដាប់យកចម្លើយនេះ នឹងត្រូវថតយកសំឡេង ឬរូបភាព ។

ជននេះបានប្រាប់យើងពីទំនាក់ទំនងរបស់គេជាមួយនឹងជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ថា គ្មាន ។

ជននេះបានស្បថ ស្របតាមបញ្ញត្តិនៃវិធាន២៤ នៃវិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញ ។

យើងបានប្រាប់ដល់ជននេះ អំពីសិទ្ធិមិនធ្វើសក្ខីកម្ម ប្រឆាំងនឹងខ្លួនឯងស្របតាមបញ្ញត្តិនៃវិធាន ២៨ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ និងមានសិទ្ធិ មានមេធាវីការពារផងដែរ ។

សួរ-ឆ្លើយ៖

ស.ស៖ អក្សរកាត់របស់ឈ្មោះ សឹម សុរិយ៉ា ជាអ្នកស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ ។
ស.ស៖ ដំបូងសូមលោកនិយាយអំពីប្រវត្តិរបស់លោកមុនឆ្នាំ១៩៧៥?
ខ.ចៈ ជាអក្សរកាត់របស់សាក្សី ខៀវ ចេស ។
ខ.ចៈ កាលណោះ ខ្ញុំនៅជាមួយឪពុកម្ដាយរស់យ៉ាងខ្វះខាត ជាមួយបងប្អូនក្រោយមកឪពុកម្ដាយ ស្លាប់អស់ទៅ បងប្អូនប្អូននាក់ ប្រុសបីស្រីមួយ ។
ស.ស៖ មុនពេលមានចលនាបដិវត្តន៍ចូលមកដល់ភូមិតើមានបញ្ហាអ្វីទេ?
ខ.ចៈ បញ្ហាដែលពិបាកលូនក្រាប គេចគ្រាប់បែកទម្លាក់ បែកបងប្អូន សង្គ្រាមកាន់តែរាលដាល ឡើង ពីមួយថ្ងៃទៅមួយថ្ងៃ ចេញមើលគោទាល់តែរើសពេលវេលាឲ្យបានត្រឹមត្រូវ ។ ខ្ញុំបានទៅនៅ វត្ត បងទីពីរខ្ញុំបួស សង្គ្រាមរាលដាលឡើងៗ ។ ក្រោយឆ្នាំ១៩៧៥ បងខ្ញុំក៏សឹកនៅផ្ទះ ។ ខ្ញុំបាន ទៅនៅមន្ទីរកុមារ ។ ពេលអាមេរិកាំងទម្លាក់គ្រាប់បែកនោះមានឆេះផ្ទះអ្នកភូមិ រួចមកគេឲ្យចូល កុមារជាក្រុមៗ ។ ប្រធានសហករណ៍ជាអ្នកឲ្យចូល ។ ហើយចេះតែចូលតាមគេទៅ ។ សហ-ករណ៍ខ្ញុំមិនដឹងរៀបចំនៅពេលណាទេ ចេះតែឮគេថាគាត់ជាប្រធានសហករណ៍ ។ ក្រោយរំដោះ ហើយបានកើតឡើង ក្រុមសាមគ្គី ក្រោយមកទើបមានសហករណ៍ ។ អ្នកដឹកនាំសហករណ៍ គឺអ្នកដែលធ្លាប់ធ្វើ និងចាត់ចែង នៅក្នុងភូមិនោះតែម្ដង ។
ស.ស៖ យ៉ាងម៉េចបានជាមេភូមិនៅក្នុងរបប លន់ នល់ បានក្លាយទៅជាប្រធានសហករណ៍ទៀតមិន មានការប្រែប្រួល?

[១៣:៤២:០០]

ខ.ចៈ ខ្ញុំមិនទាន់ដឹងដែរ មិនទាន់ដឹងបែងចែកច្បាប់ទម្លាប់ទេ ។ ពេលចូលកុមារខ្ញុំមានអាយុប្រហែល ១៥ឆ្នាំ ។ មេសហករណ៍ឈ្មោះ ចួន ប៉ុន ប្រធានកុមារ ឈ្មោះ ធឿង ។

ស.សៈ ក្រោយរំដោះ ១៧ មេសា ប៉ុន្មានថ្ងៃទើបគេហៅទៅភ្នំពេញ?

ខ.ចៈ នៅយូរខែដែរ ប្រហែលជិតកន្លះឆ្នាំ ទើបគេរើសកុមារធំៗឲ្យមកកាស់គល់នៅព្រៃធំ ។ បន្ទាប់មកប្រធានសហករណ៍គេឲ្យជ្រើសកុមារធំៗមកដេកនៅកំពង់ត្រឡាច រួចមកផ្សារក្រោមហើយគេឲ្យឡើងឡានទៅភ្នំពេញ ។ កុមារទាំងនោះខ្ញុំមិនដឹងថាមានប៉ុន្មានទេ មានឡានសេអឹមសេដឹកប្រហែល ប្រាំឡាន ។ អ្នកមកដឹកកុមារ និងអ្នកមកទទួល ខ្ញុំស្រពិចស្រពិលមិនចាំច្បាស់ទេ ។

ស.សៈ ពេលដែលទៅភ្នំពេញគេយកទៅណា?

ខ.ចៈ គេឲ្យទៅយាមផ្ទះថ្ម គេឲ្យទៅបឹងទំពុនចិញ្ចឹមជ្រូក ដាំបន្លែ រួចទើបគេឲ្យទៅរៀននៅស្ទឹង ព្រែកត្នោត រៀនបោកគ្រាប់បែក ក្រាប លូន អស់រយៈពេលជិតមួយឆ្នាំនៅទីនោះ។ ខ្ញុំតាមខ្ញុំស្មាន មានកុមារប្រហែលជា៥00នាក់ ។ អ្នកទាំងនោះមិនដឹងមិនពីណាទេ បាចទឹកក៏យ៉ាប់ អ្នកបង្រៀនគឺគណៈសាលា ។ អ្នកបង្រៀនមិនចាំថាមកពីណាទេ សុទ្ធតែទ័ពមិនដឹងនៅកងណាទេ ។ អ្នកយកមកពីកំពង់ ឆ្នាំង គេហៅតា សម្រែង ហៅ តាចាន់ ។ ពេលបង្រៀនគាត់មិនមែនជាអ្នកបង្រៀនទេ ។ អ្នកធំៗក្រៅពី កុមារគេមានបង្រៀនក្បាច់ចាក់កាំបិត ក្បាច់កាប់ ការ៉ាតេ ។

ស.សៈ តើពេលរៀនមានអ្នកធំៗណាមកមើលទេ?

ខ.ចៈ មានអ្នកធំៗមក តែមិនចាំឈ្មោះ ។

ស.សៈ ក្រោយពីនៅទីនោះមួយឆ្នាំ ហើយគេបញ្ជូនទៅទីណាទៀត?

ខ.ចៈ បន្ទាប់គេបង្រៀននៅទីនោះមួយឆ្នាំមក គេបញ្ជូនមកផ្ទះរៀបចំ ប៉ាឡូ ទៅផ្ទះអ្នកខ្លះអរ ។ ពេលឡានទៅផ្ទះស្រាប់តែដឹកចូលទៅគុកទួលស្លែងតែម្តង ។ គេឲ្យចិញ្ចឹមជ្រូកគេឲ្យដាំខ្ទឹមបារាំងមួយខែ នៅខាងលិចទួលស្លែងតែម្តង ។ ទើបគេឲ្យមកយាមជាមួយអ្នកធំៗ ហើយគេឲ្យទៅយាមអ្នកទោសស្រាលៗ ។ អគារខាងជើងខាងលើបង្អស់មួយបន្ទប់ម្នាក់ឯង ។

[១៣:៤៥:០៥]

ពេលដល់ដំបូង ឃើញគេបណ្តើរអ្នកទោសចងមុខ ពួកខ្ញុំមួយឡានគិតថា គេយកពួកខ្ញុំទៅដាក់គុកហើយ ហើយគេបរឡានគេចទៅតាមរបង ។ គេឲ្យខ្ញុំស្នាក់នៅខាងលិចក្រោយទួលស្លែងក្រៅរបងត្រង់ផ្លូវទំពូង ។ ពេលស្នាក់នៅគេមិនទាន់ឲ្យយាមទេ ក្រោយមកគេឲ្យយាមជាមួយ

អ្នកធំៗដើរតាមគេប្រហែល៣សប្តាហ៍ ។ បន្ទាប់មកក្រោយ ពីធ្វើបន្ទប់តូចៗហើយគេឲ្យយាមខាងលើបង្អស់ ។ ខ្ញុំមិនស្គាល់ អ្នកធំទាំងនេះអស់ទេ ។ គេប្រាប់ត្រូវយាមយ៉ាងម៉េច? ពេលដឹងអ្នកទោសសុំបត់ជើង សុំទឹកឲ្យទឹកពេលឆ្អេះយកទឹកបាញ់ឲ្យអ្នកទោសងូត ។ ពេលដឹងការងារនេះអស់ហើយ គេឲ្យទៅយាមខាងលើ ។ ក្នុងមួយយប់យាមពីរវេន ថ្ងៃពីរវេន ។ មួយក្រុមយប់មួយក្រុមថ្ងៃ ។ យាមខាងលើបានបីខែ ។ ពេលអ្នកទោសបត់ជើងខ្ញុំយកកែសឲ្យអ្នកទោសបត់ជើង ហើយយកទៅបោះចោល ។ ពេលអ្នកទោសកខ្វក់យកទឹកបាញ់ងូតឲ្យ ។ ចូលបាញ់ក្នុងបន្ទប់ រួចជូតឲ្យស្អាត ។ អ្នកទោសទាំងនោះដាក់ខ្នោះរហូត ពេលឈឺជើងមួយចំហៀង ដោះដាក់មួយចំហៀងទៀត ។ អ្នកទោសបាយដូចគ្នាដែរ មានព្រឹក ល្ងាច ម្ហូបអន់ជាងកម្លាំងទ័ព ។ អ្នកទោសទាំងនោះ ជាអ្នកមកពីកងចល័តក្រសួង មន្ទីរ រោងចក្រ និងកងទ័ព នេះគឺក្នុងឆ្នាំ ១៩៧៦ ។

ក្រៅពីនោះ ហ៊ុយ ជាអ្នកដើរត្រួតពិនិត្យឲ្យយើងមើលស្អាតឬមិនស្អាត បាយទឹកគ្រប់គ្រាន់ឬអត់ ។ បើសួរអ្នកទោសថា មិនគ្រប់គ្រាន់គេយកទៅកសាង ។ ខ្ញុំធ្លាប់ឃើញ ហ៊ុយ យកមនុស្សចេញ ខ្ញុំមិនប៉ានសួរទេ ហើយមានអ្នកផ្សេងចេញចូលមកយកអ្នកទោសដែរ តែខ្ញុំមិនស្គាល់ឈ្មោះ ។ ហើយមានអ្នកយកអ្នកទោសចូល អ្នកទាំងនោះជាកូនចៅរបស់ ហ៊ុយ ។ ខ្ញុំស្គាល់ ធី ពេលហូបបាយ ។ គាត់ជាអ្នកកាន់បញ្ជីទ័ពនិងបញ្ជីអ្នកទោស ។ ខ្ញុំស្គាល់តែឈ្មោះអ្នកទោសនៅក្នុងបន្ទប់ខ្ញុំ ។ ខ្ញុំមិនដឹងឈ្មោះក្នុងបញ្ជីទេ ។

ឌុច ខ្ញុំឃើញពីរដងពេលបុណ្យខួប មានអង្គរក្សមកជាមួយ ។ មួយសប្តាហ៍មកពីរដងគឺក្នុង ឆ្នាំ១៩៧៦ ខ្ញុំមើលពីលើអគារតែមិនដឹងមកពីរឿងអ្វី តែក្រោយមកគេបញ្ជូនខ្ញុំទៅធ្វើស្រែបាត់ទៅ ។ នៅបានបីខែ រួចបានចាប់អាហុង ដែលទៅជាមួយខ្ញុំ និងទៅវាយចោល ។ វាបាន

ផ្តាំខ្ញុំថាឲ្យប្រាប់ម៉ែឪវាផង វាស្លាប់ហើយ ហើយក៏ចាប់អា មឿន ជាបងប្អូនជីដូនមួយខ្ញុំយកទៅសម្លាប់ដែរទៅ ។ ហុង ជាមេក្រុមយាម ។ មឿន ជាអ្នកដឹកបន្លែឲ្យខាងសេដ្ឋកិច្ច ។ ពេលគេមកផ្លាស់វេនយាមឃើញគេចាប់ដាក់នៅស្នាក់ការកណ្តាល។ ខ្ញុំមិនដឹងមូលហេតុគេយកវាទៅវាយចោលទេ ។ អាមឿន វានិយាយប្រាប់ខ្ញុំថា អាហុង គេ ចាប់យកទៅព្រៃសហើយ ។ ហើយយប់ក្រោយមកទៀត គេចាប់អាមឿន ។ ស្អែកឡើងគេឲ្យខ្ញុំទៅធ្វើស្រែ ។

[១៣:៤៨:៥៤]

មូលហេតុដែលចាប់ ហុង មកពីមានឈ្មោះ បងណាំ ធ្វើជាទាហាន លន់ នល់ ហើយនៅភូមិកំណើតស្រោមកាំភ្លើងរបស់ ណាំ ត្រូវមេភូមិរកឃើញក៏ចាប់ទៅទួលស្លែង ។ ពេល ហុង ដើរមើលអ្នក ទោស ណាំ ក៏ឃើញស្រែកហៅថា អាហុង ធ្វើឲ្យមេក្រុមនៅជិតខាងដឹងថា ជាបងប្អូនរួច ហុង ក៏ត្រូវ ចាប់ខ្លួន ។ មឿន និយាយប្រាប់ខ្ញុំថា អាហុង គេចាប់យកទៅព្រៃសបាត់ហើយ ។ ពេលអញ្ជូមកពីដឹក បន្លែ ។ ហើយគេក៏ចាប់ អាមឿន ទៅ ។ នៅស្នាក់ការកណ្តាលកន្លែងដែលខ្ញុំឃើញ ហុង នោះ ខ្ញុំឃើញ ហ៊ុយ ជាកងចាប់មានកូនចៅច្រើននាក់នៅក្បែរនោះដែរ ។

ស.សៈ ពេលនៅទួលស្លែងមានប្រជុំទិតៀនអ្វី? ប្រជុំនយោបាយអ្វីទេ?

ខ.ចៈ មានទិតៀនជាក្រុម អ្នកខ្លះដេកងក់ មានមេក្រុមជាប្រធាន តែខ្ញុំមិនចាំឈ្មោះ ។ ទៅរៀននោះនៅខាងត្បូងទួលស្លែង ។ ទាក់ទងគោលនយោបាយរបស់បក្ស គឺថាពេលអ្នកទោសរត់រួច ឬស្លាប់ យើងជាអ្នកទទួលជំនួស ។ ពេលរៀន ហ៊ី ជាអ្នកបង្រៀន ។

ស.សៈ ក្រៅពីក្រុមយាម មានក្រុមផ្សេងទៀតទេ?

ខ.ចៈ មានកងការពារ កងសួរ កងចាប់ ដូចខ្ញុំយាមខាងក្នុង គេហៅកងការពារខាងក្នុង ។ គេអ្នកយាមខាងក្នុងគេមិនឲ្យកាន់កាំភ្លើងទេ ។

ស.សៈ លោកមានដែលឃើញ ឌុច ធ្វើទារុណកម្មអ្នកទោសទេ?

ខ.ចៈ អត់ដឹងទេ ។

ស.សៈ កន្លែងសួរចម្លើយនៅកន្លែងណា?

ខ.ចៈ ពេលខ្ញុំយាមគេឲ្យឈ្មោះមកខ្ញុំ ។ ពេលបាត់អ្នកទោសគេឲ្យខ្ញុំជំនួស ។ ពេលសួរអ្នកទោសគេយកទៅសួរនៅខាងកើតផ្លូវចូលសព្វថ្ងៃ ពេលគេមកយកគេសរសេរឈ្មោះអ្នកទោស ។ ខ្ញុំមិនចេះអក្សរ ខ្ញុំឲ្យអ្នកទោសជួយមើលឲ្យថាតើឈ្មោះអ្នកណា ។ ដល់ពេលល្ងាចគេយកមកវិញគឺអ្នកសួរចម្លើយមកយកផ្ទាល់តែម្តង ។ ខ្ញុំភ្លេចអស់ហើយ ស្គាល់ ច្រឹក ហៅ ភាព ដែលធ្លាប់មកយកដែរ គាត់គឺជាកងសួរ និងវាយអង្គុលីលេខ ។

ស.សៈ ពេលយាម?

ខ.ចៈ វេនយាមក្នុងមួយថ្ងៃចែកជាបួនវេណ ហើយយាមពេលព្រឹកមួយវេន និងយាមពេលយប់មួយវេនក្នុងមួយថ្ងៃយាមពីរដង ។

ស.សៈ មានដែលឃើញ ឌុច ចាត់តាំងទេ?

ខ.ចៈ មិនដែលទេ ។ តាហ៊ុយ ជាអ្នករៀបក្រុម ហើយ ហ៊ុយ នៅក្រុម តាហ៊ី ។

ស.សៈ តើមានអ្នកណាក្រៅពី ហុង ត្រូវមានទោសទេ?

ខ.ចៈ មានច្រើន តែមិនដឹងថាអ្នកណាខ្លះទេ តាមខ្ញុំចំណាំ ។ ចំពោះអ្នកទោសវិញ កាលខ្ញុំនៅយាម មានបាត់តិចទេ ពេលខ្ញុំចេញទៅមានបាត់ច្រើនណាស់ ហើយមានទោសដែលចូលទៅក៏ច្រើនដែរ ព្រោះអ្នកដែលគេបញ្ជូនទៅធ្វើស្រែក្រោយៗគេប្រាប់ខ្ញុំ ។

ស.សៈ លោកផ្ទាល់មានដែលសុំគេមកផ្ទះទេ?

ខ.ចៈ ខ្ញុំមិនដែលបានសុំទេ មានបងប្អូនមកកាត់ដេរនៅស្ពានមុនីវង្សក៏មិនបានសុំមកលេងដែរ ព្រោះក្រៅពីអង្គភាពក្រុមខ្លួនឯង គឺមិនឲ្យទំនាក់ទំនងជាមួយអ្នកផ្សេងទេ ។ នេះជាវិន័យរបស់ស-២១ បានតែសុំ គឺវាយចោល ។

[១៣:៥២:៣៣]

ស.សៈ សូមលោកនិយាយក្រោយពេលបីខែនោះទៀត ។

ខ.ចៈ ក្រោយមក គឺគេបញ្ជូនទៅធ្វើស្រែនៅព្រៃកកំពឹស កង១៤ តាមផ្លូវរោងចក្រកែវទៅតាមព្រៃស។ តាមរោងចក្រកែវទៅត្រង់ គេដកបុគ្គលិកស-២១ ទៅច្រើន ។ មូលហេតុដែលគេដកខ្ញុំទៅ គឺពាក់ព័ន្ធជាមួយអាហុង ដែលអាមឿន និយាយរឿងវាប្រាប់ខ្ញុំ និងអាមឿន ជាបងប្អូនជីដូនមួយខ្ញុំ ។

ស.សៈ ដល់ព្រៃកកំពឹសធ្វើស្រែធ្ងន់ធ្ងរ ឬយ៉ាងណា?

ខ.ចៈ ធ្វើស្រែទាំងយប់ទាំងថ្ងៃ បាយតិចជាងនៅស-២១ ទៅទៀត ជាប់ចំនួនប្រហែល៣០០នាក់នៅទីនោះ ។ មានឈ្មោះ ផល ជាអ្នកកាន់កាប់ គាត់ស្លាប់បាត់ហើយ ។ មិនដែលមាន ឌុច ហ៊ី ទៅមើលទីនោះទេ ។

ស.សៈ ដែលឮឈ្មោះ តេង កាន់នៅជើងឯកទេ?

ខ.ចៈ មិនដែលឮទេ ។

ស.សៈ លោកនៅព្រៃកកំពឹសរហូតដល់ពេលណា?

ខ.ចៈ នៅរហូតដល់បែករំដោះ ។

ស.សៈ តើនៅមានចាំព្រឹត្តិការណ៍អ្វីប្លែកៗពីនេះទេ?

ខ.ចៈ មានការភ័យ ដឹងថាខ្លួនចេញពីនោះមក មិនមានជីវិតជួបបងប្អូនទេ ។

ស.សៈ មូលហេតុអ្វីបានជាគេយកទៅយូរហើយ តែមិនសម្លាប់?

ខ.ចៈ ប្រហែលមិនទាន់ដល់ពេល ។

ស.សៈ ដែលឮព្រៃសទេ?

ខ.ចៈ ធ្លាប់តែឮជាគុកពីសង្គម ។

ស.សៈ ដែលឮ ហ៊ុយ ស្រែ ទេ?

ខ.ចៈ មិនដែលឮទេ ។

ស.សៈ ពេលធ្វើស្រែនោះ ផលស្រូវគេយកទៅណា?

ខ.ចៈ ខ្ញុំមិនដឹងគេយកដឹកយកទៅណាទេ ឃើញតែឡានដឹកទៅទាំងឡានៗ ។

[១៣:៥៤:៣៣]

ស.សៈ ការនៅបីខែ នៅស-២១ លោកសង្កេតឃើញមានអ្នកទោសយ៉ាងម៉េចទៀត?

ខ.ចៈ សង្កេតឃើញអ្នកទោសគេយកទៅពេលដែលសួរចប់ គឺយកទៅបាត់ មិនដែលឃើញយកមកវិញទេ ។

ស.សៈ អ្នកទោសក្នុងមួយថ្ងៃងូតទឹកប៉ុន្មានដង?

ខ.ចៈ ក្នុងមួយថ្ងៃងូតទឹកពីរដង ។ ដេកគ្មានខ្នើយ គ្មានមុង គ្មានភួយ ។ ជាន់លើមិនសូវមានមូសទេ តែជាន់ក្រោមមានមូសច្រើន ។

ស.សៈ តើអ្នកទោសដែលគេយកទៅសួរចម្លើយពេលមកវិញមានស្នាមរបួសអ្វីទេ?

ខ.ចៈ ពេលមកវិញមានជាំមុខ បែកខ្នង ។ ខ្ញុំសួរថា ហេតុអ្វីបានជាគេវាយ? គាត់ឆ្លើយថា គាត់ឆ្លើយអស់ហើយ គេវាយសួរបន្ថែមទៀតខ្លាចលាក់ ។ ការវាយបែកខ្នង ជាំមុខ ខ្ញុំមិនដឹងថា ជាវិន័យឬអត្តនោម័តិរបស់អ្នកសួរទេ ។

ស.សៈ មុនបែកពីព្រែកកំពឹស តើមានអ្នកធំដូចជា ឌុច ទៅណែនាំទេ?

ខ.ចៈ អត់មានទេ ។

ស.សៈ ហេតុអ្វីបានជាដឹងថាវៀតណាមចូល?

ខ.ចៈ ឮសួរគេវាយ គេនាំគ្នារត់ ខ្ញុំពួននៅរោងចក្រកែវ រួចបានជួបកងទ័ពរណសិរ្សជាតិ ហើយបានទៅធ្វើទ័ពនៅភ្នំតាម៉ៅ ក្រោយមកទៅធ្វើកងទ័ពនៅប៉ៃលិន រហូតដល់គេរំសាយយោធិនមុន

សម័យអ៊ុនតាក់ ។

ឯកសារថតចម្លងនៃកំណត់ហេតុមួយច្បាប់ត្រូវបានប្រគល់ឲ្យសាក្សីនេះ ។

កិច្ចនេះបញ្ចប់នៅវេលាម៉ោងដប់មួយ និងសែសិបនាទី នាថ្ងៃដដែល ។

អានឲ្យស្ដាប់ហើយ សាក្សីមិនមានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា ។

សាក្សី, ខៀវ ចេស"

[១៣:៥៦:៣៥]

**ប្រធានអង្គជំនុំ៖**

ជាបន្តទៀត សូមចាត់តាំងលោក ឌុច ផារី ឡើងអាននូវកំណត់ហេតុរបស់សាក្សី ឈ្មោះ ប៉េស ម៉ាត់ ដែលមានឯកសារ D76/2 ។ ERN 00186559 ដល់លេខ 00186563 ។

ឈប់សិនលោក ឌុច ផារី ។ អញ្ជើញតំណាងសហព្រះរាជអាជ្ញា ។

**លោក អានីស អះមេដ៖**

ខ្ញុំសូមអនុញ្ញាតជម្រាបជូនពីចំណុចមួយអំពីនីតិវិធី ហើយខ្ញុំសូមជម្រាបជូនលោកប្រធានថា វិធាន៨៧.២ ដែលគ្រប់គ្រងអំពីភស្តុតាងដែលអង្គជំនុំជម្រះត្រូវប្រើក្នុងពេលដែលធ្វើការវិនិច្ឆ័យជំនុំជម្រះ ខ្ញុំសូមអនុញ្ញាតអាន ។

រាល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះត្រូវផ្អែកលើតែភស្តុតាង ដែលបានដាក់ដេញដោលចំពោះមុខអង្គជំនុំជម្រះ ហើយត្រូវអនុញ្ញាតឲ្យមានការពិនិត្យតទល់" ។ តាមពិនិត្យមើលខបញ្ញត្តិនេះ ខ្ញុំសូមស្នើថា ដើម្បីធានានូវផលប្រយោជន៍យុត្តិធម៌អាចស្នើឲ្យភាគី ថាតើភាគីមានការយល់ដឹងដូចម្តេចដែរជំទាស់ ឬក៏មានការសង្កេតម៉េចទាក់ទងនិងភស្តុតាងនេះ ។ ដោយមានពាក្យថា អនុលោមទៅការពិនិត្យនោះ នោះមានន័យថា សាក្សីត្រូវបានស្នើឲ្យបញ្ចេញការសង្កេត ឬក៏យោបល់របស់ខ្លួនលើភស្តុតាងនេះ ។ នេះជាមតិរបស់ខ្ញុំ ។ សូមអរគុណ ។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

ភាគីផ្សេងទៀត តើមានមតិយោបល់អ្វីទេ លើការដែលលើកឡើងដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានធ្វើការកត់សម្គាល់អំពីនីតិវិធីនៃការអាននូវឯកសារភស្តុតាងនានា ដែលអនុវត្តតាមវិធាន៨៧.២ នេះ?

ខាងមេធាវីការពារក្តី តើមានអ្វីកត់សម្គាល់ចំពោះការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិដែរឬទេ?

សូមអញ្ជើញលោក ការ សាវុត្ថ ។

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន! តាមមតិរបស់ខ្ញុំជាមេធាវីការពារក្តី សូមថារាល់សាក្សីសុំឲ្យធ្វើម៉េចមានសាក្សីហ្នឹងជាមនុស្ស ដើម្បីធ្វើការដេញដោលចំពោះមុខអង្គសវនាការ ពីព្រោះកន្លងមកដូចលោកប្រធានបានជ្រាបស្រាប់ហើយ សាក្សីខ្លះដែលយើងយកមកតទល់នៅមុខនេះ ពេលគាត់ឆ្លើយនៅចៅក្រមស៊ើបអង្កេត ឬក៏ពេលគាត់ឆ្លើយនៅចំពោះលោកសហព្រះរាជអាជ្ញាគាត់ឆ្លើយផ្សេង ។ ដល់ពេលដល់ពេលសវនាការនេះគាត់ឆ្លើយផ្សេង ហើយគាត់បដិសេធចោលនូវចម្លើយរបស់គាត់ដែលបានឆ្លើយពីមុនមកហើយគាត់យកចម្លើយនូវពេលសវនាការនេះ។ ដូច្នេះ យោបល់ខ្ញុំៗយល់ថា គួរតែមានសាក្សីមកដេញដោលចំពោះមុខអង្គសវនាការជាការសមរម្យជាង ។ សូមអរគុណ ។

[១៤:០១:២៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធានសូមអនុញ្ញាតឲ្យជនជាប់ចោទ គាត់មានការសង្កេតទៅលើចំណុចនេះ តើបានទេទាន?

**ប្រធានអង្គជំនុំ៖**

ហេតុផលដែលតំណាងឲ្យសហព្រះរាជអាជ្ញាបានលើកឡើងគឺអង្គជំនុំជម្រះមិនជំទាស់ទេ ហើយក៏មិនអនុវត្តដូចដែលសហព្រះរាជ្ញាបានលើកឡើងដែរ ។ ដោយហេតុថា ការប៉ុនប៉ងនៅក្នុងដំណើរការនៃការអានសក្ខីកម្មសាក្សី ដែលបានផ្តល់រួចហើយនូវចំពោះមុខសហចៅក្រមស៊ើបអង្កេតដែលជាឯក-សារផ្លូវការប្រព្រឹត្តដោយមន្ត្រីដែលមានគុណភាពនៅក្នុងចំណាត់ការស៊ើបអង្កេតនោះ គឺយើងបានសម្រេចថា យកមកអាចនៅចំពោះមុខអង្គសវនាការដែលចាត់ទុកថា ជាការពិភាក្សាដេញដោលនៅទីនេះ ។

ដោយឡែកគឺក្នុងករណីដែលយើងប្រព្រឹត្តទៅនេះ ការប៉ុនប៉ងមួយគឺការអាចនូវឯកសារទាំងអស់តាមផែនការនៃកាលវិភាគកំណត់ហេតុ កាលវិភាគនៃដំណើរការសវនាការរួចហើយ ហើយនិងផ្តល់

វេទិកាទៅភាគី ដើម្បីធ្វើការកត់សម្គាល់នូវកំណត់ហេតុនីមួយៗតាមការយល់ឃើញរបស់ខ្លួន ។

ដូច្នេះ គឺការប្រព្រឹត្តិទៅជាគោលការណ៍មូលដ្ឋានអង្គជំនុំជម្រះប្រកាន់យកថា ការអានចប់សព្វគ្រប់ហើយទើបផ្តល់លទ្ធភាពទៅភាគីដើម្បីធ្វើការកត់សម្គាល់ពាក់ព័ន្ធនឹងកំណត់ហេតុដែលបានអានដោយក្រឡាបញ្ជីនៅក្នុងអំឡុងពេលដំណើរការសវនាការ ។

[១៤:០៤:៣០]

ដោយឡែក បញ្ហាមតិយោបល់របស់មេធាវីការពារក្តី ការ សាវុត្ថ បញ្ហានេះគឺ អង្គជំនុំជម្រះបានសម្រេចរួចរាល់ហើយ អំពីនីតិវិធីប្រព្រឹត្តទៅនៅក្នុងការសម្រេចជ្រើសរើសនូវសាក្សីណាខ្លះដែលយកមកដើម្បីធ្វើសក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ និងសាក្សីណាខ្លះដែលមិនយកក្នុងគោលបំណង ដើម្បីពន្លឿននៃកិច្ចដំណើរការសវនាការដែលយើងបានប្រជុំពិភាក្សាគ្នា អំពីការរិះរកមធ្យោបាយដើម្បីចាត់ការរឿងក្តីនេះឲ្យបានឆាប់រហ័ស ហើយមានការសម្រេចជាក់លាក់ហើយលើការជ្រើសរើសសាក្សីផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ និងសាក្សីដែលត្រូវបាននឹងអាននូវកំណត់ហេតុស្តាប់សក្ខីកម្មរបស់គាត់នៅក្នុងអំឡុងពេលនៃដំណើរការសវនាការដោយមិនចាំបាច់កោះហៅគាត់មកចំពោះមុខអង្គជំនុំជម្រះ ។

ដោយឡែក គឺលោកមេធាវី ហ្វ្រង់ស្វ័រ រ៉ូ បានលើកឡើងអំពីការកត់សម្គាល់របស់ជនជាប់ចោទដែលសុំឲ្យជនជាប់មានការកត់សម្គាល់ ។ អង្គជំនុំជម្រះសូមបញ្ជាក់ថា អង្គជំនុំជម្រះអាចអនុញ្ញាតឲ្យជនជាប់ចោទធ្វើការកត់សម្គាល់ទៅលើខ្លឹមសារនៃសក្ខីកម្មរបស់សាក្សី ប្រសិនបើចង់ធ្វើការកត់សម្គាល់តាមករណីនីមួយៗគឺសូមអញ្ជើញ ។ តែប្រសិនបើ មិនធ្វើសក្ខីកម្មករណីនីមួយៗទេ គឺអង្គជំនុំជម្រះនឹងរៀបចំនូវកាលវិភាគសម្រាប់ធ្វើការកត់សម្គាល់ចុងក្រោយបន្ទាប់ពីការអានសក្ខីកម្ម ។

អ៊ីចឹងអាចមធ្យោបាយពីរ ទីមួយគឺកត់សម្គាល់តាមករណីតាមសក្ខីកម្មមួយ ដើម្បីជាងាយយល់ដើម្បីអាចធ្វើការកត់សម្គាល់បាន ហើយឬមួយធ្វើការកត់សម្គាល់នៅពេលបញ្ចប់នៃការអាននូវកំណត់ហេតុតាមផែនការដែលយើងបានកត់កាលវិភាគរួចហើយនេះ ។ តើលោកជនជាប់ចោទចង់ធ្វើតាមវិធីណា?

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! បើសិនជាបានមានមតិក្នុងករណីមួយម្តងៗ វាល្អហើយ ។ ខ្ញុំសូមធ្វើឲ្យខ្លី ហើយចាំបាច់ក្នុងករណីខ្លះដែលលោកប្រធានអនុញ្ញាតដល់អានសរុបចប់ហើយ ខ្ញុំធ្វើការកត់សម្គាល់សរុបរួមមួយទៀត នេះបើសិនជាអនុញ្ញាត ។ ដោយគោរព ។

**ប្រធានអង្គជំនុំ៖**

ឥឡូវដើម្បីងាយស្រួលគឺសម្រេចថា យើងធ្វើតាមករណីជាក់លាក់នីមួយៗទៅ ហើយអាចចុងក្រោយគឺធ្វើសរុបម្តងទៀត ។ អ៊ីចឹង គឺករណីទីមួយដែលយើងបានអានរួចហើយ ដោយក្រឡាបញ្ជី សែ កុលវុឌ្ឍី អម្បាញ់មិញនេះ តើភាគីមានអ្វី មានមតិកត់សម្គាល់អ្វីដែរឬទេ?

សូមចាប់ផ្តើមពីតំណាងអយ្យការមុន និងភាគីពាក់ព័ន្ធ ។ បើមិនមានទេ យើងប្រគល់វេទិកានេះទៅជនជាប់ចោទដើម្បីធ្វើការកត់សម្គាល់ ។ អញ្ជើញ ។

[១៤:០៨:១៦]

**លោក អានីស អះមេដ៖**

លោកប្រធាន លោកចៅក្រម យើងមិនមានជំទាស់អ្វីទៅនឹងអ្វីដែលទើបតែបានអាននៅក្នុងសក្ខីកម្មនេះទេ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។

**លោកស្រី ស៊ីលវីស្ទ្រូត ហ្សឺនស្ដី៖**

យើងខ្ញុំមិនមានការជំទាស់អ្វីទេ ប៉ុន្តែខ្ញុំមានសំណើមួយដើម្បីឲ្យអានអំពីសៀវភៅជនរងគ្រោះហើយនិងចារីដែលយកមកពីសំណុំរឿងដែរ ដែលយើងរកឃើញសេចក្តីសង្ខេបមួយនៃចម្លើយរបស់សាក្សី ខៀវ ចេស នេះដែរ ដែលមានតែកន្លះទំព័រទេ ហើយអាចនៅក្នុងលេខ ERN00079767 នៅក្នុងអត្ថបទអង់គ្លេស ERN ដែលបាននិយាយខាងនេះគឺមានបញ្ជាក់អំពីការវាយឆ្មក់ដែលធ្វើឡើងដោយក្រុមមួយដែលក្រុមពួកចិន ពួកប្រជាជនចិនបានចូលរួមនៅក្នុងការវាយឆ្មក់នោះ ។ នេះគឺជាអង្គហេតុបន្ថែម ដូច្នេះ ខ្ញុំសូមស្នើថា សូមឲ្យអង្គជំនុំជម្រះមេត្តាបង្គាប់ឲ្យមានការអានចម្លើយដែលទាក់ទងទៅនឹងសាក្សីមួយនេះដែរ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី សូមអញ្ជើញមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមុន ។

**លោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន ហើយសូមគោរពលោកចៅក្រមជាតិ និងលោកចៅក្រមអន្តរជាតិ ។

ហើយខ្ញុំសូមចាប់អារម្មណ៍បន្តិចត្រង់ចំណុចដែលលោកប្រធានដែលបានលើកឡើងថា ឯកសារ

ដែលបានអានជាភាសាខ្មែរដោយលោកស្រីក្រឡាបញ្ជីនោះ គឺជាឯកសារមួយជាផ្លូវការ ។ រីឯឯកសារដែលជាភាសាអង់គ្លេស ហើយនិងភាសាបារាំងនោះ គឺថា មិនទាន់បានបកប្រែឲ្យបានក្បោះក្បាយ ឬក៏គ្រប់ជ្រុងជ្រោយទេ ។ សូមឲ្យភាគី សូមឲ្យខាងអន្តរជាតិ គឺស្តាប់ការបកប្រែរបស់អ្នកបកប្រែផ្ទាល់ ។ សួរថាតើការស្តាប់បកប្រែហ្នឹង គឺជាប្រតិចារឹកយកទៅធ្វើការពិចារណា ឬមួយក៏យ៉ាងម៉េចដែលលោកប្រធានថានឹងយកទៅបកប្រែទៅថ្ងៃក្រោយទៀត យកមកឲ្យខាងអន្តរជាតិគេមើល ។

អ៊ីចឹង សូមពិចារណាត្រង់ហ្នឹងមើលថា បើសិនណាជាឯកសារជាភាសាបារាំងហើយបរទេសបារាំងហើយនិងអង់គ្លេសហ្នឹងមិនទាន់ជាផ្លូវការទេ ហើយឲ្យជនជាប់ចោទគាត់ធ្វើការកត់សម្គាល់ប្រហែលជាអាហ្នឹងមិនទាន់ចូលជាផ្លូវការ ការកត់សម្គាល់ហ្នឹងក៏មិនទាន់បានត្រឹមត្រូវដែរ ។ អ៊ីចឹងសូមឲ្យពិចារ-ណាត្រង់ចំណុចហ្នឹង ។ សូមអរគុណទាន ។

[១៤:១២:០៦]

**ប្រធានអង្គជំនុំ៖**

ដោយបញ្ហានៃការខុសគ្នាចំណុចមួយចំនួន ដោយសារមូលហេតុបច្ចេកទេសនៃការបកប្រែភាសាហើយបច្ចុប្បន្ននេះយើងបានធ្វើការកត់សម្គាល់នៃការវិវឌ្ឍន៍ និងការបកប្រែភាសា គឺបានកម្រិតមួយដែលល្អប្រសើរមែនទែន ហើយដូច្នេះហើយដោយសារដើម្បីសម្រួលនីតិវិធីនេះគឺឲ្យមានការអានយឺតៗហើយនិងការបកប្រែភាសាជាផ្លូវការដោយមានការកែសម្រួលចុងក្រោយនូវប្រតិចារឹក ដែលបានមកពីលទ្ធផលនៃការអាននិងបកប្រែភាសានៅក្នុងកំណត់ហេតុសវនាការនេះ គឺនឹងចែកជូនដល់ភាគីដែលមានការពាក់ព័ន្ធជាមួយនឹងរឿងក្តីនេះជាក្រោយ ។

សូមអញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។

ខ្ញុំចង់លើកឡើងនូវមតិរបស់មេធាវី ស្ទួតហ្សីនស្គី គឺថាការអានកំណត់ហេតុសួរចម្លើយនេះដែលបានចងក្រងឡើងសោយសហចៅក្រមស៊ើបអង្កេតនោះ គឺមានលក្ខណៈសមស្របចំពោះនីតិវិធីរឿងក្តីរបស់យើង ។ ហើយយើងត្រូវប្រកាន់យកជំហរនេះក្នុងខណៈពេលនេះ ប៉ុន្តែតាមពិតគឺមានលទ្ធភាពឲ្យជនជាប់ចោទដើម្បីសម្តែងនូវការសង្កេតរបស់គាត់ ។ ប៉ុន្តែយើងទាំងអស់គ្នាមានឯកសារមួយចំនួនដែលយើងចង់ដាក់ដេញដោលចំពោះមុខតុលាការដែរ ។ ហើយខ្ញុំអាចនឹងគិតឃើញថា នៅពេលដែល

យើងបានធ្វើសវនាការសាក្សីទាំងអស់ហើយ ។ ហើយមុននឹងបញ្ចប់នៃដំណើរការនីតិវិធី ភាគីនីមួយៗនឹងសូមស្នើដាក់នូវឯកសារមួយចំនួនដើម្បីដេញដោលចំពោះតុលាការ ដូចដែលលកញ្ញាមេធាវី ស្ទួត ហ្សីនស្តី ចង់បានដាក់ចំពោះមុខតុលាការចំពោះនីតិវិធីដែលតុលាការបានអនុម័ត ឯកភាពហើយនោះ ។

អ៊ីចឹងដើម្បីយើងសន្សំពេលវេលា ហើយយើងមិនគប្បីកោះហៅសាក្សីទាំងអស់នោះទេ ដើម្បីសន្សំពេល ។ ប៉ុន្តែ ធ្វើយ៉ាងណាកុំឲ្យខ្ជះខ្ជាយពេល ហើយយើងអានឲ្យបានខ្លាំង អ៊ីចឹងសូមអនុញ្ញាតប្រគល់ឲ្យជនជាប់ចោទ ផ្តល់នូវមតិសង្កេតទៅលើចំណុចនីមួយៗ ដូច្នេះ យើងអាចនឹងធ្វើដំណើរទៅមុខបានលឿន ។ នេះជាសំណើរបស់មេធាវីការពារ ។ សូមអរគុណ ។

[១៤:១៥:០៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ទាក់ទងទៅនឹងបញ្ហានៃពេលវេលា យើងនិយាយរួចហើយនៅក្នុងការប្រជុំរៀបចំសវនាការ ។ យើងបានឯកភាពគ្នាថា មេធាវីការពារអាចទទួលយក ឬក៏បោះបង់សិទ្ធិចំពោះការកោះអញ្ជើញសាក្សីរបស់សហព្រះរាជអាជ្ញា ប៉ុន្តែវាអាចជាការបញ្ហាការបកប្រែ ។ ប៉ុន្តែ ខ្ញុំបានឮការសំណើដោយខាងមេធាវីការពារនោះបានស្នើឲ្យសាក្សីដែលសក្ខីកម្មរបស់គាត់ត្រូវបានអាននៅក្នុងអង្គជំនុំជម្រះនេះ គប្បីតែកោះហៅ សាក្សីមក ។ អ៊ីចឹងហើយសូមឲ្យលោកបញ្ជាក់ថា តើយើងអាចចាត់ទុកថាលោកបោះបង់សិទ្ធិរបស់លោកដែរឬទេ? ពីព្រោះខាងដើមលោកមេធាវីស្នើថា សូមឲ្យមានមេធាវីកោះមក កោះនូវសាក្សីទាំងអស់មកបង្ហាញមុខ ឬក៏មេធាវីចង់បញ្ជាក់ការឆ្លើយតបនៅពេលក្រោយ ។

**លោក ហ្រ្វង់ស្វ័រ រូ៖**

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! ដើម្បីៗជម្រាបឆ្លើយតបទៅនឹងចៅក្រម ឡាវ៉ែន៍ មេធាវីការពារប្រកាន់ជំហរអ្វីដែលលោក-- ដែលពួកយើងខ្ញុំបញ្ជាក់កិច្ចប្រជុំរៀបចំសវនាការដែលថាសាក្សីមួយចំនួនមិនត្រូវកោះអញ្ជើញនោះ មិនមែនមានន័យថា យើងទទួលយកនូវខ្លឹមសារទាំងអស់នៃចម្លើយរបស់គាត់នៅក្នុងកំណត់ហេតុនោះទេ ។ នេះហើយជាមូលហេតុដែលយើងសូមអនុញ្ញាតស្នើថា យើងអាចផ្តល់ផទ្ធភាពឲ្យជនជាប់ចោទក្នុងការសម្តែងនូវសេចក្តីសង្កេតរបស់គាត់លើកំណត់ហេតុនីមួយៗពេលដែលអានចប់ ។ ហើយបើសិនជាអង្គជំនុំជម្រះអាចដំណើរការរបៀបនេះ ខ្ញុំអាចនឹងទទួល

យកបាន ។ សូមអរគុណ ។

[១៤:១៩:០១]

**ប្រធានអង្គជំនុំ៖**

បានស្តាប់នូវសំណើសុំរបស់មេធាវី ស្មួតហ្សីនស្គី ដែលមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ហើយនិងបានស្តាប់នូវការកត់សម្គាល់របស់មេធាវីការពារក្តី ហ្វ្រង់ស្វ័រ រូ អង្គជំនុំជម្រះសម្រេចច្រាលចោលនូវសំណើសុំរបស់មេធាវី ស្មួតហ្សីនស្គី ដែលមេធាវីតំណាងឲ្យដើមបណ្តឹងក្រុមពីរដែលសុំឲ្យអាននូវឯកសារមួយទៀតដែលមានលេខ ERN00079767 ដោយសារហេតុផលនៃកាលវិភាគនៃដំណើរការសវនាការនេះ គឺយើងអាចនូវកំណត់ហេតុនៃការស្តាប់សក្ខីកម្មរបស់សាក្សីនៅក្នុងកំណត់ហេតុនៃការយកចម្លើយដោយសហចៅក្រមស៊ើបអង្កេត ។

ដោយឡែក ប្រសិនបើមានឯកសារណាផ្សេងទៀតដែលភាគីមានការប៉ុនប៉ងលើកមកដេញដោលនោះ គឺយើងនិងពិចារណាលើពេលវេលាចុងក្រោយនៃការបញ្ចប់ក្នុងការធ្វើសក្ខីកម្មចំពោះសាក្សីឬក៏ចំពោះដើមបណ្តឹងរដ្ឋប្បវេណី យើងនឹងមានពេលវេលាមួយសម្រាប់ពិភាក្សាដេញដោលលើឯកសារផ្សេងៗទៀត ដែលភាគីយល់ឃើញថាចាំបាច់ដើម្បីលើកមកពិភាក្សាដេញដោល ។ នេះយើងនឹងពិចារណានូវកំណត់កាលបរិច្ឆេទនៅពេលក្រោយ ។

ហើយជាបន្តសូមអញ្ជើញលោកជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់នូវលើកំណត់ហេតុសាក្សីឈ្មោះ ខៀវ ចេស អម្បាញ់មិញនេះ ។ សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! សក្ខីកម្មរបស់ ខៀវ ចេស នាអំពីអង្គហេតុស-២១ មានលក្ខណៈត្រឹមត្រូវគួរទទួលយកបានជាមូលដ្ឋាន ។ រឿងមួយដែលខ្ញុំសង្កេតឃើញលើស គឺឡានទៅដឹកយកយុវជនដែលខ្ញុំសូមពីតំបន់កំពង់ឆ្នាំងមករហូតដល់ប្រាំរយនាក់ លើសហើយ ។

ហើយធម្មតា នៅស-២១ មានការចាប់ចង ដោយឡែកករណីជាចំពោះដែល ខៀវ ចេស គាត់ធ្វើសក្ខីកម្មថាស-២១ ចាប់លោក ហុង ហើយនិង មឿន នោះ ខ្ញុំក្តាប់អត់បានទេ ។ នេះខ្ញុំសូមធ្វើជាការបញ្ជាក់ត្រឹមប៉ុនណោះ ។ ដោយគោរព ។

[១៤:២១:៥៥]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តសូមអញ្ជើញលោក ឌុច ផារី ឡើងអាននូវកំណត់ហេតុសក្ខីកម្មរបស់សាក្សី ប៉េស ម៉ាត់ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ។ ឯកសារដែលមានលេខ D76/2 ហើយនិង ERN 00186559 ដល់លេខ 00186563 ។

**លោក ឌុច ផារី៖**

ការិយាល័យសហចៅក្រមស៊ើបអង្កេត សំណុំរឿងព្រហ្មទណ្ឌលេខ ០០២ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦ លេខស៊ើបសួរ លេខ001 ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ECCC-OCIJ ។

ឆ្នាំពីរពាន់ប្រាំបីខែមីនា ថ្ងៃទី១៨ នៅវេលាម៉ោងដប់បួននិងសាមសិបនាទី នៅភូមិច្រាំងខ្ពស់ ឃុំព្រែកជីក ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។

យើង សឹម សុរិយ៉ា និង Fabienne Luco ជាអ្នកស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញដែលត្រូវបានចាត់ដោយដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៨ ។

បានឃើញច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ។

បានឃើញវិធាន២៤, ២៨ និង៦០ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំវិសាមញ្ញ ។

ដោយមានវត្តមានរបស់លោក និល សាម៉ន ជាបកប្រែនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានស្បថស្បែរួចហើយ ។

[១៤:២៤:២៨]

កត់ត្រាយកចម្លើយពីឈ្មោះ ប៉េស ម៉ាត់ ដែលហៅកាត់ថា “ប.ម.” ជាសាក្សីដែលបានផ្ដល់ព័ត៌-មានស្ដីពីអត្តសញ្ញាណដូចខាងក្រោម៖

ឈ្មោះ ប៉េស ម៉ាត់ ឈ្មោះបដិវត្តន៍ លី ទ្រី កើតឆ្នាំ១៩៦០ ។

ជននេះបានប្រកាសថា ខ្លួនចេះអានសរសេរ និងយល់ភាសាខ្មែរ ។

យើងបានជូនព័ត៌មានដល់ជននេះថាការស្ដាប់យកចម្លើយនេះនឹងត្រូវថតយកសំឡេងឬរូបភាព។

ជននេះបានប្រាប់យើងពីទំនាក់ទំនងរបស់គេជាមួយនឹងជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណីថាគ្មាន។

ជននេះបានស្បថស្របតាមបញ្ញត្តិនៃវិធាន២៤ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ។

យើងបានប្រាប់ដល់ជននេះអំពីសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ស្របតាមបញ្ញត្តិនៃវិធាន ២៨ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ និងមានសិទ្ធិមានមេធាវីការពារខ្លួនផងដែរ ។

សួរ-ឆ្លើយ៖

សុរិយា និង ហ្វាប៊ីយ៉ាង (Fabienne)៖ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តើលោកនៅឯណា? កំពុងធ្វើអ្វី?

ប.ម៖ ថ្ងៃនេះខ្ញុំនៅជាកុមារ ។ ខ្ញុំនៅធ្វើទំនប់នៅអូរកណ្តាល ក្នុងឃុំឈូកស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំ ។ ក្រោយមកគ្រូបង្រៀនឈ្មោះ តាណូ បានហៅកុមារទៅនៅភ្នំពេញ ។ ក្នុងមួយឃុំគេរើសកុមារចំនួនបីនាក់ ។ ក្នុងនោះមាន ម៉ក់ ស៊ីធឹម ទៅដែរ ទៅជួបគ្នានៅសាលាលេខ៥ ដោយធ្វើការងារដាំដំឡូង ។ នៅចុងឆ្នាំ១៩៧៥ ខ្ញុំបានមករៀនបច្ចេកទេសយោធារៀន ដោះមីន និងយុទ្ធវិធីនៅសាលាបច្ចេកទេសយោធា៧០៣ នៅបឹងទំពុន ។ នៅពាក់កណ្តាលឆ្នាំ១៩៧៦ ពួកខ្ញុំត្រូវបានរើស និងបែងចែកជាបីក្រុម ។ មួយក្រុមទៅការពារនៅព្រំដែន មួយក្រុមទៅធ្វើការនៅព្រៃស និងមួយទៀតទៅខាងការពារក្រុង ។ ខ្ញុំនៅខាងការពារក្រុង បានទៅធ្វើការនៅក្នុងគុកតាខ្មៅក្នុងមន្ទីរពេទ្យឆ្កួត ។ ខ្ញុំបានឃើញអ្នកទោសក្នុងគុកនោះមិនដឹងថាជាទាហាន ឬស៊ីវិលទេ ។ ហើយមានជាប់ខ្នោះជើង ខ្ញុំមិនស្គាល់មេគុកនោះទេ ។ ខ្ញុំមិនដឹងអ្នកទោសនោះត្រូវបានយកមកសួរចម្លើយយ៉ាងម៉េច ឬយកទៅណាទេ ឃើញតែបាត់ខ្លួន ។ មេកងហារបស់ខ្ញុំនៅកន្លែងគុកនោះឈ្មោះ ហ៊ន ហើយគេចាប់ដាក់គុកស្លាប់យូរហើយ ដោយសារថាក្បត់ ។ ក្នុងឆ្នាំ១៩៧៦ ខ្ញុំបានទៅទួលស្លែង ។

[១៤:២៧:៥៩]

សុរិយា និង ហ្វាប៊ីយ៉ាង៖ សូមរៀបរាប់ពេលវេលាទៅដល់ទួលស្លែង តើគេឲ្យលោកធ្វើអ្វី?

ប.ម៖ ខ្ញុំមកដំបូងរៀបចំបោសសម្អាតផ្ទះជុំវិញទួលស្លែង ។ សម្អាតផ្ទះមួយហើយ ខ្ញុំត្រូវសម្អាតផ្ទះមួយទៀត ពីព្រោះផ្ទះទាំងនោះមានភាពរញ៉េរញ៉ៃក្រោយពីមនុស្សត្រូវជម្លៀសអស់ ។ ការងាររបស់ខ្ញុំនៅចាំផ្ទះមើលមាន់ទា ដាំបាយ ។ ពេលខ្លះខ្ញុំយាមគុកទួលស្លែងនៅខាងក្រៅ ពេលខ្លះខ្ញុំយាមនៅខាងក្នុង ហើយមានដូរវេនគ្នា ។ មេក្រុមរបស់ខ្ញុំឈ្មោះ ហេង ធំជាង ហេង មានឈ្មោះ នី ដែលជាប្រធានកងហា ។ ធំជាង នី មានឈ្មោះ ប៉ូច ធំជាង ប៉ូច មានឈ្មោះ ប៉េង ធំជាង ប៉េង មាន តាហ៊ី ធំជាង ហ៊ី មាន ចាន់ និង ឌុច ។ ទាំងបីនាក់ចុងក្រោយនេះ ជាគណៈ ជាអនុ

និងសមាជិក ស្និតនឹងគ្នា ទាំងអស់នេះខ្ញុំមិនដឹងថា នៅរស់ឬយ៉ាងណាទេ ។

[១៤:២៩:២០]

សុរិយា និង ហ្វាប៊ីយាង៖ តើលោកទទួលការចាត់តាំងការងារដោយរបៀបណា?

ប.ម៖ ខ្ញុំទទួលការងារដោយមេក្រុមរបស់ខ្ញុំមកហៅប្រាប់។ ហើយមេក្រុមរបស់ខ្ញុំទៅប្រជុំមួយអាទិត្យម្តង ។ ខ្ញុំធ្លាប់ប្រជុំកសាងខ្លួន និងធ្លាប់រៀននយោបាយដែលមានឈ្មោះ ប៉េង ជាអ្នកឧទ្ទេសនាម ។

សុរិយា និង ហ្វាប៊ីយាង៖ តើលោកធ្លាប់ទៅចូលរួមប្រជុំធំៗអប់រំនយោបាយ ដោយមានមនុស្សច្រើនដោយមាន ឌុច ទៅចូលរួមដែរឬទេ?

ប.ម៖ ខ្ញុំធ្លាប់ចូលរៀននៅសាលានយោបាយនៅខាងកើតគុក នៅចន្លោះពីគុកនិងផ្លូវមុនីវង្ស មានមនុស្សចូលរួមច្រើន ហើយមានរយៈពេលពីរបីថ្ងៃទើបមាន ឌុច ចូលរួម ។

សុរិយា និង ហ្វាប៊ីយាង៖ ក្នុងការរៀនយោបាយហ្នឹងមានរៀនអ្វីខ្លះ? តើមានរៀនពីការតាមចាប់ខ្មាំងដែរឬទេ?

ប.ម៖ មាននិយាយអំពីការកសាងខ្លួនឲ្យមានជំហររឹងមាំកុំចូលដៃជាមួយខ្មាំងយួន ។

សុរិយា និង ហ្វាប៊ីយាង៖ តើលោកធ្លាប់ឃើញអ្នកដែលចូលដៃជាមួយខ្មាំងយួន ហើយត្រូវបានចាប់គុកក្នុងទួលស្លែងដែរឬទេ?

ប.ម៖ ខ្ញុំឃើញអ្នកដែលបាត់ខ្លួន បាត់តែម្តង ខ្ញុំមិនដឹងថាគេចោទថាជាខ្មាំង ឬយ៉ាងណាទេ ។ ក្នុងនោះមានឈ្មោះ នី, ឈ្មោះ ប៉ូច ដោយខ្ញុំគ្រាន់តែដឹងថា គេចោទថាក្បត់ ។

សុរិយា និង ហ្វាប៊ីយាង៖ តើមេក្រុមរបស់លោកមានដែលបញ្ជាឲ្យលោកតាមដាន និងរាយការណ៍ថាអ្នកណាមួយជាខ្មាំងដែរឬទេ?

ប.ម៖ ពេលប្រជុំមេក្រុមប្រាប់ខ្ញុំ ឲ្យរាយការណ៍ប្រាប់គាត់អំពីអ្នកណាដែលមានសកម្មភាពឬនិយាយជាមួយមនុស្សចំឡែក ហើយខ្ញុំគិតថាបញ្ហានេះ គឺមានថ្នាក់លើប្រាប់មកប្រធានរបស់ខ្ញុំទើបគាត់ប្រជុំប្រាប់យ៉ាងដូច្នេះ ។

[១៤:៣១:៥២]

សុរិយា និង ហ្វាប៊ីយាង៖ តើលោកធ្លាប់ឃើញអ្នកទោសរៀតណាមក្នុងពេលដែលលោកយាមនៅខាងក្នុង និងខាងក្រៅដែរឬទេ?

ប.មៈ នៅឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ ខ្ញុំបានឃើញពីរបីនាក់ជាអ្នកទោសវៀតណាម ដោយឃើញពាក់ខោអាវទាហានវៀតណាមមានជាប់ខ្នោះ តែខ្ញុំមិនដឹងថា យកមកពីណា ។ ប៉ុន្មានថ្ងៃក្រោយមកខ្ញុំមកយាមម្តងទៀតឃើញមានស្នាមរបួស ដូច្នេះខ្ញុំគិតថាពេលសួរចម្លើយពិតជាមានការវាយធ្វើទារុណកម្ម ។ ក្រោយមកអ្នកទោសវៀតណាមបាត់ខ្លួនទៅវិញ តែមិនដឹងថាគេយកទៅណា ។ ខ្ញុំឃើញអ្នកទោសស្ត្រីវៀតណាមពីរបីនាក់ដែរ ស្លៀកពាក់ស៊ីវិល ។

សុរិយា និង ហ្វាប៊ីយាងៈ តើអ្នកទោសទាំងវៀតណាម ទាំងខ្មែរត្រូវបានប្រព្រឹត្តដូចគ្នា ឬយ៉ាងម៉េច?

ប.មៈ ត្រូវគេប្រព្រឹត្តដូចគ្នា ។ កុំឲ្យសម្លុត កុំឲ្យវាយ គឺគោលការណ៍ដូចគ្នា ។

សុរិយា និង ហ្វាប៊ីយាងៈ តើលោកដឹងថា ពេលចាប់វៀតណាមនោះមានសង្គ្រាមរវាងកម្ពុជានិងវៀត-ណាមដែរឬទេ?

ប.មៈ ខ្ញុំដឹងតាមរយៈអ្នកការដូចគ្នាថា មានសង្គ្រាមចាប់វៀតណាមមកពីព្រំដែន ព្រៃវែង និងស្វាយ-រៀង តែ ឌុច ផ្ទាល់មិនដែលប្រជុំប្រាប់ថាមានសង្គ្រាមទេ ។ ខ្ញុំក៏បានឮថា មានសង្គ្រាមថា មានចាប់វៀតណាមតាមរយៈវិទ្យុនៅកន្លែងរោងបាយដែរ ។

សុរិយា និង ហ្វាប៊ីយាងៈ តើលោកមានដែលឃើញអ្នកណារៀនសៀវភៅទង់បដិវត្តន៍ដែរឬទេ?

[១៤:៣៣:៥៨]

ប.មៈ ខ្ញុំមិនដែលអានសៀវភៅទង់បដិវត្តន៍ទេ ។ តែខ្ញុំធ្លាប់ឃើញអ្នកផ្សេងអានដែលជាប្រធានក្រុមប្រធានពួក អត់ចាំឈ្មោះ ។

សុរិយា និង ហ្វាប៊ីយាងៈ តើលោកមានដែលឃើញ ឌុច មកចាត់តាំងការងារផ្ទាល់នៅក្នុងគុក ឬក៏នៅពេលដែលយកអ្នកទោសចេញទៅក្រៅឬទេ?

ប.មៈ ខ្ញុំមិនដែលឃើញទេ ។ ខ្ញុំធ្លាប់ ឌុច នៅតាមផ្លូវជិះឡានហ្ស៊ីប ។

សុរិយា និង ហ្វាប៊ីយាងៈ តើលោកមានដឹង ឬធ្លាប់ធ្វើការងារពេទ្យដែរឬទេ?

ប.មៈ ខ្ញុំធ្លាប់នៅយាមជិត ម៉ក់ ស៊ីធីម ឃើញគាត់លាងរបួស ។ នៅពេលខ្លះ ខ្ញុំជួយចែកថ្នាំឲ្យអ្នកទោស ។ ខ្ញុំមិនបានធ្វើពេទ្យ ដោយសារគេរើសរកអ្នកដែលចេះអក្សរច្រើន ។ ផ្ទះពេទ្យ គឺផ្ទះឈើដែលនៅខាងមុខទួលស្លែង ។ ខ្ញុំមិនដែលឃើញការបូមឈាមនិងការយកមនុស្សទៅពិសោធន៍ទេ តែខ្ញុំឮតាមអ្នកធ្វើការដូចគ្នាថា មានការបូមឈាមយកទៅជំនួយអ្នករបួស ។ ខ្ញុំឮថាមានកន្លែងចិញ្ចឹមឈាមនៅកន្លែងមួយហៅថា “ស្រះស្រង់” នៅខាងកើតគុកទួលស្លែង ។

សុរិយា និង ហ្វាប៊ីយាង៖ តើលោកមានឃើញអ្នកទោសបរទេសដែរឬទេ?

ប.ម៖ ខ្ញុំមិនដែលឃើញទេ ។

សុរិយា និង ហ្វាប៊ីយាង៖ លោកមានដែលឃើញអ្នកទោសត្រូវសម្លាប់ទាំងក្រុមៗ មុនបែកឆ្នាំ១៩៧៩ ដែរឬទេ?

ប.ម៖ ខ្ញុំមិនដែលឃើញទេ ព្រោះខ្ញុំត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅជិតរោងចក្រកែវ ក្បែរជើងឯក ។ ការងារខ្ញុំ គឺបូមទឹកដាក់ស្រែ កាយកំផ្លោកធ្វើជីដាក់ស្រែ ។

ឯកសារច្បាប់ដើម ឬថតចម្លងនៃកំណត់ហេតុមួយច្បាប់ត្រូវបានប្រគល់ឲ្យសាក្សីនេះ ។

កិច្ចការនេះបញ្ចប់នៅវេលាម៉ោងដប់ប្រាំមួយ និងសែសិបនាទី នាថ្ងៃដដែល ។

អានឲ្យស្តាប់ហើយ សាក្សីមិនមានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា ។

សាក្សី ប៉េស ម៉ាត់ ។”

**ប្រធានអង្គជំនុំ៖**

ក្រោយពីស្តាប់នូវការអានចម្លើយសាក្សី ប៉េស ម៉ាត់ តើភាគីសហព្រះរាជអាជ្ញា មានការកំណត់សម្គាល់អ្វីដែរទេ?

**លោក អានីស អះមេដ៖**

លោកប្រធាន ខាងសហព្រះរាជអាជ្ញាមិនមានការជំទាស់អ្វីទៅក្នុងការដាក់សេចក្តីថ្លែងការណ៍នេះ ចូលទៅក្នុងសំណុំរឿងទេ ។

**ប្រធានអង្គជំនុំ៖**

ខាងមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី តើមានមតិអ្វីកត់សម្គាល់លើឯកសារ លើកំណត់ហេតុសាក្សី ដែលបានអានដោយក្រឡាបញ្ជី ឌុច ផារី អម្បាញ់មិញនេះដែរឬទេ?

**លោក អាឡាំង វ៉ែនណឺ៖**

មិនមានទេ លោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

លោកខាងមេធាវីការពារក្តី តើមានអ្វីចង់កត់សម្គាល់លើការកំណត់ហេតុសាក្សី ប៉េស ម៉ាត់ ដែលអានដោយក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះដែរឬទេ?

**លោក ហ្វេង់ស្វ័រ រូ៖**

លោកប្រធាន យើងខ្ញុំចង់ឲ្យជនជាប់ចោទធ្វើការកត់សម្គាល់ទៅលើកិច្ចសម្ភាសន៍ដែលទើបតែបានអានអម្បាញ់មិញនេះ ។

**ប្រធានអង្គជំនុំ៖**

សូមផ្តល់ឱកាសទៅដល់ជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់នូវកំណត់ហេតុសក្ខីកម្មរបស់សាក្សី ប៉េស ម៉ាត់ ដែលបានធ្វើនៅចំពោះមុខអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត ។

សូមអញ្ជើញលោក ឌុច ។

[១៤:៣៨:៤៥]

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! សក្ខីកម្មរបស់ ប៉េស ម៉ាត់ មានលក្ខណៈសមរម្យជាមូលដ្ឋាន ។ ខ្ញុំសូមបញ្ជាក់តែបញ្ហាបី៖

ទីមួយ គឺខ្ញុំពិតជាបានទៅយកមនុស្ស ទៅសុំមនុស្សពីតំបន់៣១ គឺកំពង់ឆ្នាំងមកមែន ។ កាលសុំមនុស្សមកនេះ មិនឋិតនៅក្នុងក្របខ័ណ្ឌចាត់ចែងរបស់កងពល៧០៣ទេ គឺស-២១ ចាត់ចែងដោយផ្ទាល់។ នេះគ្រាន់តែសូមជូនជាការសង្កេតប៉ុណ្ណោះ ។ ឯចំណែករចនាសម្ព័ន្ធរបស់ ស-២១ ខ្ញុំបានរាយការណ៍ជូនអង្គជំនុំជម្រះ ក៏ដូចតាំងពីសម័យស៊ើបអង្កេតម្ល៉េះ។ គណៈកម្មាធិការមន្ទីរស-២១ មានខ្ញុំជាលេខា មិត្តហ៊ី អនុលេខា ហើយនិង នុន ហ៊ុយ ជាសមាជិក ។ ក្រោយមកដាក់មិត្ត ផល ជំនួស នុនហ៊ុយ ។ នេះ គឺសូមកត់សម្គាល់ប៉ុណ្ណោះ ។

ឯចំណែកករណីមួយ ដែលលោក ប៉េស ម៉ាត់ ឲ្យសក្ខីកម្មថាបានឮគេនិយាយអំពីកន្លែងចិញ្ចឹមឈាម ។ ខ្ញុំមានបំណងចង់បញ្ជាក់បញ្ហានេះ ។ លោក ប៉េស ម៉ាត់ សក្ខីកម្មរបស់គាត់ គាត់ថាបានឮ ក៏ប៉ុន្តែទោះបីយ៉ាណក៏ដោយ ក៏ខ្ញុំសូមមេត្តាបញ្ជាក់ថា កន្លែងចិញ្ចឹមឈាមនេះ វាទាមទារបច្ចេកទេសខ្ពស់ ។ ដូច្នេះ មិនអ្នកណាធ្វើបានដោយគ្មានសំណើរបស់ខ្ញុំទៅខាងលើទេ ។ ខ្ញុំអត់បានស្នើទៅខាងលើទេ ហើយក៏គ្មានអ្នកណាជំនាន់នោះប៉ានដាក់ឈ្មោះអង្គភាព ឬកន្លែងមួយរបស់ខ្លួនថា “ស្រះស្រង់” ថា “បាយ័ន” ថា “អង្គធំ” អី គឺអត់ប៉ានទេ ។ ដូច្នេះ ខ្ញុំសូមកត់សម្គាល់អំពីបញ្ហាកន្លែងចិញ្ចឹមឈាមដែលបារាំងគេហៅថា *ឡាប៉ង់កឹសឌុយសង់* ហ្នឹងប៉ុណ្ណោះ ។ សូមគោរព ។

**ប្រធានអង្គជំនុំ៖**

ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ហើយដល់រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចនីតិវិធីសវនាការរបស់យើង ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកនៅម៉ោង១៤:៤១:១០ ដល់ម៉ោង ១៥:០២នាទី ]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

ជាបន្តប្រគល់ភារៈទៅលោកស្រី សែ កុលវុឌ្ឍី ឡើងអាននូវកំណត់ហេតុយកចម្លើយសាក្សីឈ្មោះ ញ៉ែម អេន ដែលមានឯកសារ D22/15 លេខERN ជាភាសាខ្មែរ 00162833 រហូតដល់ 00162851 ។

**លោកស្រី សែ កុលវុឌ្ឍី៖**

“ការិយាល័យសហចៅក្រមស៊ើបអង្កេត សំណុំរឿងព្រហ្មទណ្ឌលេខ ០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ ។ លេខស៊ើបសួរ ០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ។

ឆ្នាំ២០០៧ ខែវិច្ឆិកា ថ្ងៃទី០១ នៅវេលាម៉ោងប្រាំបួនព្រឹក នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

យើង ស៊ឹម សុរិយា អក្សរកាត់ ស.ស និង ហ្វាប៊ីយាង លុក្ខ អក្សរកាត់ អេហ្វ.អិល អ្នកស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ ដែលត្រូវបានចាត់ដោយដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់សហចៅក្រមស៊ើប អង្កេត ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ ។

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ។

បានឃើញវិធាន២៤ ២៨ និង ៦០ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ។

ដោយមានវត្តមានរបស់លោក ហេង ហាំខេង ជាអ្នកបកប្រែភាសានៃអង្គជំនុំជម្រះវិសាមញ្ញ ដែលបានស្បថរួចហើយ ។

បានកត់ត្រាយកចម្លើយពីឈ្មោះ ញ៉ែម អេន អក្សរកាត់ ញ.អ ជាសាក្សីដែលបានផ្តល់ព័ត៌មានស្តីពីអត្តសញ្ញាណដូចខាងក្រោម៖

ឈ្មោះ ញ៉ែម អេន ឈ្មោះបដិវត្តន៍ អត់មាន កើតថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៩ ។

ជននេះបានប្រកាសថា ខ្លួនចេះអានអក្សរ និងយល់ភាសាខ្មែរ ។

ជននេះបានប្រកាសថាខ្លួនមិនចេះអាន និងសរសេរភាសាដទៃ ។

ហេតុដូច្នេះ ច្បាប់ដើមនៃកំណត់នៃហេតុ ត្រូវបានសរសេរជាភាសាខ្មែរ ។

យើងបានជូនព័ត៌មានរួចហើយដល់ជននេះថា ការស្តាប់យកចម្លើយនេះនឹងត្រូវថតយកសំឡេងឬរូបភាព ។

[១៥:០៥:១៥]

ជននេះបានប្រាប់យើងពីទំនាក់ទំនងរបស់គេជាមួយនឹងជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណីថាមិនទាក់ទង ។

ជននេះបានស្បថស្របតាមបញ្ញត្តិនៃវិធាន២៤ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ។

យើងបានប្រាប់ដល់ជននេះអំពីសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ស្របតាមបញ្ញត្តិ នៃវិធាន២៨ នៃវិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញ ។

សួរ-ឆ្លើយ

ស.ស៖ សូមលោករៀបរាប់ពីប្រវត្តិរបស់លោកមុនពេលលោកមកដល់ ស-២១?

ញ.អ៖ ខ្ញុំសូមជម្រាបជូនថា ខ្ញុំនិយាយត្រឹមឆ្នាំ១៩៧៥ ។ នៅថ្ងៃ១៧ មេសា ក្រោយពេលរណសិរ្សកម្ពុជាវាយ លន់ នល់ ខ្ញុំក្នុងនាមជាកុមារឈានមុខមួយនៅស្រុកកំពង់លែង តំបន់៣១ ។ ខ្ញុំក៏ត្រូវបានជ្រើសរើសដោយអង្គការដោយសារខ្ញុំជាមនុស្សឧស្សាហ៍ព្យាយាមក្នុងការងារ ។ កាលនោះអង្គការរើសតាមឃុំ ក្នុងមួយឃុំប្រាំពីរនាក់ ។ ក្នុងនោះមានកុមារប្រហែលជាមួយពាន់នាក់ត្រូវបានអង្គការជ្រើសរើស ។ ក្រោយមកអង្គការហៅមកនៅផ្ទះប្រាំជាន់ ជិតព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ។ កាលនោះខែបួន ខ្ញុំមានឃើញមានការជម្លៀសប្រជាជនចេញពីភ្នំពេញតាមផ្លូវកំពង់ឆ្នាំងផងដែរ ។

អេហ្វ.អិល៖ លោកមានប្រសាសន៍ថា ព្រលានយន្តហោះកំពង់ឆ្នាំង?

ញ.អ៖ គឺព្រលានយន្តហោះចាស់ ។ ខ្ញុំនៅទីនោះប្រហែលជាខែប្រាំ ឬប្រាំមួយ ឆ្នាំ១៩៧៥ ។ ក្រោយ

មកអង្គការបញ្ជូនខ្ញុំមកភ្នំពេញតាមរយៈឡាន *សេអឹមសេ* របស់អាមេរិកាំង ដែលកាលនោះមានឡានដប់គ្រឿង ។ កាលនោះតាមផ្លូវមានការដាច់ស្ពាន ដូច្នេះខ្ញុំធ្វើដំណើរអស់រយៈពេលមួយយប់ ទើបមកដល់ភ្នំពេញ ។

ស.ស៖ ពេលនោះលោកអាយុប៉ុន្មាន?

ញ.អ៖ កាលនោះខ្ញុំអាយុដប់ប្រាំមួយដប់ប្រាំពីរឆ្នាំ ហើយបន្ទាប់មកទៀតពេលខ្ញុំនៅភ្នំពេញ អង្គការគេបញ្ជូនខ្ញុំមកនៅបឹងទំពុន ទល់មុខពេទ្យរុស្ស៊ី ។

ស.ស៖ តើអ្នកណាជាអ្នកនាំលោកមកភ្នំពេញ?

[១៥:០៧:៤៨]

ញ.អ៖ ខ្ញុំមិនអាចចាំបាន តែនិយាយរួមប្រហែលជាគណៈតំបន់ គណៈស្រុកកំពង់លែង ដែលគេទទួលបញ្ជាពីអង្គការមក ឲ្យរើសកុមារល្អៗមកភ្នំពេញ ។ ពេលខ្ញុំមកនៅបឹងទំពុន ខ្ញុំអត់មានធ្វើអ្វីទេ គេឲ្យនៅគេងតាមផ្ទះ ដែលសល់ពីសង្គម ហើយបើតាមខ្ញុំស្មាន ខ្ញុំប្រហែលជាមកដល់ក្នុងខែប្រាំមួយ ឬប្រាំពីរ ឆ្នាំ១៩៧៥ ។ ខ្ញុំសូមបញ្ជាក់ថាការរើសកុមារមកនេះ បើមិនមានការបញ្ជាពីមជ្ឈិមបក្សមកទេ មិនអាចរើសបានទេ ។

អេហ្វ.អិល៖ លេខតំបន់ឈ្មោះអ្វី?

ញ.អ៖ ខ្ញុំភ្លេចឈ្មោះហើយ ។ ខ្ញុំចេញពីបឹងទំពុន ហើយអង្គការបញ្ជូនខ្ញុំទៅនៅតាខ្មៅ នៅក្រពើហា នៅតាមដងស្ទឹងព្រែកត្នោត ហើយគេឲ្យខ្ញុំហាត់ខាងផ្នែកបច្ចេកទេស ។

អេហ្វ.អិល៖ នៅពេលនោះអ្នកណាជាប្រធាននៅតាខ្មៅ?

ញ.អ៖ កាលនោះយើងមានអគ្គសេនាធិការ ខ្ញុំអត់ស្គាល់ឈ្មោះទេ តែមានឈ្មោះ ណាត ឈ្មោះ ពីន តែតា ពីន ជាប្រធានកងពល៧០៣ កាន់ខាងបច្ចេកទេស ។

ស.ស៖ ហាត់បច្ចេកទេសអ្វី?

ញ.អ៖ គេឲ្យរៀនបច្ចេកទេសយោធា គឺបច្ចេកទេសសមរភូមិ គ្រប់យ៉ាងទាំងអស់ ទាំងបច្ចេកទេសខាងកងព័ទជើងគោក ជើងអាកាស គឺរៀនទាំងអស់ ។

អេហ្វ.អិល៖ តាខ្មៅនៅពេលនោះ គេហៅឈ្មោះអ្វី?

ញ.អ៖ កាលនោះនៅខាងក្រោយពេទ្យឆ្កួត នៅតាមផងស្ទឹងព្រែកត្នោត ។

អេហ្វ.អិល៖ ក្រៅពីកន្លែងហាត់បច្ចេកទេស តើកន្លែងនោះមានបង្រៀនអ្វីផ្សេងទេ?

ញ.អ៖ អត់មានអ្វីផ្សេងទៀតទេ តែបើកុមារ ដែលខ្ជិលច្រអូសនឹងការងារ គេឲ្យទៅធ្វើស្រែ អ្នកខ្លះគេឲ្យទៅតាមរោងចក្រ អ្នកខ្លះគេយកទៅខាងកងទ័ព។ កាលនោះកុមារប្រហែលជាហាទៅហុកសិបនាក់ ដែលត្រូវបានគេពិនិត្យប្រវត្តិរូបថា ជាកុមារឈានមុខគេ គេក៏បញ្ជូនទៅរៀននៅប្រទេសចិន ។

ស.ស៖ ដូច្នេះទៅចិនទាំងហាសិបនាក់ ឬក៏ម្នាក់ឯង?

ញ.អ៖ ទៅចិនកាលនោះមានគ្នាសែសិបប្រាំមួយនាក់ តែការទៅចិននោះមានការបំពាក់បំប៉នពីអង្គការដែលគេមានការពិនិត្យសុខភាពរួចអស់ ទើបគេបញ្ជូនខ្ញុំទៅកំពង់សោមឲ្យជិះនាវាទៅប្រទេសចិន ។

ស.ស៖ មុននឹងលោកចេញទៅចិន អ្នកណាហ្វឹកហ្វាត់លោក?

[១៥:១០:៤៣]

ញ.អ៖ សុទ្ធតែខ្មែរតែម្តង អត់មានជនជាតិផ្សេងទេ ។

ស.ស៖ ពេលហាត់នោះគេមានប្រាប់ថា ហាត់ដើម្បីធ្វើអ្វី?

ញ.អ៖ បើនិយាយធម្មតា គេបង្ហាត់យោធា ។ សំខាន់ទិសដៅរបស់អង្គការ គឺដើម្បីការពារទឹកដី ការពារសង្គម គេមានណែនាំដែរ ។

ស.ស៖ ការបង្រៀននោះមានដែលប្រើពាក្យថា ដើម្បីយកទៅវាយវៀតណាមទេ?

ញ.អ៖ កាលនោះអត់មាននិយាយទេ តែសំខាន់ដើម្បីពង្រឹងស្មារតីទឹកចិត្ត ដើម្បីការពារបូរណភាពទឹកដីតែម្តង ។

អេហ្វ.អិល៖ នៅពេលដែលហាត់នៅតាខ្មៅ តើគេមាននិយាយពីខ្មាំងរបស់បដិវត្តន៍ទេ?

ញ.អ៖ កាលនោះ ការអប់រំអត់ទាន់មានអ្វីទាំងអស់ ។ សំខាន់ គឺហាត់តែបច្ចេកទេស ទឹកដី សំខាន់ គឺការការពារព្រំដែន និងប្រឆាំងនឹងចក្រពត្តិតែម្តង ។

អេហ្វ.អិល៖ នៅពេលហាត់នៅតាខ្មៅ តើលោកមានដែលថ្នាក់លើទៅមើលទេ?

ញ.អ៖ ថ្នាក់លើខ្ញុំមានឃើញតែតា ណាត និង សុន សេន ។

អេហ្វ.អិល៖ ពេល សុន សេន ទៅដល់កន្លែងហាត់នៅតាខ្មៅ តើ សុន សេន មាននិយាយអ្វីទេ?

ញ.អ៖ ការផ្តាំផ្ញើរបស់គាត់ គឺឲ្យកុមារខិតខំការរៀនសូត្រពីបញ្ហាបច្ចេកទេសទាំងអស់ ដើម្បីឲ្យក្លាយជាកុមារឈាននៅពេលនោះ ។

អេហ្វ.អិល៖ លោកនិយាយពីគណកម្មាធិការមជ្ឈិម តើលោកដឹងតាំងពីពេលនោះមក ឬក៏ក្រោយមក?

ញ.អ៖ កាលនោះមានឮតែគណកម្មាធិការមជ្ឈិមបក្សនៅពេលប្រជុំ ។

ស.ស៖ តើលោកទៅដល់ប្រទេសចិននៅពេលណា?

ញ.អ៖ ខ្ញុំមិនដឹងខែ មិនដឹងថ្ងៃទេ ។ ខ្ញុំធ្វើដំណើរតាមនាវា ហើយតាមឡាន ។ ពេលខ្ញុំទៅដល់ចិន គេពិសោធន៍យើង ដូចថាគេឲ្យយើងគេងគ្រែតូចមួយ ដើម្បីចង់ដឹងថា កុមារល្អ មិនល្អ ។ គេឲ្យយើងបត់ភួយ ដើម្បីចង់ដឹងថា យើងឧស្សាហ៍ ឬមិនឧស្សាហ៍ ។ កាលនោះការបត់ភួយ ខ្ញុំទទួលបានចំណាត់ថ្នាក់លេខមួយ ។ និយាយរួមសីលធម៌ខ្ញុំបានលេខមួយ ។ ការចាប់ផ្ដើមរៀនទីមួយគឺការថតរូបធម្មតា ថតកុន បញ្ចាំងកុន គូសផែនទី និងផ្តិតរូបធម្មតា ដែលមានរយៈពេលប្រាំមួយខែ ។

[១៥:១៣:៣៧]

ស.ស៖ អ្នកណាជាអ្នកបង្រៀន?

ញ.អ៖ អ្នកបង្រៀនជាជនជាតិចិន តែគាត់និយាយភាសាខ្មែរ តែក៏មានការបកប្រែខ្លះដែរ ។

ស.ស៖ រៀនរយៈពេលប៉ុន្មាន?

ញ.អ៖ រៀនប្រាំមួយខែ រៀនទាំងអស់ ។

ស.ស៖ ពេលនោះនៅពេលប៉េកាំង?

ញ.អ៖ ខ្ញុំមិនដឹង គេគ្រាន់តែថា នៅប្រទេសចិន តែខ្ញុំដឹងថាមិនមែននៅប៉េកាំងទេ ។

អេហ្វ.អិល៖ អ្នកដែលទៅរៀនថតជាមួយលោកមានប៉ុន្មាននាក់?

ញ.អ៖ កាលនោះធ្វើដំណើរទៅរួមគ្នា តែពេលទៅដល់ចិន គេបំបែកផ្នែកទាំងអស់ ខ្លះទៅខាងគីមី ខាងនាវា ខាងជីវសាស្ត្រ មានតែខ្ញុំទេទៅរៀនខាងថតរូប ។

អេហ្វ.អិល៖ អ្នកណា ដែលធ្វើការបកប្រែពីខ្មែរទៅចិន ពីចិនទៅខ្មែរ?

ញ.អ៖ អ្នកបកប្រែ គឺខ្មែរយើង តែជនជាតិចិននោះក៏ចេះខ្មែរខ្លះដែរ ។

អេហ្វ.អិល៖ ក្នុងចំណោមសិស្ស ដែលរៀនមានជនជាតិផ្សេងទេ?

ញ.អ៖ អត់មានទេ មានតែខ្ញុំម្នាក់គត់ ។

ស.ស៖ ខាងកម្មាភិបាលខ្មែរ អ្នកណាជាអ្នកនាំទៅចិន?

ញ.អ៖ តាណាត ជាអ្នកជូនទៅដល់ចិនតែម្តង តែតា ណាត គាត់មិនធ្វើដំណើរ តាមនាវាទេ ។ ខ្ញុំជួប

គាត់នៅប្រទេសចិន ។
អេហ្វ.អិល៖ តាណាត នោះជាអ្នកណា?
ញ.អ៖ តាណាត មកពី៧០៣ ។
អេហ្វ.អិល៖ ដូច្នេះ តា ណាត គាត់ទៅចិនដែរ ។
ញ.អ៖ បាទ ។ កាលណោះ គាត់អគ្គសេនាធិការនាសម័យនោះ បន្ទាប់ពី សុន សេន ។
អេហ្វ.អិល៖ លោកទៅដល់ស្រុកចិន គាត់នៅទីនោះស្រាប់ មានន័យថា ក្នុងមួយខែ-- ក្នុងខែ១ ៧៦ តាណាតនៅស្រុកចិន?
ញ.អ៖ បាទ, គាត់ជាមនុស្សសំខាន់មួយ ក្នុងការរៀបចំកងទ័ព ។ គាត់ អតីតគាត់ជាប្រធានកងពល១២។
អេហ្វ.អិល៖ មានដឹងថា តា ណាត ត្រឡប់មកស្រុកខ្មែរវិញនៅពេលណា?
ញ.អ៖ ពេលមក-- ត្រឡប់មកជាមួយខ្ញុំដែរ តែខ្ញុំអត់បានជិះយន្តហោះទេ ។
ស ស៖ តើពេលណា-- តើពេលតា ណាត មានណែនាំឲ្យជួបកម្មាភិបាលចិន ឬស្ថាប័នចិនណាមួយទេ?
ញ.អ៖ អត់មានទេ ។ សំខាន់ការណែនាំរបស់គាត់ គឺឲ្យយើងប្រឹងរៀនសូត្រ និយាយរួមការរៀនសូត្រកុំឲ្យធ្វេសប្រហែសច្រើនដង ខ្ញុំជួបឯកអគ្គរាជទូតចិននៅស្រុកខ្មែរម្តង នៅស្រុកចិន គាត់ឈ្មោះ សុន ហៅ ។
ស ស៖ សុន ហៅ ជួបលោកក្នុងន័យអ្វី?
ញ.អ៖ គាត់ជួបនៅឆ្នាំ៧៦ គាត់មកជួបដើម្បីសរសើរកុមារឈានមុខ និងកុមារល្អ កាលណោះ គេឲ្យមេដៃខ្ញុំមួយ មានរូបប្រធាន ម៉ៅ នៅកណ្តាល តែខ្ញុំបាត់អស់ហើយ ។
អេហ្វ.អិល.៖ នៅពេលណាលោកត្រឡប់មកស្រុកខ្មែរវិញ?
ញ.អ៖ ខ្ញុំមកដល់ភ្នំពេញ អត់ទាន់បានចូលធ្វើការនៅ ស-២១ ទេ ។ ខ្ញុំនៅមន្ទីរអគ្គសេនាធិការភ្នំពេញ គឺខ្ញុំដើរថត ។ ខ្ញុំមកដល់អាចនៅចុងឆ្នាំ៧៦ ឬក៏ដើមឆ្នាំ៧៧ ។
[១៥:១៧:២៨]
ស ស៖ ពេលដែល សុន ហៅ មកមើលលោករៀន តើមានកម្មាភិបាលខ្មែរយើងមកដែរ?
ញ.អ.៖ មានគណៈប្រតិភូខ្មែរយើងមកច្រើនដែរ ខ្ញុំអត់ចាំទេ តែខ្ញុំមានរូបថតដែរ ។
អេហ្វ.អិល៖ លោកមានប្រសាសន៍ពីរូបថតកាលជំនាន់នោះ តើលោកអាចឲ្យខ្ញុំមើលបានទេ?
ញ.អ.៖ ខ្ញុំអត់បានយកមកទេ តែខ្ញុំយកសៀវភៅដែលខ្ញុំទៅរៀននៅចិន និងរូបថតខ្ញុំទៅរៀននៅចិន ។

អេហ្វ.អិល.៖ តើឯកសារអស់នេះ លោកអាចផ្តល់ឲ្យយើងថតចម្លងបានទេ?
ញ.អ.៖ បើតុលាការត្រូវការខ្ញុំមិនបដិសេធទេ ។ តែចាំខ្ញុំយកទៅធ្វើឲ្យ ។
ស ស៖ លោកថាមានសល់រូបថតពេលគណៈប្រតិភូទៅជួបលោកនៅចិន?
ញ.អ.៖ អត់មានទេ ។ ខ្ញុំមានតែរូបថត តាណាត ។ ខ្ញុំមានរូបថតពីរពាន់សន្លឹក ។
ស ស៖ តើលោកធ្វើអ្វីពេលលោកមកដល់ស្រុកខ្មែរ?
ញ.អ.៖ ខ្ញុំមកនៅអគ្គសេនាធិការភ្នំពេញ នៅពេទ្យមុនីវង្ស ។
អេហ្វ.អិល.៖ នៅពេលនោះពេទ្យមុនីវង្ស គេប្រើជាអ្វី?
ញ.អ.៖ ពេលនោះគេហៅពេទ្យ ព-៩៨ ជាពេទ្យរបស់អគ្គសេនាធិការកងទ័ព ។
អេហ្វ.អិល៖ តើលោកធ្វើអ្វីនៅពេទ្យនោះ?
ញ.អ.៖ ខ្ញុំមិនមែននៅពេទ្យទេ តែនៅជិតកន្លែងនោះ ។
អេហ្វ អិល៖ តើលោកធ្វើអ្វីនៅជិតពេទ្យនោះ?
ញ.អ.៖ កាលនោះចាប់ផ្តើមធ្វើកន្លែងរោងពុម្ពៗដែលធ្វើកាសែតទស្សនាវដ្តី ។
អេហ្វ.អិល៖ តើអ្នកណាប្រធានលោកកាលណោះ?
ញ.អ.៖ ប្រធានខ្ញុំមានពីរនាក់ ម្នាក់នោះឈ្មោះតា ប៉ង់ ។ គាត់គឺជាភ្នាក់ងារពិសេសរបស់ ប៉ុល ពត ហើយម្នាក់ទៀតឈ្មោះ នឿន គាត់នៅជាប់ជាមួយ សុន សេន ដែរ តែខ្ញុំមិនដឹងគាត់ទៅណាអស់ ហើយសព្វថ្ងៃនេះ ។
អេហ្វ.អិល៖ តើ នឿន តួនាទីជាអ្វី?
ញ.អ.៖ តាមពាក្យអង្គការគេហៅថា នីរសារក្រុង ។
[១៥:១៩:៥១]
អេហ្វ.អិល៖ តើការងារនីរសាក្រុងធ្វើអ្វី?
ញ.អ.៖ បើប្រៀបទៅដូច ហ៊ឹង ប៊ុនហៀង ប្រធានអង្គរក្ស ហ៊ុន សែន សព្វថ្ងៃនេះ ។
ស ស៖ ប៉ង់ ជានីរសារក្រុងដូច នឿន ដែរ?
ញ.អ៖ ពួកនោះជាអ្នកពិសេសរបស់អង្គការហើយ តែ ប៉ង់ កាលណោះមានតួនាទីធំជាង នឿន ប៉ង់ នោះហើយជួយឲ្យខ្ញុំរស់នៅ រស់ដល់សព្វថ្ងៃនេះ ។ កាលណោះ ខែកញ្ញា ឆ្នាំ១៩៧៧ បក្សកុម្មុយនីស្តកម្ពុជាប្រកាសថា ជាបក្សកុម្មុយនីស្តពេញសិទ្ធិនៅលើពិភពលោក ។

អេហ្វ.អិល៖ តើលោកធ្វើអ្វីកាលណោះ?

ញ.អ៖ ការងារខ្ញុំ គឺថតពេលប្រជុំថ្នាក់ដឹកនាំ ប្រជុំសភា ប្រជុំកងទ័ព និងពេលមានគណៈ ប្រតិភូបរទេសមក គឺខ្ញុំជាអ្នកថត ។

អេហ្វ.អិល៖ តើលោកមានដែលចេញទៅក្រៅភ្នំពេញ ដើម្បីថតរូបទេ?

ញ.អ៖ ខ្ញុំទៅថតតាមភូមិភាគដែរ ។ ខ្ញុំច្រើនទៅភូមិភាគនិរតី ពាយ័ព្យ ឧត្តរ និងបស្ចិម ។

អេហ្វ.អិល.៖ តើលោកទៅថតរូបប្រភេទណា? ហើយលោកឃើញអ្វីខ្លះ?

ញ.អ៖ ខ្ញុំថតពេលថ្នាក់ដឹកនាំចុះទៅមើលការលើកទំនប់ ប្រឡាយ តើការងារជឿនលឿន ឬមិនជឿនលឿន ។

អេហ្វ.អិល៖ អ្នកដឹកនាំដែលលោកចុះទៅនោះមានអ្នកណា?

ញ.អ.៖ ចួនកាលមានអ៊ំ ប៉ុល ពត, នួន ជា, សុន សេន, ចួនកាលមាន ខៀវ សំផន ហើយចួនកាលមានជួបជាមួយគណៈភូមិភាគដូចជា តា ម៉ុក ។

អេហ្វ.អិល.៖ ពេលជួប ពេលលោកជួបជាមួយ នួន ជា តើលោកទៅថតនៅខេត្តណា?

ញ.អ.៖ រូបថតខ្ញុំថត នួន ជា គឺពេលគាត់ទៅមើលប្រឡាយ ទំនប់ នៅភូមិភាគ បស្ចិម ប្រហែលជាឆ្នាំ ១៩៧៧ ។

អេហ្វ.អិល.៖ ចុះ ខៀវ សំផន ទៅកន្លែងណាដែរ?

ញ.អ.៖ គាត់មិនសូវទៅតាមជនបទទេ ព្រោះគាត់ធ្វើការខាងគណៈប្រតិភូរដ្ឋ ខ្ញុំកម្រឃើញគាត់ ទៅតាមជនបទណាស់ ។

ស ស៖ ដូច្នេះ លោកធ្លាប់ថត ខៀវ សំផន នៅភ្នំពេញ?

[១៥:២២:២២]

ញ.អ.៖ ខ្ញុំថតគាត់ពីរដង នៅបូរីកីឡាម្តង និងសាលចតុមុខនេះម្តង ។

ស ស៖ ថតនៅបូរីកីឡា តើថតឆ្នាំណា? ក្នុងពិធីអ្វីដែរ?

ញ.អ.៖ ដូចជាក្នុងពិធី១៧ មេសា ឬបុណ្យខួបបក្សជាដើម ។

អេហ្វ.អិល៖ មានដែលជួបលោក ខៀវ សំផន ទៅខេត្តហើយថតគាត់ទេ?

ញ.អ.៖ មានដែរ ខ្ញុំថតថ្នាក់ដឹកនាំទូទាំងប្រទេសទៅហើយ វាច្រើនពេក ។

អេហ្វ.អិល.៖ តើលោកមានចាំថា នៅខេត្តណាមួយទេ?

ញ.អ៖ កាលណោះ មានការប្រជុំពិសេសមួយនៅកោះធំ មានរូបថតមួយដែល ខៀវ សំផន កំពុងឈរ និងរូប អៀង សារី អង្គុយ ហើយមានម៉ាស៊ីនថតកុន នៅខាងក្រោយ ។

ស សៈ តើក្នុងពិធីអ្វីដែរនៅ កោះធំ នោះ?

ញ.អ៖ នៅសហករណ៍ នៅឆ្នាំ៧៧ ដើម៧៨ កាលណោះខ្ញុំធ្វើការទួលស្លែងផង តែពេលខ្ញុំថត នៅទួលស្លែង ផុតពីការងារទំនេរ គេអញ្ជើញខ្ញុំទៅ ដូចជាមានគណៈប្រតិភូចិនមក ។

ស សៈ ពេលថតនៅបូរីកីឡា តើថតនៅឆ្នាំណា?

ញ.អ៖ ឆ្នាំ៧៧ ។

ស សៈ ចុះនៅចតុមុខ ក្នុងពិធីអ្វី? ហើយនៅឆ្នាំណា?

ញ.អ.៖ កាលណោះ ជាពិធីប្រកាសគណៈប្រធានរដ្ឋយ៉ាងម៉េចមិនដឹងទេ ខ្ញុំភ្លេចហើយ រឿងឆ្នាំនោះខ្ញុំភ្លេចហើយ ។

ស សៈ ក្រៅពីថ្នាក់ធំៗ តើលោកមានថតនរណាទៀតទេ ដូចជា អៀង សារី, អៀង ធីរិទ្ធិ?

ញ.អ៖ មានៗច្រើន បើខ្ញុំឃើញរូបថត ខ្ញុំស្គាល់ ទោះខ្ញុំមិនចាំអស់ក៏ខ្ញុំស្គាល់ដែរ ។

អេហ្វ.អិល៖ ឧទាហរណ៍ដូចជា អៀង សារី តើលោកមានដែលថតរូបគាត់ពេលប្រជុំ ឬទៅតាមខេត្តណាមួយទេ?

ញ.អ៖ អៀង សារី ភាគច្រើនពេលនៅជាមួយប្រតិភូបរទេស តែអ្នកថតមានផ្សេងគ្នា អ្នកនៅខាងអគ្គ-សេនាធិការផ្សេង ហើយនៅខាង អៀង សារី មានអ្នកថតរូបគេផ្សេង តែពេលផ្តិត ពេលខ្លះខ្ញុំគឺជាអ្នកផ្តិត ការងារខ្លះគេមិនឲ្យយើងដឹងទេ ។

អេហ្វ.អិល៖ ដូច្នេះការងារលោក គឺអ្នកផ្តិតរូបនៅជិតមន្ទីរពេទ្យយោធា?

[១៥:២៤:៥៥]

ញ.អ៖ បាទ ។

អេហ្វ.អិល៖ លោកមានចាំទេ អ្នកណា អ្នកថតរូប អៀង សារី?

ញ.អ៖ ខ្ញុំមិនចាំទេ ។ ខ្ញុំនៅក្នុងមន្ទីរ ៦២(ក) គឺនៅជាប់ជាមួយអង្គការតែម្តង វាជាផ្នែកនៃមន្ទីរ ៨៧០ ធំជាងគេ ហើយគេមានបែងចែកជាមន្ទីរផ្សេងៗទៀត ។

អេហ្វ.អិល៖ មានដឹងអ្នកណានៅ៨៧០ អ្នកណាជាអ្នកប្រធាន?

ញ.អ៖ បើនិយាយរួម តា ប៉ុល ពត នោះជាប្រធាន ហើយមន្ទីរ៨៧០ ធំជាងគេនៅស្រុកខ្មែរ ។

ស សៈ លោកធ្លាប់ថតរូបរបស់ អៀង សារី ផ្ទាល់ ឬក៏ផ្តិតរូបគាត់?

ញ.អៈ ខ្ញុំភាគច្រើនផ្តិតរូបរបស់គាត់ ។

ស សៈ ចុះ អៀង ធីរិទ្ធិ?

ញ.អៈ ខ្ញុំធ្លាប់ផ្តិតដែរ ដែលខ្ញុំស្គាល់មុខច្បាស់មានតែ សុន សេន, ប៉ុល ពត, ខៀវ សំផន, នួន ជា តែប្រពន្ធៗគេ ខ្ញុំមិនអាចដឹងបានអស់ទេ វាច្រើនពេក ។

ស សៈ ដូច្នេះអ្នកថតជាមួយលោកមានប៉ុន្មាននាក់?

ញ.អៈ មានប្រាំមួយនាក់ ។ ប្រាំមួយនាក់នោះមានម៉ាស៊ីនប្រាំមួយ អ្នកណាថត អ្នកនោះផ្តិតនិង លាង ។ អ្នកថតមាននាទីខុសគ្នាទាំងអស់ ។

ស សៈ សូមរៀបរាប់ពីឈ្មោះអ្នកដែលថតជាមួយលោក?

ញ.អៈ ពេលនៅជិតពេទ្យមុនីវង្សនោះមានតែខ្ញុំម្នាក់ឯង ។

អេហ្វ.អិលៈ ពេលណាលោកទៅ ស-២១?

ញ.អៈ ខ្ញុំមិនចាំថ្ងៃដែរ តែក្នុងដើមឆ្នាំ៧៧ ។

អេហ្វ.អិលៈ អ្នកណាចាត់តាំងលោកទៅ?

ញ.អ.ៈ កាលនោះមាន សុន សេន មានតា ណាត ព្រោះកាលខ្ញុំទៅចិនក៏មានតា ណាត និង សុន សេន ដែរ ហើយការងារក៏គាត់អ្នកចាត់ឲ្យធ្វើដែរ ។

អេហ្វ.អិលៈ លោកមានបានដឹងទេ ហេតុអ្វីគេឲ្យលោកទៅធ្វើនៅស-២១?

ញ.អៈ ខ្ញុំអត់ដឹងដែរ ព្រោះជាការងាររបស់អង្គការ ។ ការងារថតរូបនៅស-២១ គឺមានពីរផ្នែក។ ទីមួយ គឺថតអ្នកទោសនៅ ស-២១ ទីពីរ ពេលទំនេរខ្ញុំទៅថតនៅខាងក្រៅ ។

[១៥:២៧:១៩]

ស សៈ ពេលនៅជិតពេទ្យមុនីវង្ស តើក្រៅពី ប៉ង់ និង នឿន តើនរណាផ្សេងទៀត?

ញ.អៈ អត់មានទេ ខ្ញុំតែម្នាក់ឯង ។

ស សៈ លោកនៅជិតពេទ្យមុនីវង្សប៉ុន្មានឆ្នាំដែរទើបទៅ ស-២១?

ញ.អៈ ខ្ញុំមិនចាំទេ តែដឹងថានៅដើមឆ្នាំ៧៧ ខ្ញុំចូលទៅ ស-២១ តែម្តង ។

អេហ្វ.អិលៈ លោកធ្វើការប៉ុន្មានខែនៅជិតពេទ្យមុនីវង្ស?

ញ.អៈ ប្រហែលជាបី ទៅបួនខែប៉ុណ្ណោះ ព្រោះធ្លាក់ខ្យល់ ហើយប្រហែលជាខែដប់មួយ ដប់ពីរហ្នឹង ។

ស សៈ ពេលលោកមក ស-២១ តើលោកនៅក្រោមការដឹកនាំរបស់អ្នកណា? ហើយនៅអគារណា?

ញ.អៈ ខ្ញុំនៅផ្ទះថ្មសព្វថ្ងៃជាស្ថានទូត ហុងហ្គារី នៅទល់មុខក្រសួងផែនការ ។

អេហ្វ.អិលៈ អ្នកណាដែលនៅផ្ទះជាមួយលោក?

ញ.អៈ នៅរួមគ្នាប្រាំមួយនាក់ ជាងថតរូបទាំងអស់ ។

អេហ្វ.អិលៈ សូមលោករៀបរាប់ពីការងារប្រចាំថ្ងៃនៅ ស-២១?

ញ.អៈ គេមានគោលការណ៍របស់គេ ព្រឹកឡើងម៉ោងប្រាំមួយកន្លះ យើងមកដល់កន្លែងហូបបាយរួមហូបបបរ ហើយម៉ោងប្រាំពីរយើងចូលធ្វើការ ។ យើងថតអ្នកទោសដែលមកដល់ ហើយសម្រាកម៉ោងដប់មួយ ហើយម៉ោងប្រាំចេញ តែក្រោយពីនោះអត់មានធ្វើអ្វីទេ យើងឆ្លៀតដាំស្លែសម្រាប់ខ្លួនឯង ។

អេហ្វ.អិល.ៈ លោកនិយាយថាការងារស្នូលចាប់ផ្តើមពីម៉ោងប្រាំពីរ តើធ្វើអំពីអ្វី?

ញ.អៈ យើងថតរូបអ្នកទោស ពេលត្រឡប់មកវិញ យើងលាងហ្វីល និងផ្តិតខ្លួនឯង ។

អេហ្វ.អិលៈ តើអ្នកទោសមកដល់ពេលណា?

ញ.អៈ អត់ទៀង តែអ្នកថតប្រាំមួយនាក់ គឺចែកវេនគ្នាថត ។

អេហ្វ.អិលៈ នៅពេលនោះ តើអ្នកទោសមក ស-២១ រាល់ថ្ងៃ?

ញ.អៈ បើនិយាយពីអ្នកទោស គឺមករាល់ថ្ងៃ គ្រាន់តែតិច និងច្រើនប៉ុណ្ណោះ ។

អេហ្វ.អិលៈ លោកនិយាយថា ក្រុមលោកមានប្រាំមួយនាក់ ។ តើអ្នកណាប្រធាន? ហើយឋានៈលោកអ្វីដែរ?

ញ.អៈ កាលណោះ ស្រៀង ប្រធានក្រុម ហើយខ្ញុំជាប្រធានពួក ។ ស្រៀង គេក្តាប់ពីរនាក់ ហើយខ្ញុំក្តាប់ពីរនាក់ ទាំងអស់មានប្រាំមួយនាក់ តែ ស្រៀង ប្រធានធំជាងគេ ។

អេហ្វ.អិលៈ លោកទទួលបញ្ជាពីអ្នកណា?

ញ.អៈ កាលនោះមាន សុន សេន, តា ណាត កាលនោះក៏មាន ឌុច ដែរ គាត់ប្រធាន ស-២១ ។

អេហ្វ.អិលៈ អ្នកដែលបញ្ជាលោកផ្ទាល់ ជាអ្នកណា?

ញ.អៈ ឌុច អ្នកបញ្ជាផ្ទាល់ ហើយគាត់មើលការខុសត្រូវទាំងអស់នៅក្នុងនោះ ។

អេហ្វ.អិលៈ តើលោកមានចាំបញ្ជារបស់ ឌុច ចំពោះលោកទេ?

ញ.អៈ ការបញ្ជារបស់គាត់ គឺនឹង ម៉ឺងម៉ាត់តែម្តង បើខ្ញុំធ្វើខុសអ្វីមួយគឺមិនបាន ។

អេហ្វ.អិល៖ លោកបានឮ ឌុច ប្រើពាក្យអស់នេះ?

ញ.អ៖ បាទ ។

អេហ្វ.អិល៖ លោកនិយាយថា តែឌុចបញ្ជាឲ្យធ្វើអ្វី គឺត្រូវធ្វើឲ្យបាន បើសិនជាខុសលោកថា មានបញ្ហា តើបញ្ហានោះយ៉ាងម៉េច?

ញ.អ៖ បញ្ហានោះគឺបញ្ហាអាយុជីវិតតែម្តង ព្រោះជាចម្បងអាយុជីវិតទីមួយហើយទីពីរការងារ គឺប្រុងប្រយ័ត្នជាទីបំផុត មិនឲ្យខូចដាច់ខាត ។

អេហ្វ.អិល៖ ឌុច បញ្ជាមកលោកហាក់ដូចជាការគំរាមកំហែង?

ញ.អ៖ វាគឺជាការពិត ព្រោះការងារនៅស-២១ អ្នកដែលមកតាំងពី៧៥ មកពីកំពង់ឆ្នាំងនោះ បានបាត់បង់ជីវិតនៅស-២១ នោះច្រើនណាស់ ភាគច្រើនអ្នកយាមដែលយាមងោក នោះគេយកទៅវ៉ៃចោល ដូចជា ចន ហើយមួយទៀត ស្រ៊ុន នោះមកជាមួយខ្ញុំដែរ ។ ពេលគាត់យកស្លៃដែលស្រោចអង់ទ្រីនហើយលាងមិនជ្រះ ពេលគាត់យកទៅស្ល លាងអត់ជ្រះ វាធុំក្លិន ។ គេចោទថាគាត់ដាក់ថ្នាំបំពុល ហើយគេយកទៅវ៉ៃចោលទាំងអស់ ។

អេហ្វ.អិល៖ តាមលោកយល់អ្នកណាដែលទទួលខុសត្រូវចំពោះការស្លាប់របស់អ្នកទាំងនោះ?

ញ.អ៖ និយាយឲ្យខ្លីគឺតា ឌុច ព្រោះនៅស-២១ មិត្តភក្តិខ្ញុំដែលមកពីស្រុកភូមិជាមួយខ្ញុំនោះបាត់ច្រើនណាស់ ។

អេហ្វ.អិល៖ លោកសំអាងទៅលើអ្វីដែលថា ឌុច ជាអ្នកទទួលខុសត្រូវ?

[១៥:៣២:២៤]

ញ.អ៖ តាមដែលខ្ញុំដឹង ព្រោះវាបទបញ្ជារបស់គាត់តែម្តង ។ ព្រោះអ្នកស-២១ មានការបាត់ច្រើនណាស់ ក្នុងនោះប្រហែលជា៤០០នាក់ មានបាត់អស់១៥០នាក់ហើយ ។

ស.ស៖ តើ ឌុច មានណែនាំពីការថតដល់លោកទេ?

ញ.អ៖ អត់ទេ សំខាន់ការណែនាំរបស់គាត់ គឺថាកុំឲ្យខូច ពេលយើងថតហើយ ត្រូវបញ្ជូនទៅឲ្យ ធី ។ តែការធ្វើនោះកម្រខូចណាស់ ព្រោះខ្ញុំប្រយ័ត្នជាទីបំផុត ។

ស.ស៖ ពេលដែលលាងហ្វីលនោះ តើលោកលាងនៅឯណា?

ញ.អ៖ ខ្ញុំយកទៅលាងនៅមុខក្រសួងផែនការ ។

ស.ស៖ សូមលោករៀបរាប់ពីការថត ចាប់តាំងពីការនាំអ្នកទោសចូលមក ហើយការដាក់ស្លាកចំណាំ

អ្នកទោស ។

ញ.អ៖ ដូចថាគេដឹកឡានមក ពេលនោះអ្នកទោសគេចងមុខ ហើយអ្នកនាំយកមកឱ្យយើងគេស្រាយមុខ។

ស.ស៖ អ្នកណាដែលស្រាយមុខនោះនរណាគេ?

ញ.អ៖ អ្នកយាមគេអ្នកស្រាយមុខ ។

អេហ្វ.អិល៖ កន្លែងថតនៅកន្លែងណា?

ញ.អ៖ នៅទល់មុខផ្លូវចូលទួលស្លែងសព្វថ្ងៃ ។ នៅខាងក្រៅរបងទួលស្លែង តែកន្លែងលាងហ្វីលនៅជិតផ្ទះតា ឌុច ។ ថតអ្នកទោសមុនបញ្ចូលទៅចូលគុក ។

អេហ្វ.អិល៖ តើលោកមានដឹងថា អ្នកទោសគេបញ្ជូនមកពីណាទេ?

ញ.អ៖ អត់ដឹងទេ ។

អេហ្វ.អិល៖ ឡានដែលដឹកមកនោះ តើជាឡានរបស់ស-២១?

ញ.អ៖ យើងពិបាកពិពណ៌នាដែរ ឡានគេមានដាក់ឡានភូមិភាគបស្ចិម ពាយ័ព្យ យើងអត់ដឹង។ ចួនកាលគេអត់ដាក់ស្លាក ចួនកាលគេដឹកតាមឡានតូច ។ ឡានរបស់ ស-២១ ក៏មានដែរ ។

អេហ្វ.អិល៖ និយាយពីឡានរបស់ស-២១ ក្នុងពេលឡានចេញទៅយកអ្នកទោស តើអ្នកណា ចេញទៅយកអ្នកទោស?

ញ.អ៖ យើងមិនអាចដឹងបានទេ គេមានផ្នែកៗគ្នា វាច្រើនណាស់ តែខ្ញុំអ្នកថត គឺដឹងតែថត ។

[១៥:៣៥:០០]

អេហ្វ.អិល៖ មានដែលឃើញ ឌុច នៅក្នុងឡានដែលគេនាំអ្នកទោសមកទេ?

ញ.អ៖ យើងមិនបានសង្កេតមើលដែរ ។

ស.ស៖ ពេលថត តើគេមានដាក់ឈ្មោះឱ្យអ្នកទោសដើម្បីឱ្យ ធី ស្រួលចំណាំទេ?

ញ.អ៖ យើងចង់និយាយថា ពេលថតគេមានលេខចំណាំគេ ។ ចួនកាលគេដាក់ឈ្មោះ ចួនកាលគេមានលេខ ចួនកាលក៏អត់មានដាក់លេខដែរ ហើយលេខរបស់អ្នកទោសគឺផ្លាស់ប្តូរតាមថ្ងៃ ហើយថ្ងៃក្រោយមកទៀត គឺចាប់ផ្តើមលេខថ្មីឡើងវិញ ។

ស.ស៖ តើមានអ្នកជួយរៀបចំស្លាក រៀបចំឯកសារទេ?

ញ.អ៖ ចួនកាលខ្ញុំរៀបចំខ្លួនឯងអត់មានអ្នកជួយទេ ។

ស.ស៖ តើលោកចំណាំរបៀបម៉េច?

ញ.អ៖ អត់មានអ្វីពិបាកទេ ដូចថាអ្នកទោសចូល១០០នាក់ រូបថត១០០ សន្លឹកដែរ ដាក់តែលេខដូចថា ឈ្មោះក លេខ១, ឈ្មោះខ លេខ២ ។
ស.ស៖ បានន័យថា អ្នកនាំមកអត់មានឲ្យបញ្ចើមកលោកទេ?
ញ.អ.៖ អត់មានឲ្យទេ ហើយឲ្យទៅ ធី តែម្តង ។
អេហ្វ.អិល៖ អ្នកទោសដែលនាំមកទាំងអស់ត្រូវថតរូបទាំងអស់?
ញ.អ៖ ភាគច្រើនថត មានតិចទេដែលអត់បានថត ។
អេហ្វ.អិល៖ ហេតុអ្វីបានអត់ថត?
ញ.អ៖ ចួនកាលយើងដល់យប់ជ្រៅ យើងអត់បានថត ។ ចួនកាលគេឲ្យយើងថតដល់បន្ទប់ តែកម្រណាស់។ អ្នកទោសត្រូវតែថតរូបទាំងអស់ ។
អេហ្វ.អិល៖ តើក្រៅពីថតអ្នកទោស លោកមានដែលថតក្នុងបរិវេណគុក ស-២១ ទេ?
ញ.អ៖ បរិវេណគុក គេមិនឲ្យខ្ញុំចូលទេ ។
អេហ្វ.អិល៖ មានដែលធ្លាប់ថតរូបអ្នកទោសក្រោយពីគេសម្លាប់ហើយទេ?
ញ.អ៖ ខ្ញុំអត់ដែលទេ តែគេមានក្រុមពិសេសគេមួយទៀត គឺឈ្មោះ ស្រ៊ុ គាត់នោះនៅកងការពារ ពិសេស ពេលមានអ្នកស្លាប់ គាត់គឺជាអ្នកថត ។
អេហ្វ.អិល៖ តើការថតរូបអ្នកស្លាប់ហើយញឹកញាប់ទេ ។
[១៥:៣៧:៣៧]
ញ.អ៖ មានញឹកញាប់ដែរ ។ ពេលគេថតហើយ គេឲ្យយើងផ្តិត តែមិនឲ្យប្រាប់អ្នកផ្សេងទេ ។
អេហ្វ.អិល៖ តើហេតុអ្វីបានគេថតរូបអ្នកដែលស្លាប់ហើយ?
ញ.អ៖ បើតាមខ្ញុំដឹង ប្រហែលគ្រាន់តែជាការកត់សម្គាល់ តែ ស្រ៊ុ នោះ ប្រហែលជាស្លាប់ ហើយតា ឌុច ជាអ្នកសម្លាប់ ។ ខ្ញុំដឹងថាស្រុកកំណើតគាត់នៅស្រុកបាទី ខេត្តតាកែវ មិនដឹងភូមិឃុំទេ ។
អេហ្វ.អិល៖ អ្នកណាបញ្ជាឲ្យថតអ្នកដែលស្លាប់ហើយ ។
ញ.អ៖ មានតែ ឌុច ទេ ។
អេហ្វ.អិល៖ ហេតុអ្វីលោកសន្និដ្ឋានដូច្នេះ?
ញ.អ៖ អ្នកស្លាប់នោះប្រហែលជាស្ងួរចម្លើយមិនទាន់អស់ ហើយទីពីរគឺការធ្វើទារុណកម្ម ព្រោះរូបថតមានបែកឈាម មានអី ។

អេហ្វ.អិល៖ តើលោកដឹងថា អ្នកណាបញ្ជា ឌុច?

ញ.អ៖ បើតាមខ្ញុំទៅប្រជុំពីមាត៌ារបស់អង្គការ គឺ សុន សេន ជាចម្បង ។ អានេះតាមដែលខ្ញុំឃើញនឹងភ្នែក ឬតាមគាត់មកប្រជុំសន្និបាតនៅស-២១។ ក្រៅពី សុន សេន អត់មានឃើញនរណាមកទេ។

អេហ្វ.អិល៖ ការទាក់ទង ឌុច និង សុន សេន តើ ឌុច សុំបញ្ជាពី សុន សេន ឬ សុន សេន ចេញបញ្ជាមក ឌុច?

ញ.អ៖ ការសម្រេចរបស់ ឌុច គឺរឿងមួយ ហើយការបញ្ជាពី សុន សេន គឺជាចរន្តតែម្តង ។ បើសរុបមកទាំងពីរនាក់នោះគឺស្មើគ្នាតែម្តង ។ បើ ឌុច មិនរាយការណ៍ទេ សុន សេន, ប៉ុល ពត, នួន ជា ក៏មិនដឹង ឯកសារទាំងអស់ គឺនៅលើ ឌុច ។ ឌុច គឺសំខាន់ណាស់ ។ ឌុច គឺជាអ្នកកំណត់ឈ្មោះអ្នកដែលត្រូវសម្លាប់ ។ គាត់ជាអ្នកឲ្យភ្លើងខៀវ ទៅឲ្យ សុន សេន និងប៉ុល ពត ។

ស.ស៖ អ្នកទោសសំខាន់ណាខ្លះដែលលោកបានថត ដូចជា កុយ ធួន, ហ៊ូ នឹម?

ញ.អ៖ ខ្ញុំមិនបានថតទេ គឺ ស្រ៊ី ជាអ្នកថត ។ គុកពិសេសគឺ ផ្ទះថ្មនៅខាងក្រៅស-២១ នោះ សម្រាប់ដាក់អ្នកទោសថ្នាក់តំបន់ ។ ខ្ញុំមិនដែលបានចូលទេ ។

អេហ្វ.អិល៖ តើ នួន ជា មានតួនាទីអ្វី?

ញ.អ៖ គាត់ជាប្រធានរដ្ឋសភា តែមិនមែនថាគាត់មិនដឹងទេ ។ គាត់ដឹង ព្រោះការចាប់ចងថ្នាក់ភូមិភាគ, តំបន់ សុទ្ធតែអ្នកសំខាន់ៗនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ។

[១៥:៤០:៤០]

អេហ្វ.អិល៖ តើតួនាទីសន្តិសុខ ក្រៅពី សុន សេន តើ នួន ជា យ៉ាងម៉េច?

ញ.អ៖ ខ្ញុំមិនដឹងទេ ។ តែបើ សុន សេន ក្នុងមួយអាទិត្យគាត់មក ស-២១ ម្តង ។

អេហ្វ.អិល៖ លោកមានដែលឮគេនិយាយពី នួន ជា ថាគាត់មានតួនាទីនៅស-២១ ទេ?

ញ.អ៖ ខ្ញុំឮពាក្យតា ឌុច និយាយថា បញ្ជូនទៅឲ្យបងទីមួយ, ទីពីរ ហើយខ្ញុំដឹងថា បងទីមួយប៉ុល ពត, បងទីពីរ នួន ជា ។ ស-២១ គឺជាមន្ទីរសន្តិសុខសំខាន់នៅក្នុងជាតិ ។ សុន សេន និយាយពេលប្រជុំជាមួយ ឌុច ថា ស-២១ គឺជាដួងព្រលឹងសំខាន់របស់ជាតិ ។ នួន ជា, ប៉ុល ពត មិនដែលឃើញ មកទេ ។ តែបើ សុន សេន ឃើញមកជាអចិន្ត្រៃយ៍តែម្តង ។

អេហ្វ.អិល៖ លោកនិយាយថា នៅ ស-២១ ក្រៅពី ឌុច មាន សុន សេន ហើយ សុន សេនមក ស-២១ ស្ទើររាល់អាទិត្យ តើ សុន សេន មករហូតដល់៧៩?

ញ.អ៖ សុន សេន គាត់មកនោះ គឺរហូតដល់វៀតណាមចូលតែម្តង ។ តាមខ្ញុំដឹង នៅ ស-២១ ឆ្នាំ៧៨ ខ្សោយអ្នកទោសហើយ ចូលតែម្នាក់ពីរនាក់ទេ ។ តែបើឆ្នាំ៧៧ គឺច្រើនតែម្តង ។ ចួនកាល២៤ ម៉ោងតែម្តង ។

ស.ស៖ លោកដែលថតជនជាតិអ្វីផ្សេងក្រៅពីខ្មែរទេ?

ញ.អ៖ ខ្ញុំបានថតម្តង ។ ជនជាតិពីរនាក់មកពីសមុទ្រ តែមិនមែនវៀតណាមទេ ។ តែខ្ញុំមិនដឹងជាបារាំង អាមេរិកទេ ។

ស.ស៖ តើពីរនាក់នោះសក់ពណ៌អ្វី?

ញ.អ៖ ខ្ញុំគ្រាន់តែដឹងថា មាឌធំ ច្រមុះស្រួច សក់ពណ៌ទង់ដែង ។

ស.ស៖ ពេលថតហើយ គេយកទៅណា?

ញ.អ៖ គាត់មានរោមទ្រូងច្រើន ហើយមានពុកមាត់ ។ តែខ្ញុំមិនដឹងគេយកទៅណាទេ ។ កាលនោះក្នុង ឆ្នាំ៧៧ ។

ស.ស៖ មានចាំឈ្មោះទេ?

ញ.អ៖ អត់បានចាំផង ។

ស.ស៖ លោកមានចាំឈ្មោះអ្នកថតផ្សេងៗនៅ ស-២១ ទេ?

ញ.អ៖ ១) ស្រ៊ាង ២) សុង ៣) នីត ៤) សំ ៥) រី ៦) គឺខ្ញុំ ។

[១៥:៤៣:៣៧]

ស.ស៖ ដឹងថានៅរស់ទេ?

ញ.អ៖ ខ្ញុំដឹងថាស្លាប់បីហើយ រី, សំ និងសុង ស្លាប់ហើយ ។ តែពីរនាក់ទៀតខ្ញុំមិនដឹងដែរ ។

ស.ស៖ តែ នីត នៅរស់ទេ?

ញ.អ៖ នៅរស់ពេលវៀតណាមចូល បីនាក់នោះស្លាប់ក្រោយវៀតណាមចូលទេ ។

ស.ស៖ លោកមានដែលថតចំជនជាតិព្នង ឬវៀតណាមទេ?

ញ.អ៖ មានដូចជាជនជាតិវៀតណាម ព្រោះកាលនោះវៀតណាមវ៉ៃចូលកម្ពុជាតាមព្រំដែន ។ ខ្ញុំសោក ស្តាយដែរ ខ្ញុំបាត់ការសែតវីដេអូអស់ហើយពីរឿងវៀតណាម ហើយអ្នកបកប្រែវៀតណាមគឺ ម៉ម ណៃ នៅម៉ាឡៃ ។

ស.ស៖ តើទាហានវៀតណាមនោះមកទាំងខោអាវ?

ញ.អ៖ បាទ ។
ស.ស៖ ចុះគិញវិញ លោកមើលដឹងយ៉ាងម៉េចដឹងថាវៀតណាម?
ញ.អ៖ ចុះបើនិយាយវៀតណាម ។
ស.ស៖ មានការលើកឡើងថា ខ្មែរក្រហមពាក់ខោអាវទាហានវៀតណាមឲ្យតើលោកយល់ថាមានទេ?
ញ.អ៖ អត់មានទេ ។ ព្រោះខ្មែរក្រហមអត់មានកាឡៃទេ ។ ខ្មែរក្រហមចង់ធ្វើអ្វីដែលពិត ។
ស.ស៖ លោកថា មានវីដេអូទាហានវៀតណាម តើវីដេអូអ្វី?
ញ.អ៖ ទាហានវៀតណាមដែលខ្ញុំចាប់បាននៅសៀមរាប ក្រោយ៧៩ ។
ស.ស៖ ទាហានវៀតណាម ដែលលោកថតនោះច្រើនទេ?
ញ.អ៖ ប្រហែលជា២០នាក់ ។
អេហ្វ.អិល៖ នៅពេលថតរូប តើ ឌុច មានដែលមកមើលលោកពេលថតរូបទេ?
ញ.អ៖ មានមកតែកម្រណាស់ តែពេលញ៉ាំបាយរួមជុំគ្នា មានគាត់មក ។
អេហ្វ.អិល៖ ពេល ឌុច មកគាត់មានដែលនិយាយអ្វីជាមួយលោកទេ?
ញ.អ៖ ការនិយាយគឺថាឲ្យប្រុងប្រយ័ត្ន កុំឲ្យខូចបាត់បង់ ព្រោះរូបថតសំខាន់ណាស់ សម្រាប់ធ្វើប្រវត្តិរូប សម្រាប់អត្តសញ្ញាណបណ្ណ ។
អេហ្វ.អិល៖ មានបញ្ហាអ្វីទេនៅពេលថតរូបនោះ ថតរូបខូច ឬមិនច្បាស់ តើលោកធ្លាប់ដែរមានបញ្ហានេះទេ?
ញ.អ៖ បើមានការខូចរូបថត គឺអត់រួចទេ គឺស្លាប់ ។ តែពេលខ្លះរូបថតខ្ញុំ ថតទៅបិទភ្នែក បើមានបិទភ្នែក ខ្ញុំត្រូវថតម្តងទៀត ។
ស.ស៖ ឧបមាថា រូបថតនោះខូច តើអ្នកណាជាអ្នកសម្រេចចាប់?
ញ.អ៖ តា ឌុច, តា ហ៊ី និង តា ចាន់ (ម៉ម ណៃ) នោះ ។
អេហ្វ.អិល៖ តើអះអាងលើអ្វីដែលលោកនិយាយដូច្នេះ?
ញ.អ៖ អានេះគឺការពិត ។ ការសម្រេច គឺបីនាក់នោះជាអ្នកសម្រេច ។ រឿងខ្ញុំមួយ ខ្ញុំផ្តិតរូបអ៊ំ ប៉ុល ពត ខូចហ្វិលនោះ ខូចចំភ្នែក ហើយខ្ញុំ ហើយនិង រី ក៏ដឹងរឿងនោះដែរ ។ ពេលនោះតា ហ៊ី, តាចាន់, តា ឌុច តេឡេហ្វូន មកខ្ញុំ ។ ពួកខ្ញុំថតរូប ក៏ប្រជុំគ្នា ហើយខ្ញុំរាយការណ៍ថា ខ្ញុំផ្តិតរូបអ៊ំទីមួយខូច បើមិនជឿសួរ រី ទៅ ។ ពេលនោះ រី ថា មិនដឹងមិត្ត អេន ផ្តិតពីពេលណាមកទេ ។ ពេលនោះ

គេដកខ្ញុំទៅចិញ្ចឹមទន្សាយ ។ ពេលនោះ ឆេន ដែលជានីរសាររបស់ ឌុច ប្រាប់ខ្ញុំថា ឌុច សួរ ប៉ង់ នាំពីរឿងនោះ ហើយ ប៉ង់ ថា ហ្វីលនោះមានខូចមួយសន្លឹក ក្រោយមកទើបគេឲ្យខ្ញុំមកវិញ ។

ស.សះ តើ ឆេន នោះនៅរស់ទេ?

[១៥:៤៧:៤៩]

ញ.អះ ខ្ញុំមិនដឹងថា ឆេន នៅរស់ ឬក៏ស្លាប់ទេ ។

ស.សះ ស្រុកកំណើតគាត់នៅកំពង់ឆ្នាំដែរ?

ញ.អះ ពួកនោះ មានតែពីរទេ បើមិននៅកំពង់ឆ្នាំងទេ កំពង់ស្ពឺ ។

ស.សះ ឆេន នោះលោកឃើញនៅរស់ពេលវៀតណាមចូល?

ញ.អះ បាទ ។

ស.សះ លោកថាទៅថតវិញម្តងទៀត តើថតនៅឯណា?

ញ.អះ អត់ទេ ថតវិញភ្លាម ព្រោះខ្ញុំដឹងថា បិទភ្នែក ។

ស.សះ លោកមានដែលទៅថតនៅព្រៃសទេ?

ញ.អះ ខ្ញុំធ្លាប់ទៅព្រៃស តែព្រៃសនោះមិនមែនជាគុកទេ ជាកន្លែងកសាង ហើយ ហ៊ុយ ស្រែ ជាប្រធាននៅព្រៃស ។

ស.សះ តើព្រៃសនោះ គេហៅលេខប៉ុន្មាន?

ញ.អះ ភ្លេចហើយ ។

ស.សះ លោកថាព្រៃសមិនមែនកន្លែងដាក់អ្នកទោសទេ ហេតុអ្វីបានលោកទៅថតដែរ?

ញ.អះ ទៅថតដែរ ព្រោះដើម្បីធ្វើប្រវត្តិរូប តែព្រៃសនោះក៏ជារបស់អគ្គសេនាធិការដែរ ។

ស.សះ រូបថតនៅព្រៃស ដែលមានមកដាក់នៅស-២១ទេ?

ញ.អះ អត់ដែលមានទេ ។

ស.សះ តើមាន ចាន់ ណាផ្សេងទៀត ដែលធ្វើការជាមួយ ម៉ម ណៃ ទេ?

ញ.អះ អត់មានទេ មានតែមួយនោះហើយ ។ តាចាន់ នោះកើតឃ្លង់ល្តៅ ។

(សម្រាកការស្តាប់ចម្លើយសាក្សីនៅម៉ោង១២ថ្ងៃត្រង់ ថ្ងៃខែឆ្នាំដដែល)

(ចាប់ផ្តើមការស្តាប់ចម្លើយសាក្សីនៅម៉ោង១និង៣០នាទីថ្ងៃត្រង់ ថ្ងៃខែឆ្នាំដដែល)

អេហ្វ.អិលះ ការដឹកនាំនៅទួលស្លែងមាននរណាឋានៈ និងតួនាទីដូចម្តេច?

ញ.អ៖ មេធំជាងគេគា ឌុច ប្រធាន គាត់ទទួលរួម ។ តា ហ៊ី អនុប្រធាន ទទួលរួមផ្នែកយោធា ។ ចាន់ សមាជិកទទួលផ្នែកបកប្រែ គេហៅថា គណៈស-២១ ។

ស.ស៖ ហ៊ុយ ស្រែ ជាសមាជិកស-២១ ឬ?

ញ.អ៖ មិនមែនទេ ។

[១៥:៥០:១៦]

អេហ្វ.អិល៖ អង្គភាពរបស់លោកនៅក្រោមអ្នកណាពិតប្រាកដ? ហើយអ្នកណាបញ្ជាផ្ទាល់លើអង្គភាពថតរូប?

ញ.អ៖ នៅក្រោមទាំងបី បញ្ជាផ្ទាល់ទាំងបីនាក់ ។ តែ ចាន់ ទទួលខុសត្រូវផ្ទាល់ ។

អេហ្វ.អិល៖ តើលោកទាក់ទងទៅ ឌុច ផ្ទាល់ឬទេ?

ញ.អ៖ បាទ ធ្លាប់ពេលគាត់ហៅទៅថតរូបគ្រួសារ ជប់លៀង ។

អេហ្វ.អិល៖ តើ ចាន់ បញ្ជាបែបណា?

ញ.អ៖ ដូចបាននិយាយពីខាងដើមអ៊ីចឹង គឺគាត់បញ្ជាដោយហ្មត់ចត់ ។

ស.ស៖ ពេលខ្លះទៅថតនៅក្រៅ តើញឹកញាប់ឬទេ? ថតអ្នកណា?

ញ.អ៖ មិនសូវជាញឹកញាប់ មួយម្តង ឬពីរដងក្នុងមួយខែ ។ ពេលចិនមកទស្សនកិច្ចរោងចក្រប្រេងកាត ឧស្សាហកម្ម កសិកម្ម អង្គរវត្ត ប្រព័ន្ធធារាសាស្ត្រ ពេលខ្លះគេហៅមកថត ថ្នាក់ដឹកនាំកំពូលៗ ។

ស.ស៖ មានចាំពេលទៅថត?

ញ.អ៖ ដូច ធ្លាប់បានរៀបរាប់ពីព្រឹករួចហើយ បានទៅជាមួយគណៈប្រតិភូជួបអ៊ំ នួន ពេលចុះទៅមើលសហករណ៍ ។ ក្នុងក្រុមខ្ញុំមានអ្នកថតប្រាំមួយនាក់ ពេលខ្លះមានការផ្លាស់ប្តូរគ្នា ។

ស.ស៖ មានន័យថា នួន ជា និងថ្នាក់ដឹកនាំធំៗចុះមូលដ្ឋាន?

ញ.អ៖ ចុះទាំងអស់គ្នា ។ តែគ្រាន់តែថា តិចច្រើនមិនដឹងទេ ។

ស.ស៖ តើពេលចុះហ្នឹងលោកឃើញសភាពប្រជាជនយ៉ាងម៉េចដែរ?

ញ.អ៖ ការហូបចុកគ្រប់គ្រាន់ ពេលជួបគណៈតំបន់ តែពេលក្រោយ៧៨ ស្រាប់តែឮថា មានអ្នកអត់បាយ ។

ស.ស៖ នៅក្នុងស-២១ ធ្លាប់ឃើញ ឌុច សួរទេ?

ញ.អ៖ ធ្លាប់ឃើញគាត់សួរម្តង ពេលចាប់អ្នកទោសមកឆ្នាំ៧៧ តាមខ្ញុំដឹងគាត់ចង់បានចម្លើយបញ្ជូនទៅ

អង្គការ ។

អេហ្វ.អិល៖ តើលោកឃើញផ្ទាល់ភ្នែកលោកប៉ុន្មានដង?

[១៥:៥២:៥០]

ញ.អ៖ ឃើញម្តង ។ ពេលនោះគាតជិះម៉ូតូមក ហើយជូនខ្ញុំជិះកង់ ឃើញគាត់វាយនៅមុខទួលស្លែង ព្រោះកន្លែងខ្ញុំធ្វើការនៅទីនោះដែរ ។ ដូច្នេះ ពេលនោះខ្ញុំឃើញ ។

អេហ្វ.អិល៖ ផ្ទះដូចម្តេចដែរនៅផ្នែកខាងណា?

ញ.អ៖ ផ្ទះក្បឿងនៅខាងត្បូង ។

អេហ្វ.អិល៖ ផ្ទះអ្នកណា?

ញ.អ៖ មិនបានចាំទេ ។ ពេលដែលខ្ញុំឃើញនោះ ផ្ទះនោះចំហស្លួរនៅជាន់ក្រោម ។

អេហ្វ.អិល៖ នៅក្នុងផ្ទះលោក ឃើញមានពាងទឹកទេ?

ញ.អ៖ ខ្ញុំមិនបានដឹងទេ ។

អេហ្វ.អិល៖ ពេល ឌុច សួរចម្លើយធ្វើដូចម្តេចខ្លះ?

ញ.អ៖ ធ្វើទារុណកម្ម ដោយវាយនឹងផ្តៅ ។

ស.ស៖ លោកឈប់មើល ឬគ្រាន់តែជិះឃើញ?

ញ.អ៖ គ្រាន់តែជិះឃើញ ។

អេហ្វ.អិល៖ ចុះអ្នកនៅចង្រ្កានបាយ ស្រ៊ុន?

ញ.អ៖ ខ្ញុំដើរចូលទៅ ស្រ៊ុន បាននិយាយឲ្យខ្ញុំជួយផង នៅពេលដែលគេនាំយកទៅសួរចម្លើយ ។

អេហ្វ.អិល៖ បន្ទាប់ពីការសួរចម្លើយហើយ អ្នកទោសនោះក្លាយទៅជាយ៉ាងណា?

ញ.អ៖ អ្នកទាំងនោះមិនអាចត្រឡប់ក្រោយវិញបានទេ ភាគតិចណាស់ យើងឃើញផ្ទាល់នឹងភ្នែកឃើញ ឡានទ្រុងៗ មកគេដឹកអ្នកទោសទៅវាយ តែមិនដឹងយកទៅវាយនៅឯណាទេ ព្រោះកន្លែងខ្ញុំនៅជិតនៅកន្លែងអ្នកទោស ។ ពេលដែលឆ្នាំ៩៥ ក្រោយពេលដែលធ្វើសមាហរណកម្មហើយ ទើបឃើញនៅជើងឯក ។

[១៥:៥៤:៤២]

អេហ្វ.អិល៖ ឈ្មោះ ស្រ៊ី គឺជាជាងថតដែរ?

ញ.អ៖ ស្រ៊ី ក៏ខ្ញុំបង្ហាត់ថតដែរ ។

អេហ្វ.អិល៖ ស-២១ មានពេទ្យទេ?

ញ.អ៖ មានដែរឈ្មោះ ប៉ោ ។ ហើយគេវាយចោលហើយ ។

អេហ្វ.អិល៖ ពេលលោកនៅជិតពេទ្យមុនីវង្ស តើលោកឃើញឈាមដែលស-២១បូមយកទៅឲ្យពេទ្យទេ?

ញ.អ៖ មិនដែលឃើញទេ ។

ស.ស៖ អ្នកនៅថតក្រុមជាមួយបងមានដែល ឌុច ចាប់មកដាក់គុកទេ?

ញ.អ៖ មិនដែលទេ ។

ស.ស៖ ដូចបងរៀបរាប់អ្នកនៅជាមួយគ្នា អ្នកណាខ្លះស្លាប់?

ញ.អ៖ អ្នកដែលមកជាមួយខ្ញុំ ៧៥ ស្រ៊ុន អ្នកដាំបាយ ចន អ្នកយាម ។ ចាប់ ស្រ៊ុន ឆ្នាំ៧៧។ មូលហេតុមកពីចង់បំពុលសម្តេចហភាពគឺ ឌុច ជាអ្នកបញ្ជាឲ្យចាប់ ។ ខ្ញុំដឹងច្បាស់ គឺពីរនាក់មកពីស្រុកខ្ញុំដែលគេយកទៅសម្លាប់ ។

អេហ្វ.អិល៖ លោកបាននិយាយថា គណៈស-២១ មាន ឌុច, ហ៊័, ចាន់ តើអ្នកទាំងបីស៊ីសង្វាក់គ្នាទេ?

ញ.អ៖ គឺស៊ីសង្វាក់គ្នា ព្រោះការដឹកនាំមិនអាច ឌុច សម្រេចម្នាក់ឯងទេ គឺត្រូវប្រជុំគ្នាដែរ ។

អេហ្វ.អិល៖ ចំពោះតែកិច្ចការពិសេស ឬយ៉ាងណា?

ញ.អ៖ ករណីរបស់ខ្ញុំ ជាករណីពិសេសហើយ ។

អេហ្វ.អិល៖ នៅពេលដែលអ្នកទាំងបីសម្រេច ហើយអ្នកណាជាអ្នកបញ្ជា?

ញ.អ៖ គឺគេបញ្ជូនឲ្យអ្នកផ្សេង ។ អ្នកផ្សេងឲ្យសម្រេចការទាំងអស់ ។ បញ្ជូនទៅផ្នែកផ្សេងៗតាមរយៈការសរសេរក្នុងនោះមានចុះហត្ថលេខា តាឌុច រួចផ្ញើទៅ សុន សេន ។ អ្នកដែលស្លាប់នៅស-២១ មានចំនួនមួយម៉ឺននាក់ ។ តែបើមិនមាន ចាន់  ឌុច និង ហ៊័ សម្រេចទេ មិនមានការសម្លាប់ដល់ម្លឹងទេ ។

អេហ្វ.អិល៖ ពេលនោះលោកបានដឹង តួនាទីជាក់លាក់របស់ សុន សេន ទេ?

ញ.អ៖ ខ្ញុំដឹងនៅពេលនោះ គាត់ជារដ្ឋមន្ត្រីក្រសួងការពារជាតិ ទទួលបន្ទុកសន្តិសុខ ។

ស.ស៖ លោកស្គាល់ ប៉ង់ និង នឿន តើលោកជួបគាត់ទៀតទេ?

ញ.អ៖ ខ្ញុំជួបពេលគាត់មកយកឯកសារ ។ គាត់យកឯកសារឲ្យ ប៉ុល ពត ។

ស.ស៖ ឯកសារអ្វី?

ញ.អ៖ ឯកសារជាប្រវត្តិរូប និងចម្លើយសារភាព ។ រឿងនេះខ្ញុំដឹងច្បាស់ណាស់ ពេលដែលពួកនេះមកគឺជិះឡានហ្ស៊ីបមក ។ ក្រោយមក ប៉ង់ ស្លាប់នៅភ្នំពេញចុងឆ្នាំ៧៨ ។

អេហ្វ.អិល៖ កន្លែងណាដែល នឿន និង ប៉ង់ មក?

ញ.អ៖ មកផ្ទះតា ឌុច នៅមុខក្រសួងផែនការ កន្លែងទូតហុងគ្រី ផ្ទះខ្ញុំក៏នៅជិតនោះដែរ ។

អេហ្វ.អិល៖ លោកធ្លាប់ចូលផ្ទះតា ឌុច ទេ? ធ្លាប់ឃើញ ឌុច ធ្វើទារុណកម្មនៅផ្ទះគាត់ទេ?

ញ.អ៖ ធ្លាប់ចូលពេលគាត់ហៅទៅថតប្រពន្ធគាត់ ហើយមិនដែលឃើញគាត់ធ្វើទារុណកម្មនៅផ្ទះគាត់ទេ។

អេហ្វ.អិល៖ រង្វង់ប្អូនជ្រុងកណ្តាលជាបរិវេណស-២១ តើលោកអាចគូសកន្លែងសួរចម្លើយនៅកន្លែងណាខ្លះ?

ញ.អ៖ និយាយរួមកន្លែងសួរចម្លើយ គឺនៅពេញទីនោះតែម្តង ប្រហែលដប់ផ្ទះតែវាមានប្លុកច្រើនហើយប្លុកខ្លះគេមិនឲ្យចូលទេ ។

ស.ស៖ ក្រៅពី ប៉ង់ និង នឿន មាននីរសារក្រុមផ្សេងទេ?

ញ.អ៖ មិនដែលឃើញអ្នកណាផ្សេងទេ ។

ស.ស៖ តើនៅចាំមុខអ្នកទាំងពីរនោះទេ?

ញ.អ៖ មិនចាំទេ ។

អេហ្វ.អិល៖ លោកនៅស-២១ រហូតដល់ពេលណា?

ញ.អ៖ រហូតដល់វៀតណាមចូល ។ កាលណោះខ្ញុំមកធ្វើការមក៦ខែពាក់កណ្តាល៧៨ គេដកខ្ញុំឲ្យទៅគូសផែនទីសមរភូមិវៀតណាមនៅស-២១ ពេលនោះខ្ញុំឈប់ថតរូបហើយ ។

អេហ្វ.អិល៖ ក្នុងរយៈពេលចុងក្រោយ តើលោកធ្លាប់ឃើញគេនាំអ្នកទោសមកទៀតទេ?

ញ.អ៖ នាំមកតែតិចបំផុត ។

អេហ្វ.អិល៖ ពេលនោះមានគេនាំអ្នកទោសមកស-២១ដោយមិនបាច់សួរចម្លើយ ហើយសម្លាប់តែម្តង តើលោកដឹងទេ?

ញ.អ៖ មិនដឹងទេ ។

[១៦:00:00]

អេហ្វ.អិល៖ លោកមានដឹងសល់អ្នកទោសទេ?

ញ.អ៖ ខ្ញុំមិនបានដឹងទេ ។

អេហ្វ.អិល៖ មុនភ្លាមៗ ៧ មករា ៧៩ លោកឃើញអ្នកធំៗមកទេ?

ញ.អ៖ សុន សេន ហៅមកប្រជុំ ពេលនោះគេឲ្យត្រៀមជីកត្រង់សេ ពេលនោះ សុន សេន បញ្ជាឲ្យគូស

ផែនទី ហើយពេលនោះវៀតណាមវាយចូលដល់ក្រចេះ ។
អេហ្វ.អិល៖ លោកបានដឹងថា ទ័ពយួនបានចូលដល់កន្លែងណាៗ តើដឹងមកពីណា?
ញ.អ៖ គណៈបញ្ជាការគ្រប់មុខព្រួយគេផ្ដល់ព័ត៌មានមក ។ សុន សេន គឺសុន សេន មកផ្ទាល់ គឺពួកខ្ញុំ ១២នាក់ ក្រុមនេះដកមកពីខាងជាងថត៣នាក់ ។
ស.ស៖ សុន សេន មកប្រជុំស-២១ ទាំងអស់គ្នាឬ?
ញ.អ៖ គឺប្រជុំទាំងអស់ ឲ្យត្រៀមប្រយុទ្ធជាមួយទ័ពវៀតណាម ។
ស.ស៖ ពេលនោះថ្ងៃ ១ មករា ៧៩ គេនិយាយពីអ្នកទោសនៅស-២១ ត្រូវធ្វើយ៉ាងម៉េច?
ញ.អ៖ នៅឆ្នាំ៧៧ គឺខ្ញុំដឹងតែក្រោយមកមិនដឹងតែម្ដង ។ កម្លាំងស-២១ ទាំងអស់រត់តាមទួលទំពូងស្ពានទូតចិន កន្ទួត មាន ឌុច មាន ចាន់ មាន ផែន កម្លាំងបែកគ្នាពាក់កណ្ដាលនៅកន្ទួត ព្រោះរថក្រោះបញ្ឈរនៅទីនោះ ហើយខ្ញុំបានបែកកម្លាំងគ្នានៅខេត្តកំពង់ស្ពឺ ។
អេហ្វ.អិល៖ ក្រោយមក ឌុច គាត់ទៅណា?
ញ.អ៖ ខ្ញុំមិនដឹងទេ តែបែកខែ២ ឆ្នាំ៧៩ នៅថ្នូគុប អន្លង់ជ្រៃ មិនដែលបានដឹងគាត់ដឹងសោះ ។
អេហ្វ.អិល៖ លោកមានដឹងទេថា ក្នុងជំនាន់នោះមានគេទុកអ្នកទោសសម្រាប់ធ្វើការងារផ្សេងៗទេ?
ញ.អ៖ មិនដឹងទេ ។
អេហ្វ.អិល៖ តាណាត ជាអ្នកទោស ឬអ្នកគូររូប?
ញ.អ៖ គាត់អ្នកទោស ។
ឯកសារថតចម្លង នៃកំណត់ហេតុមួយច្បាប់ត្រូវបានប្រគល់ឲ្យសាក្សីនេះ ។
បញ្ចប់ការស្ដាប់ចម្លើយរបស់សាក្សីនៅម៉ោង ៤ និង១២ នាទីថ្ងៃខែឆ្នាំដដែល ។
សាក្សីបានផ្ដល់រូបថតចំនួនបីសន្លឹក និងសៀវភៅរៀនបច្ចេកទេស ថតកាលគាត់រៀននៅប្រទេសចិន ។ អានឲ្យស្ដាប់ហើយសាក្សីមិនមានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា ។
សាក្សី ញ៉ែម អេន ។”

**ប្រធានអង្គជំនុំ៖**

ក្រោយពីបានស្ដាប់នូវការអានដោយក្រឡាបញ្ជីសវនាការ នូវចម្លើយសាក្សីដែលកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម អេន ដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត តើតំណាងសហព្រះរាជអាជ្ញាមានអ្វីចង់កត់សម្គាល់កំណត់ហេតុនេះដែរឬទេ?

**លោក តាន់ សេណារ៉ុង៖**

សូមគោរពលោកប្រធានអង្គជំនុំជម្រះ តំណាងសហព្រះរាជអាជ្ញាគ្មានយោបល់ជំទាស់ជាមួយនឹងកំណត់ហេតុលើសាក្សីឈ្មោះ ញ៉ែម អេន នេះទេ ។

**ប្រធានអង្គជំនុំ៖**

ខាងមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី តើមានអ្វីកត់សម្គាល់អំពីខ្លឹមសារនៃកំណត់ហេតុរបស់សាក្សី ញ៉ែម អេន ដែលបានអានដោយក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះដែរឬទេ?

**លោក អាឡាំង វែនណឺ៖**

យើងមិនមានការជំទាស់អ្វីទេ ។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្តី តើមានអ្វីកត់សម្គាល់លើកំណត់ហេតុនៃការស្តាប់សក្ខីកម្មសាក្សី ញ៉ែម អេន ដែលអានដោយក្រឡាបញ្ជីសវនាការអំមិញនេះដែរឬទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ជនជាប់ចោទនឹងមានសេចក្តីសង្កេតមួយចំនួននៅលើកំណត់ហេតុនេះ ។ ប៉ុន្តែសូមអនុញ្ញាតឲ្យខ្ញុំសូមបញ្ជាក់ក្នុងនាមមេធាវីការពារថា ដំណើរការនីតិវិធីរបស់យើងត្រូវបានអនុវត្តបានល្អប្រសើរជាងអ្វីដែលយើងបានគ្រោងទុក ។ ហើយខ្ញុំក៏នៅតែយល់ថា តើសហព្រះរាជអាជ្ញាបានទទួលជោគជ័យ បានជោគជ័យក្នុងការដាក់សាក្សីនេះនៅក្នុងបញ្ជី ហើយដែលបានជាពិសេសអរគុណចំពោះអង្គជំនុំជម្រះដែលបានអនុញ្ញាតឲ្យយើងបានស្តាប់នូវសក្ខីភាព ដែលថា គាត់បានទទួលសាក្សីនេះក៏បានជួបជាមួយអ្នកកាសែត ហើយអ្នកស្រាវជ្រាវជាច្រើនហើយ ។ ហើយយើងមិនចាំបាច់មានមតិយោបល់អ្វីនោះទៀតទេ ។

[១៦:០៥:៤៤]

**ប្រធានអង្គជំនុំ៖**

លោក ហ្វ្រង់ស្វ័រ រូ សូមលោកបញ្ជាក់ម្តងទៀត តើជំហររបស់លោកចំពោះកំណត់ហេតុដែលអានដោយក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ លោកចង់មានយោបល់ថាម៉េចច្បាស់លាស់?

សូមអញ្ជើញលោក ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អរគុណលោកប្រធាន ។ ខ្ញុំសូមឲ្យលោកមេធាវី រូ បញ្ជាក់ខាងមេធាវីការពារបញ្ជាក់ថាតើលោកមានការជំទាស់ ឬក៏មិនមានទៅលើហ្នឹងសក្ខីកម្មរបស់សាក្សី ហើយនិងតើលោកជនជាប់ចោទលោកអាចនឹងបញ្ជាក់ដើម្បីថា លោកមេធាវីអាចបញ្ជាក់ថា លោកមានការជំទាស់ ឬក៏មិនមាន ឬក៏លោកចង់នាំសាក្សីនេះមកបំភ្លឺនៅតុលាការ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

យើងខ្ញុំមិនស្នើសុំឲ្យកោះអញ្ជើញសាក្សីឲ្យមកតុលាការទេ វាអាចនឹងចំណាយពេលច្រើន។ យើងក៏មិនជំទាស់ទៅនឹងឯកសារដែលត្រូវលើកមកពិភាក្សាដេញដោលក្នុងតុលាការដែរ ប៉ុន្តែយើងជំទាស់យ៉ាងរឹងមាំ ទៅនឹងខ្លឹមសារនេះ ។ នេះជាពាក្យលោកហ្វ្រង់ស្វ័រ រូ ។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិមានយោបល់អ្វី ចង់មានយោបល់អ្វី?

**លោក អានីស អះមេដ៖**

ការជំទាស់របស់ខ្ញុំដែលថា ចំណុចដែលចៅក្រម ខាតវាយថ៍ បានលើកឡើងនោះខ្ញុំឯកភាព ប៉ុន្តែមេធាវីការពារបានលើកឡើងនោះគាត់មិនមានបំណងជំទាស់ទៅនឹងតម្លៃខ្លឹមសារសក្ខីភាពទេ ប៉ុន្តែគាត់ទទួលស្គាល់ថា គាត់មិនចង់កោះហៅសាក្សី ។ អ៊ីចឹងយើងនឹងត្រៀមខ្លួនដើម្បីតទល់នឹងអ្វីដែលគាត់ថាជំទាស់ទៅនឹងខ្លឹមសារនៃសក្ខីកម្មនេះ ។

**ប្រធានអង្គជំនុំ៖**

[១៦:០៨:៥៤]

អញ្ជើញលោកហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមឲ្យមានការច្បាស់លាស់គឺថាមេធាវីជំទាស់ដាច់ខាតទៅលើភាពជឿជាក់របស់សាក្សីនេះ ប៉ុន្តែមេធាវីមិនជំទាស់ថា ចំពោះការដាក់ឯកសារនេះដេញដោលចំពោះតុលាការទេ ដូចដែលយើងបានបញ្ជាក់ខាងដើម ។ ប៉ុន្តែ យើងជំទាស់ជាដាច់ខាត ហើយជឿជាក់បានទៅលើសាក្សីនេះ ហើយជនជាប់ចោទនិងផ្តល់សេចក្តីបន្ទាប់ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តទៅនេះ អង្គជំនុំជម្រះទុកផ្តល់ឱកាសដល់ជនជាប់ចោទដើម្បីធ្វើការកត់សម្គាល់លើខ្លឹមសារនៃការស្តាប់សក្ខីកម្មរបស់សាក្សី ញ៉ែម អែន ដោយអ្នកស៊ើបអង្កេតនៃអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដោយបានអានដោយក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ។

សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! សក្ខីកម្មរបស់ ញ៉ែម អែន ខ្ញុំសូមចែកជាពីរ ។ ទីមួយគឺសក្ខីកម្មរបស់គាត់ជុំវិញការថតនៅស-២១ ។ ចំណុចនេះមានការលើសខ្វះខ្លះក៏ពិតមែន ក៏ប៉ុន្តែត្រឹមត្រូវជាមូលដ្ឋាន ។ ចំណុចទីពីរ ពីរឿងប្រវត្តិគាត់ទៅរៀននៅស្រុកចិនគាត់ធ្លាប់ទៅថតដឹកនាំ ជារឿងប្រឌិត ។ សភាពការណ៍ពិតគឺយ៉ាងនេះ ។ ឆ្នាំ១៩៧៦ ទើប ប៉ុល ពត គាត់បញ្ជូនក្មួយគាត់ទៅរៀនថតរូបនៅស្រុកចិន គឺមិត្តថេង ហៅ ពូល គ្មាន ញ៉ែម អែន ទេ ទៅស្រុកចិន ។ ហើយក៏ ញ៉ែម អែន ជាកូនបុគ្គលិកមួយ ខាងថតរូបនៅស-២១ អត់មានសិទ្ធិចេញទៅថតឯណាទេ ។ ប្រធានថតរូបនៅស-២១ គឺ នឹម គីមស្រៀង ថតនៅខាងក្នុង ។ បន្ទាប់មក បុគ្គលទីពីររបស់អ្នកថតរូបគឺមិត្ត សុង ទៅថតនៅព្រៃស ។ មិត្តសុង នេះខ្ញុំឃើញឲ្យសម្ភាសន៍ជាមួយកាសែតក្នុងស្រុកច្រើនដែរមុននឹងអយ្យការយោធានាំខ្ញុំយកមកឃុំឃាំង ។ គឺ១៩៩៦ គឺខ្ញុំឃើញសេចក្តីសម្ភាសន៍របស់ មិត្តសុង ដាក់ចុះក្នុងកាសែតក្នុងស្រុក។ ឯចំណែក មិត្តស្រ៊ី ត្រូវហើយ។ មិត្តស្រ៊ី គាត់ជាកងពិសេស ថតកន្លែងណាដែលគេសម្លាប់ ។ បុគ្គលសំខាន់ដូច យ៉ាង វន វ៉េត, ណាត, បង ឆាយ គឹមហ៊ី ហៅហុក អាហ៊្វីង ស្រ៊ី គេអ្នកថត ។ នេះការដែល ញ៉ែម អែន អួតគឺចេះតែទៅហើយ ។ ទៅរៀនស្រុកចិន ៦ខែ ចេះបីមុខវិជ្ជាគឺថតរូបផង ថតកុនផង គូរផែនទីផង ។ សរុបមក គាត់អួតច្រើន ។ ក៏ប៉ុន្តែខ្ញុំសរុបឡើងវិញ សក្ខីកម្មគាត់លើការងារថតរូបនៅស-២១ មានលើសខ្វះបន្តិចបន្តួច។ ដូចគាត់អួតថា គាត់ទៅថតផ្ទះខ្ញុំឲ្យប្រពន្ធខ្ញុំអត់ទេ ។ អាហ៊្វីងខ្ញុំនិយាយឲ្យត្រង់ទៅចុះ ។ ខ្ញុំមានម៉ាស៊ីនថតមួយខ្ញុំថតក្នុងគ្រួសារខ្ញុំ ។ ហើយខ្ញុំហៅ មិត្តស្រៀង ឲ្យផ្តិត ។ នេះខ្ញុំសូមបញ្ចប់ប៉ុណ្ណោះ ដោយគោរព ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវសម្រាកនៅពេលល្ងាចហើយ ដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តនៅថ្ងៃស្អែកចាប់ពីម៉ោងប្រាំបួនព្រឹកទៅ ។ ហើយ

ថ្ងៃស្អែកអង្គជំនុំជម្រះនឹងធ្វើការដេញដោលទៅលើសាក្សីមួយរូបដែល KW-22 ហើយបញ្ហានេះអង្គជំនុំជម្រះសូមបញ្ជាក់ជាថ្មីជម្រាបជូនដល់ភាគីទាំងអស់ដែលពាក់ព័ន្ធដើម្បីបានជ្រាប ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញហើយឲ្យនាំគាត់មកកាន់សាលសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំណត់ ៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការផ្អាកនៅម៉ោង ១៦ និង ១៤ នាទី]*